# បុព្វកថា

ពិធីសារក្យូតូ ដែលត្រូវបានចុះហត្ថលេខាក្នុងឆ្នាំ 1997 បានចូលជាធរមានជាស្ថាពរ នៅថ្ងៃទី 16 ខែ កុម្ភៈ ឆ្នាំ 2005 ។ ចាប់តាំងពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងម៉ារ៉ាកេស ក្នុងឆ្នាំ 2001 ដែលបានដាក់ចេញនូវវិធានជាមូលដ្ឋានមួយចំនួនសំរាប់បណ្តាយន្តការនៃពិធីសារក្យូតូ ដូចជា យន្តការអភិវឌ្ឍន៏ស្អាត (CDM) ការអនុវត្តរួម (JI) និងការធ្វើពាណិជ្ជកម្មលើការបញ្ចេញឧស្ម័ន (ET) រួចមក យន្តការអភិវឌ្ឍន៏ស្អាតបានក្លាយជាគំរូនាំមុខគេ ដោយមានគំរោងដែលបានចុះឈ្មោះចំនួន 12 និងគំរោងជាង 150 ទៀត កំពុងស្ថិតនៅក្នុងដំណាក់កាលផ្តល់សុពលភាព នៅពេលបោះពុម្ពផ្សាយសៀវភៅមគ្គុទ្ទេសក៏នេះ ។ យន្តការអភិវឌ្ឍន៏ស្អាតត្រូវបានរៀបចំឡើង ដើម្បីជួយដល់ប្រទេស ដែលនៅក្នុងឧបសម្ព័ន្ធទី 1 ក្នុងការបំពេញគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ពួកគេ តាមរយៈការអនុវត្តគំរោងកាត់បន្ថយ/ស្រូបយកកាបូន នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៏ និងគណនាបរិមាណឧស្ម័នដែលបានកាត់បន្ថយ/ស្រូបយកកាបូន ជា "ឥណទាន" ដែលអាចទិញបាន ។ មុនពេលដែលពិធីសារនេះចូលជាធរមាន វិនិយោគគិន និងអ្នករៀបចំគំរោងជាច្រើន រារែកចិត្តក្នុងការធ្វើសកម្មភាពខាងផ្នែកគំរោងយន្តការអភិវឌ្ឍន៏ស្អាត ។ ចាប់តាំងពីពិធីសារនេះចូលជាធរមានមក ចំនួនគំរោងដែលបានដាក់សុំការផ្តល់សុពលភាព និងការចុះបញ្ជីការ មានការកើនឡើងគួរឱ្យកត់សំគាល់ ហើយនិន្នាការកំណើននេះ នឹងនៅតែបន្ត ក្នុងរយៈពេលពីរបីឆ្នាំ ទៅមុខទៀត ។

ទោះបីជាមានតំរូវការខ្ពស់ក្នុងការប្រើប្រាស់យន្តការអភិវឌ្ឍន៏ស្អាត និងការបន្តកែតំរូវវិធានច្បាប់យន្តការអភិវឌ្ឍន៏ស្អាតក៏ដោយ ក៏វិនិយោគគិន និងអ្នករៀបចំគំរោងជាច្រើន នៅតែមានការលំបាកក្នុងការអនុវត្តគំរោង ។ មានកត្តានានាជាច្រើន ដែលជាឧបសគ្គក្នុងការទាក់ទាញការវិនិយោគពីបរទេស ដែលក្នុងនោះរួមមានបញ្ហាដោយឡែករបស់ប្រទេសនីមួយៗផង ។ ប៉ុន្តែបញ្ហាមួយដែលមានទំនាក់ទំនងដោយផ្ទាល់ ជាមួយនឹងប្រសិទ្ធភាពនៃការអនុវត្តគំរោងយន្តការអភិវឌ្ឍន៏ស្អាត គឺការមិនបានប្រុងប្រៀបជាមុនរបស់ប្រទេសកំពុងអភិវឌ្ឍន៏ ដើម្បីទទួលធ្វើជាម្ចាស់គំរោងនានា ។ មូលហេតុមួយចំនួននៃបញ្ហានេះ រួមមាន ការរៀបចំស្ថាប័នដែលមិនទាន់មានលក្ខណៈពេញលេញ ប្រព័ន្ធផ្តល់ការអនុម័តលើគំរោងមានលក្ខណៈស្មុគស្មាញ បុគ្គលិករដ្ឋាភិបាលខ្វះបទពិសោធន៏ និងកង្វះខាតកិច្ចសហការគ្នារវាងក្រសួង និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ ។ ដូច្នេះ គេចាំបាច់ត្រូវកែលំអរស្ថានភាពនៅក្នុងប្រទេសម្ចាស់គំរោងក្នុងគោលបំណងលើកស្ទួយសកម្មភាពគំរោង CDM និងរួមចំណែកក្នុងការខិតខំប្រឹងប្រែងជាសកលដើម្បីប្រយុទ្ធ ប្រឆាំងនឹងការឡើងកំដៅផែនដី ។

យុទ្ធសាស្ត្រសំខាន់ៗចំនួនពីរ ដើម្បីជំរុញប្រទេសម្ចាស់គំរោងឱ្យចេះប្រើប្រាស់គំរោងយន្តការអភិវឌ្ឍន៏ស្អាត គឺ *ការប្រមូល/ការរៀបចំឡើងវិញ/ការចែករំលែកព័ត៌មាន* និង*ការកសាងសមត្ថភាព* ។ ប្រទេសម្ចាស់ផ្ទះភាគច្រើនមានព័ត៌មានដែលពាក់ព័ន្ធរួចស្រេចទៅហើយ ប៉ុន្តែច្រើននៅបែកខ្ញែកពីគ្នា ឬមិនត្រូវបានយកមកធ្វើការពិចារណាផ្នែកគំរោង CDM ហើយព័ត៌មានទាំងអស់នោះមិនដែលត្រូវបានដាក់បញ្ចូលគ្នានៅក្នុងទំរង់មួយ ដែលមានលក្ខណៈ

ទូលំទូលាយឡើយ ។ នេះគឺជាមូលហេតុចំបង នៃការបោះពុម្ពស៊េរីសៀវភៅមគ្គុទ្ទេសក៍នេះ ដែលបង្ហាញពីព័ត៌មានរបស់ប្រទេសមួយចំនួននៅអាស៊ី ។ ដើម្បីឱ្យសៀវភៅមគ្គុទ្ទេសក៍នេះកាន់តែមានភាពងាយស្រួលសំរាប់អ្នកអានសៀវភៅទាំងនេះបង្ហាញព័ត៌មានសំខាន់ៗ ដែលអ្នករៀបចំគំរោង និងវិនិយោគិនត្រូវការ ដើម្បីធ្វើការរៀបចំ និងអនុវត្តគំរោង CDM ឱ្យមានប្រសិទ្ធភាពបំផុតនៅក្នុងប្រទេសនីមួយៗ ។

សៀវភៅមគ្គុទ្ទេសក៍នេះ គឺជាផ្នែកនៃស៊េរីសៀវភៅមគ្គុទ្ទេសក៍ ដែលត្រូវបានរៀបចំឡើងសំរាប់ការប្រើប្រាស់ជាសំខាន់នៅក្នុងសកម្មភាពផ្សព្វផ្សាយព័ត៌មាន និងលើកកំពស់ការយល់ដឹង ក្រោមកម្មវិធីពង្រឹងសមត្ថភាពចំរុះសំរាប់យន្តការអភិវឌ្ឍន៍ស្អាត/ការអនុវត្តរួម របស់ក្រសួងបរិស្ថាននៃប្រទេសជប៉ុន ។

Akio Morishima
ប្រធាន គណៈកម្មការនាយក IGES

# សេចក្តីថ្លែងអំណរគុណ

សៀវភៅមគ្គុទ្ទេសក៏នេះ ត្រូវបានរៀបរៀងឡើងដោយវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក (IGES) ក្រោមកម្មវិធីពង្រឹងសមត្ថភាពចំរុះសំរាប់យន្តការអភិវឌ្ឍន៏ស្អាត និងការអនុវត្តរួម (ICS-CDM/JI) ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងបរិស្ថាននៃប្រទេសជប៉ុន ដែលបានផ្តល់នូវការជួយឧបត្ថម្ភយ៉ាងមានតំលៃ ដើម្បីធ្វើឱ្យគំរោងនេះអាចដំណើរការទៅមុខបាន ។

ការចងក្រងសៀវភៅនេះនឹងមិនអាចសំរេចបានឡើយ ប្រសិនបើពុំមានការគាំទ្រពីការិយាល័យប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថានរបស់ព្រះរាជាណាចក្រកម្ពុជា ។

លោក Keisuke Iyadomi មន្ត្រីកម្មវិធីសំរាប់ប្រទេសកម្ពុជានៃវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក និងលោកស្រី Yukimi Shimura ប្រធានក្រុមការងារកែសំរួលសើរីសៀវភៅមគ្គុទ្ទេសក៏ CDM នៃវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក គឺជាអ្នកទទួលខុសត្រូវខាងការកែសំរួលមាតិការបស់សៀវភៅមគ្គុទ្ទេសក៏ទាំងនេះ នៅក្រោមការគ្រប់គ្រងរបស់លោក Shinichi Iioka អ្នកគ្រប់គ្រងកម្មវិធី CDM នៃ IGES ។ បណ្ឌិត Thanakavaro De Lopez នៃមជ្ឈមណ្ឌលស្រាវជ្រាវកម្ពុជាដើម្បីអភិវឌ្ឍន៏ ជាអ្នករៀបចំសំណៅដើម ដោយលោកបានចងក្រងស្ថិតិ របាយការណ៏ បទបញ្ញត្តិ ច្បាប់ និងព័តិមានពាក់ព័ន្ធនឹងការវិនិយោគទាំងអស់ ឱ្យក្លាយទៅជាឯកសារមួយមានភាពងាយស្រួលសំរាប់អ្នកអាន ។ លោក Greg Helten បានផ្ទៀងផ្ទាត់ឡើងវិញគ្រប់អត្ថបទទាំងអស់ ហើយបានធ្វើការងារយ៉ាងច្រើនក្នុងការកែសំរួលអត្ថបទ ។ លោកស្រី Akiko Sato នៃវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោកក៏បានផ្តល់ជាមតិយោបល់ជាច្រើនដើម្បីធ្វើឱ្យសៀវភៅមគ្គុទ្ទេសក៏នេះ មានភាពងាយស្រួលសំរាប់អ្នកអាន ។

វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក ក៏សូមថ្លែងអំណរគុណជាពិសេសដល់បណ្ឌិត ទិន ពន្លក និង លោក ស៊ុំ ធី នៃក្រសួងបរិស្ថានរបស់ប្រទេសកម្ពុជា និងសហការីរបស់លោកទាំងពីរ នៅក្នុងការិយាល័យប្រែប្រួលអាកាសធាតុ ដែលបានផ្តល់នូវការគាំទ្រយ៉ាងច្រើន ក្នុងការធ្វើឱ្យសៀវភៅមគ្គុទ្ទេសក៏នេះសមស្របទៅនឹងស្ថានភាពជាក់ស្តែង និងមានព័តិមានថ្មីៗ ។

បណ្ឌិត Kayo Ikeda លោក Jun Ichihara លោក Kazuhisa Koakutsu និងលោកស្រី Sakae Seki នៃវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក បានផ្តល់នូវការគាំទ្រយ៉ាងច្រើននៅក្នុងពេលអនុវត្តគំរោង ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេសដល់លោក Kiyoto Tanabe កម្មវិធីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ (IPCC NGGIP) នៃក្រុមប្រឹក្សាអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ ដែលបានផ្តល់មតិមានតំលៃជាច្រើន ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះការិយាល័យប្រែប្រួលអាកាសធាតុកម្ពុជា ដែលបានអនុញ្ញាតឱ្យប្រើប្រាស់រូបថតនៅលើក្របសៀវភៅនេះ ។

## បញ្ជីមាតិកា


**បញ្ជីប្រអប់ រូបភាព និងតារាង .....XI**

**អក្សរកាត់.....XIII**

**សេចក្តីសង្ខេប.....XVII**

**1. សេចក្តីផ្តើម .....1**

**2. ព័ត៌មានអំពីសង្គម សេដ្ឋកិច្ច និងនយោបាយ.....3**

2.1 ព័តិមានអំពីប្រទេស.....3

2.2 ព័តិមានអំពីសង្គម .....4

2.3 ព័តិមានអំពីសេដ្ឋកិច្ច.....5

2.4 ព័តិមានអំពីនយោបាយ .....12

**3. វដ្តគំរោងយន្តការអភិវឌ្ឍន៍ស្អាត.....16**

3.1 ទិដ្ឋភាពទូទៅនៃគំរោងយន្តការអភិវឌ្ឍន៍ស្អាត.....16

3.2 សកម្មភាពគំរោងដែលអាចអនុវត្តបាន.....18

3.3 ចំណាត់ថ្នាក់សកម្មភាពគំរោង CDM.....19

3.4 គំរោង CDM ខ្នាតតូច.....20

3.5 វិស័យព្រៃឈើ និងយន្តការអភិវឌ្ឍន៍ស្អាត.....22

3.6 ឥណទាន និងរយៈពេលផ្តល់ឥណទាន .....23

3.7 ទិដ្ឋភាពរួមនៃវដ្តគំរោង CDM.....25

3.7.1 ការបង្កើតគំរោង.....25

3.7.2 ការរៀបចំឯកសារប្លង់គំរោង .....27

3.7.3 លក្ខខណ្ឌគោល .....27

3.7.4 ផលបន្ថែម (Additionality).....30

3.7.5 ការទទួលបានការអនុម័តពីប្រទេសម្ចាស់គំរោង.....32

3.7.6 ការផ្តល់សុពលភាព និងការចុះបញ្ជីការ.....33

3.7.7 ការពិនិត្យតាមដានសកម្មភាពគំរោង CDM.....35

3.7.8 ការផ្ទៀងផ្ទាត់ និង ការបញ្ជាក់ .....35

3.7.9 ការចេញ CERs .....36

**4. សក្តានុពលសំរាប់គំរោង CDM នៅក្នុងប្រទេសកម្ពុជា ........ 37**

4.1 សេចក្តីសង្ខេបនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងប្រទេសកម្ពុជា ........ 37

4.2 សក្តានុពលសំរាប់គំរោង CDM នៅក្នុងវិស័យថាមពល ........ 38

4.2.1 ទិដ្ឋភាពទូទៅ ........ 38

4.2.2 សក្តានុពលសំរាប់គំរោង CDM នៅក្នុងវិស័យថាមពលវារីអគ្គិសនី........ 40

4.2.3 សក្តានុពលសំរាប់គំរោង CDM នៅក្នុងជីវថាមពល........ 40

4.2.4 សក្តានុពលសំរាប់គំរោង CDM នៅក្នុងថាមពលពន្លឺព្រះអាទិត្យ ........ 42

4.2.5 សក្តានុពលសំរាប់គំរោង CDM នៅក្នុងថាមពលខ្យល់........ 42

4.2.6 សក្តានុពលសំរាប់គំរោង CDM នៅក្នុងប្រសិទ្ធភាពថាមពល ........ 43

4.3 វិស័យព្រៃឈើ........ 46

4.3.1 និន្នាការកាប់ព្រៃឈើ និង សិទ្ធិទទួលជាគំរោង CDM ........ 46

4.3.2 សក្តានុពលសំរាប់គំរោង CDM ដាំព្រៃ/ស្តារព្រៃឡើងវិញខ្នាតតូច........ 50

**5. ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងយន្តការអភិវឌ្ឍន៍ស្អាត ........ 53**

5.1 រចនាសម្ព័ន្ធបច្ចុប្បន្ននៃស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតរបស់ប្រទេសកម្ពុជា ........ 53

5.2 ការរៀបចំស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតរបស់ប្រទេសកម្ពុជានៅពេលអនាគត........ 55

**6. តម្រូវការ និងនីតិវិធីអនុម័តគំរោងយន្តការអភិវឌ្ឍន៍ស្អាត ........ 60**

6.1 តារាងវាយតម្លៃ និងលក្ខណៈវិនិច្ឆ័យការអភិវឌ្ឍប្រកបដោយចីរភាព........ 60

6.2 នីតិវិធីអនុម័តគំរោងបច្ចុប្បន្ន ........ 61

6.3 នីតិវិធីដែលបានស្នើឡើងសំរាប់អនុម័តគំរោង........ 62

**7. ច្បាប់ និងបទបញ្ញត្តិនានា........ 66**

7.1 ច្បាប់វិនិយោគ........ 66

7.2 ការកំហិតនៃការវិនិយោគដែលពាក់ព័ន្ធជាមួយនឹងគំរោង CDM........ 67

7.3 ច្បាប់បរិស្ថាន ........ 68

7.4 បទបញ្ញត្តិផ្សេងៗទៀត ដែលអាចយកមកអនុវត្តចំពោះគំរោងថាមពល CDM........ 69

7.5 បទបញ្ញត្តិ ដែលអាចយកមកអនុវត្តចំពោះគំរោងព្រៃឈើ CDM........ 70

**8. បញ្ហាហិរញ្ញវត្ថុ និង សារពើពន្ធ ........ 73**

8.1 ប្រព័ន្ធហិរញ្ញវត្ថុ ........ 73

8.2 បញ្ហាសារពើពន្ធ ........ 75

**9. ការលើកទឹកចិត្តរបស់រដ្ឋាភិបាល.....77**
9.1 ការលើកទឹកចិត្តលើការវិនិយោគបរទេស .....77
9.2 ការលើកទឹកចិត្តពន្ធបន្ថែម.....78
9.3 ការលើកទឹកចិត្តផ្នែកថាមពលកកើតឡើងវិញ.....79

**សេចក្តីបន្ថែម.....83**
សេចក្តីបន្ថែម 1. បញ្ជីឈ្មោះប្រទេសដែលនៅក្នុងឧបសម្ព័ន្ធ 1 និងឧបសម្ព័ន្ធ B* .....84
សេចក្តីបន្ថែម 2. បញ្ជីឈ្មោះវិធីសាស្រ្តដែលបានអនុញ្ញាត និងបង្រួមចូលគ្នា.....86
សេចក្តីបន្ថែម 3. វិធីសាស្រ្តគោលងាយ និងវិធីសាស្រ្តពិនិត្យតាមដាន .....89
សេចក្តីបន្ថែម 4. តារាងវាយតំលៃ និងការវិនិច្ឆ័យការអភិវឌ្ឍដោយចីរភាព.....90
សេចក្តីបន្ថែម 5. ឈ្មោះមន្រ្តីទំនាក់ទំនងនៅក្នុងស្ថាប័នរដ្ឋាភិបាលដែលទាក់ទងនឹង CDM .....100
សេចក្តីបន្ថែម 6. គេហទំព័រដែលពាក់ព័ន្ធ.....102
សេចក្តីបន្ថែម 7. សន្ទានុក្រម.....103

**ឯកសារយោង .....106**

# បញ្ជីប្រអប់ រូបភាព និងតារាង

## បញ្ជីប្រអប់

ប្រអប់ទី 2.1. ផែនការ 12 ចំនុចរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកែលំអបរិស្ថានវិនិយោគ............................11
ប្រអប់ទី 3.1. ឧស្ម័នផ្ទះកញ្ចក់ទាំង 6 ដែលបានចែងនៅក្រោមពិធីសារក្យូតូ.............................................17
ប្រអប់ទី 3.2. របៀបធ្វើការកំណត់ថាតើគំរោងមួយ អាចយកមកពិចារណាបំបែកទៅជាគំរោងតូចៗ បានដែរឬទេ.............................................................................................22
ប្រអប់ទី 3.3. អង្គភាពប្រតិបត្តិការដែលត្រូវបានចាត់តាំង.................................................................34
ប្រអប់ទី 7.1. សេចក្តីសង្ខេបច្បាប់វិនិយោគសំខាន់ៗ.......................................................................66
ប្រអប់ទី 7.2. ដំណាក់កាលដើម្បីទទួលបានអាជ្ញាប័ណ្ណវិនិយោគក្នុងប្រទេសកម្ពុជា....................................67
ប្រអប់ទី 7.3. សេចក្តីសង្ខេបនៃច្បាប់បរិស្ថានសំខាន់ៗរបស់ប្រទេសកម្ពុជា.............................................68
ប្រអប់ទី 9.1. បណ្តាប្រទេសសំខាន់ៗដែលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគទ្វេភាគីជាមួយ ......78
ប្រអប់ទី 9.2. វិស័យវិនិយោគ CDM ដែលមានសក្តានុពលអាចយកការលើកទឹកចិត្តមកអនុវត្តជាមួយបាន........78
ប្រអប់ទី 9.3. គោលដៅ 10 ឆ្នាំ នៃផែនការសកម្មភាពអគ្គិសនីកកើតឡើងវិញ........................................80
ប្រអប់ទី 9.4. តួនាទីរបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ និងថាមពលកកើតឡើងវិញ........................81

## បញ្ជីរូបភាព

រូបភាពទី 2.1. ផែនទីប្រទេសកម្ពុជា ..........................................................................................4
រូបភាពទី 2.2. រចនាសម្ព័ន្ធអភិបាលកិច្ចសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា.......................................15
រូបភាពទី 3.1. ដ្យាក្រាមបង្ហាញអំពីការបំពេញមុខងាររបស់ CDM....................................................17
រូបភាពទី 3.2. ចំណាត់ថ្នាក់ប្រភេទរង នៃសកម្មភាពគំរោង CDM.....................................................19
រូបភាពទី 3.3. ទិដ្ឋភាពទូទៅនៃវដ្តគំរោង CDM..........................................................................26
រូបភាពទី 3.4. សេណារីយ៉ូគោល ..............................................................................................28
រូបភាពទី 3.5. សេណារីយ៉ូគោល និងការស្រូបយកឧស្ម័ន GHG ដោយអាងស្តុកកាបូន..............................29
រូបភាពទី 3.6. ការគណនាសម្រូបឧស្ម័ន GHG សុទ្ធដោយអាងស្រូបកាបូន...........................................30
រូបភាពទី 3.7. ការវាយតំលៃគំរោង ដោយប្រើមធ្យោបាយផលបន្ថែម ..................................................31
រូបភាពទី 4.1. ចំណែកនៃការបញ្ចេញ GHGs ធំៗទាំងបី (A) និងការបញ្ចេញ $CO_2$e សរុបតាមវិស័យ (B) .38

រូបភាពទី 4.2. ផែនទីគំរបដីរបស់ប្រទេសកម្ពុជា ........................................................................ 50
រូបភាពទី 5.1. វច្ចនាសម្ព័ន្ធបច្ចុប្បន្នសំរាប់ការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា................................ 54
រូបភាពទី 6.1. ដ្យាក្រាមនៃដំណើរការអនុម័តគំរោង CDM នៅកម្ពុជា................................................. 64
រូបភាពទី 6.2. រយៈពេល និងសកម្មភាពសំរាប់ការវាយតំលៃគំរោង CDM ដែលបានស្នើឡើងនៅកម្ពុជា.......... 65
រូបភាពទី 7.1. សេចក្តីសង្ខេបអំពីច្បាប់សំខាន់ៗ ដែលពាក់ព័ន្ធជាមួយនឹងគំរោង CDM នៅក្នុងប្រទេសកម្ពុជា..... 72

## បញ្ជីតារាង

តារាងទី 2.1. ព័ត៌មានសំខាន់ៗរបស់ប្រទេស ...................................................................................... 3
តារាងទី 2.2. តំលៃផលទុនជាតិសរុបរបស់ប្រទេសកម្ពុជា តាមសកម្មភាពសេដ្ឋកិច្ច គិតជាលានរៀលក្នុង
តំលៃបច្ចុប្បន្ន........................................................................................................ 6
តារាងទី 2.3. អត្រាកំណើនផលទុនជាតិសរុបរបស់កម្ពុជាតាមសកម្មភាពសេដ្ឋកិច្ច ក្នុងតំលៃបច្ចុប្បន្ន................. 8
តារាងទី 2.4. ជំនួយផ្លូវការពីបរទេសដល់ប្រទេសកម្ពុជា គិតជាពាន់លានរៀល ........................................... 9
តារាងទី 2.5. សន្ទស្សន៍តំលៃអ្នកប្រើប្រាស់នៅទីក្រុងរបស់ប្រទេសកម្ពុជា................................................ 9
តារាងទី 2.6. អត្រាប្តូរប្រាក់រៀល ជាមួយប្រាក់ដុល្លារអាមេរិច........................................................... 9
តារាងទី 2.7. របបនយោបាយរបស់ប្រទេសកម្ពុជាពីឆ្នាំ 1863 ដល់ពេលបច្ចុប្បន្ន....................................... 14
តារាងទី 2.8. អាណត្តិការិយាល័យសំរាប់អ្នកដឹកនាំនយោបាយ.......................................................... 14
តារាងទី 3.1. ប្រភេទគំរោង ដែលអាចអនុវត្តបាននៅក្រោម CDM ..................................................... 19
តារាងទី 3.2. ឥណទាន និងរយៈពេលផ្តល់ឥណទាន សំរាប់សកម្មភាពគំរោង CDM................................. 24
តារាងទី 3.3. លក្ខណៈវិនិច្ឆ័យសំរាប់ការបង្ហាញហេតុផលលើផលបន្ថែមសំរាប់សកម្មភាពគំរោង CDM ខ្នាតតូច.. 32
តារាងទី 3.4. ថ្លៃចុះបញ្ជីការសំរាប់គំរោង CDM ........................................................................ 35
តារាងទី 4.1. គំរោងប្រសិទ្ធភាព និងការសន្សំសំចៃថាមពលប្រកបដោយសក្តានុពល ដែលបានកំណត់.............. 44
តារាងទី 4.2. និន្នាការបាត់បង់ព្រៃឈើក្នុងប្រទេសកម្ពុជា តាមបណ្តាខេត្ត ............................................ 47
តារាងទី 4.3. ដីព្រៃតាមបណ្តាខេត្តក្នុងឆ្នាំ 1985- 87 និង 1992/93................................................... 48
តារាងទី 5.1. សេចក្តីសង្ខេបអំពីអ្នកដើរតួសំខាន់ៗនៅក្នុងស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត ............ 57
តារាងទី 7.1. បញ្ជីគំរោង CDM សក្តានុពលដែលត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ...................... 69
តារាងទី 8.1. សេចក្តីសង្ខេបនៃអត្រាពន្ធរបស់កម្ពុជា........................................................................ 76
តារាងទី 9.1. អត្រាឧបត្ថម្ភធនរបស់មូលនិធិអគ្គិសនីភាវូនីយកម្មជនបទដោយប្រើថាមពលកកើតឡើងវិញ
ដែលបានស្នើឡើង គិតជាដុល្លារអាមេរិច................................................................... 82

# អក្សរកាត់

## ពាក្យបច្ចេកទេស

| | |
|---|---|
| CDM | យន្តការអភិវឌ្ឍន៍ស្អាត |
| EIA | ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន |
| GDP | ផលទុនជាតិសរុប |
| Gg | ហ្គីហ្គាក្រាម ($10^9$ ក្រាម) |
| GNP | ផលិតផលជាតិសរុប |
| GWh | ហ្គីហ្គាវ៉ាត់-ម៉ោង |
| ha | ហិចតា |
| HDI | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស |
| IPP | អ្នកផលិតថាមពលឯករាជ្យ |
| kg | គីឡូក្រាម |
| km | គីឡូម៉ែត្រ |
| $km^2$ | គីឡូម៉ែត្រការេ |
| kWh | គីឡូវ៉ាត់-ម៉ោង |
| IFSR | ការពិនិត្យវិស័យព្រៃឈើឯករាជ្យ |
| LUCF | ការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ |
| m | ម៉ែត្រ |
| m/s | ម៉ែត្រក្នុងមួយវិនាទី |
| MW | មេហ្គាវ៉ាត់ |
| NEAP | ផែនការបរិស្ថានជាតិ |
| PV | បន្ទះចាប់ពន្លឺព្រះអាទិត្យ |
| REAP | ផែនការសកម្មភាពអគ្គិសនីកកើតឡើងវិញ |
| REE | សហគ្រាសអគ្គិសនីជនបទ |
| SEDP | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម |
| SHS | ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ |
| TRIMS | កិច្ចព្រមព្រៀងវិធានការការវិនិយោគផ្នែកពាណិជ្ជកម្ម |
| TRIPS | កម្មសិទ្ធិបញ្ញាដែលទាក់ទងនឹងពាណិជ្ជកម្ម |
| W | វ៉ាត់ |
| Wp | កំរិតខ្ពស់នៃវ៉ាត់ |

## ស្ថាប័ន និងអង្គការ

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CDRI | វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា |
| CRCD | មជ្ឈមណ្ឌលស្រាវជ្រាវកម្ពុជាដើម្បីអភិវឌ្ឍន៍ |
| CPP | គណៈបក្សប្រជាជនកម្ពុជា |
| EAC | អាជ្ញាធរអគ្គិសនីកម្ពុជា |
| EDC | អគ្គិសនីកម្ពុជា |
| FAO | អង្គការស្បៀង និងកសិកម្មពិភពលោក |
| FUNCIPEC | គណៈបក្សហ៊្វុនស៊ិនប៊ិច |
| GEF | មូលនិធិបរិស្ថានពិភពលោក |
| ICC | សភាពាណិជ្ជកម្មអន្តរជាតិ |
| IDA | សមាគមន៍អភិវឌ្ឍន៍អន្តរជាតិ |
| IPCC | ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ |
| ITC | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MOE | ក្រសួងបរិស្ថាន |
| MOF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MOP | ក្រសួងផែនការ |
| NEDO | អង្គការថាមពលថ្មី និងការអភិវឌ្ឍបច្ចេកវិទ្យាឧស្សាហកម្ម |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| REB | ក្រុមប្រឹក្សាអគ្គិសនីជនបទ |
| REF | មូលនិធិអគ្គិសនីជនបទ |
| RUA | សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| SHV | ក្រុងព្រះសីហនុ |
| UN | អង្គការសហប្រជាជាតិ |

| | |
|---|---|
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNFCCC | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| UNCTAD | សន្និសិទសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ |
| WB | ធនាគារពិភពលោក |

# សេចក្តីសង្ខេប

*សេចក្តីសង្ខេបអំពីសង្គម សេដ្ឋកិច្ច និងនយោបាយ*

ប្រទេសកម្ពុជាកំណត់យករបបប្រជាធិបតេយ្យពហុបក្សអាស្រ័យរដ្ឋធម្មនុញ្ញ ដែលរដ្ឋាភិបាលត្រូវបង្កើតឡើងដោយសំលេង ២ ភាគ ៣ នៃសភាជាតិ ។ ព្រះមហាក្សត្រគ្រងរាជ ជានិមិត្តរូបនៃឯកភាពជាតិកម្ពុជា ប៉ុន្តែមិនគ្រប់គ្រងអំណាចទេ ។ រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយនាយករដ្ឋមន្ត្រី ។

ដោយសារប្រវត្តិចំបាំងរ៉ាំរ៉ៃដែលជះឥទ្ធិពលអាក្រក់រយៈពេលយូរអង្វែង ប្រទេសកម្ពុជានៅតែជាប្រទេសមានសេដ្ឋកិច្ចពឹងផ្អែកលើវិស័យកសិកម្មជាចំបង ដែលមានតំរូវការអភិវឌ្ឍបន្ទាន់យ៉ាងច្រើន ។ វិស័យកសិកម្មនៅតែតំណាងឱ្យជាងពាក់កណ្តាលនៃផលិតផលក្នុងស្រុកសរុប ។ ក្នុងសន្ទស្សន៍អភិវឌ្ឍន៍មនុស្សប្រទេសកម្ពុជាស្ថិត នៅលំដាប់ផ្នែកខាងក្រោមនៃក្រុមប្រទេសដែលមានការអភិវឌ្ឍមធ្យម ហើយសន្ទស្សន៍អភិវឌ្ឍន៍មនុស្សរបស់សហប្រជាជាតិឆ្នាំ 2004 បានចាត់ថ្នាក់ប្រទេសកម្ពុជានៅលំដាប់ទី 130 ក្នុងចំណោមប្រទេស 177 ។ យន្តការអភិវឌ្ឍន៍ស្អាតផ្តល់នូវកាលានុវត្តភាពវិនិយោគ សំរាប់ការឈានដល់ទិសដៅអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយចីរភាព ជាពិសេសការកាត់បន្ថយភាពក្រីក្រ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ។

*សក្តានុពលគំរោងយន្តការអភិវឌ្ឍន៍ស្អាតនៅប្រទេសកម្ពុជា*

- **គំរោងថាមពល**

វិស័យថាមពលរបស់ប្រទេសកម្ពុជាកំពុងអភិវឌ្ឍន៍ក្នុងដំណើរមួយលឿន ដើម្បីដើរឱ្យទាន់នូវតំរូវការលូតលាស់របស់ប្រទេសជាតិ ។ គំរោងថាមពលប្រកបដោយចីរភាពជាច្រើនដែលអាចសមស្របសំរាប់គំរោងយន្តការអភិវឌ្ឍន៍ស្អាតមាននៅក្នុងវិស័យវារីអគ្គិសនី ជីវម៉ាស និងប្រសិទ្ធភាពថាមពល ។ សក្តានុពលថាមពលវារីអគ្គិសនី ដ៏ធំដែលនៅមិនទាន់ធ្វើអាជីវកម្មរបស់ប្រទេសកម្ពុជា ត្រូវបានប៉ាន់ស្មានថាមានរហូតដល់ 10.000 មេហ្គាវ៉ាត់ ។

ពិតមែនតែសំណល់កសិកម្មរបស់ប្រទេសកម្ពុជាត្រូវបានប្រើប្រាស់ជាប្រចាំ សំរាប់ឥន្ទនៈចំអិនអាហារនៅតាមលំនៅដ្ឋាន ការកែលំអដី ឬចំណីសត្វក្តី ក៏ការអនុវត្តបច្ចេកវិទ្យាថាមពលជីវម៉ាសទំនើបនៅមានកំរិតនៅឡើយ ។

សក្តានុពលរបស់កម្ពុជាក្នុងផ្នែកសន្សំសំចៃថាមពលនៅក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និងលំនៅដ្ឋានត្រូវបានប៉ាន់ប្រមាណថាមានប្រហែល 470 ហ្គីហ្គាវ៉ាត់-ម៉ោង ក្នុងមួយឆ្នាំ ។

**1. គំរោងវិស័យព្រៃឈើ**

ការកាប់ឈើនៅប្រទេសកម្ពុជាបានបន្សល់ទុកនូវតំបន់ព្រៃឈើស្តុក និងព្រៃដែលអាចធ្វើអាជីវកម្មពាណិជ្ជកម្មតិចតួច ។ ការកាប់ឈើបានកើនឡើងនៅដើមទសវត្សឆ្នាំទី 90 អាចនាំឱ្យមានកាលានុវត្តភាពតិចតួចសំរាប់ការអនុ-វត្តគំរោង CDM ដាំឈើឡើងវិញខ្នាតធំ ។ម្យ៉ាងវិញទៀត ខេត្តទាំងឡាយនៅតាមទំនាបកណ្តាល ដែលគ្មានព្រៃនៅមុនឆ្នាំ 1990 មានប្រជាពលរដ្ឋរស់នៅច្រើន និងជាតំបន់ផលិតកម្មកសិកម្ម ។ មិនតែប៉ុណ្ណោះ តំបន់ដែលទើបបានកាប់

ឈើថ្មីៗនៅខេត្តឆ្ងាយៗ អាចបង្ហាញនូវការលានុវត្តភាពតិចតួចសំរាប់គំរោងអាងស្តុកកាបូនយន្តការអភិវឌ្ឍន៍ស្អាត ។ សក្តានុពលខ្ពស់បំផុត សំរាប់យន្តការអភិវឌ្ឍន៍ស្អាតក្នុងគំរោងអាងស្តុកកាបូនរបស់ប្រទេសកម្ពុជា រួមមានសកម្មភាពស្តារ និងដាំឈើឡើងវិញ ដែលអនុវត្តដោយសហគមន៍ដែលមានចំណូលតិច ។ ជាប្រពៃណី ព្រៃឈើផ្តល់ដល់ប្រជាជនក្រីក្រកម្ពុជានូវផលិតផលឈើហ៊ុប និងអនុផលព្រៃឈើ ដែលជាការបំពេញបន្ថែមដ៏សំខាន់លើកសិកម្មស្រូវ និងការនេសាទ ។ គំរោងអាងស្តុកកាបូនយន្តការអភិវឌ្ឍន៍ស្អាតនៅតាមសហគមន៍មានសក្តានុពលសំរាប់ការកាត់បន្ថយភាពក្រីក្រនៅជនបទ ដោយផ្តល់នូវប្រភពចំណូលច្រើន និងផ្តល់ឱ្យប្រជាពលរដ្ឋនូវផលិតផលព្រៃឈើ ។ លើសពីនេះគំរោងអាងស្តុកកាបូនយន្តការអភិវឌ្ឍន៍ស្អាតខ្នាតតូចទាំងនេះនឹងទទួលបានប្រយោជន៍ពីការអនុវត្តវិធីសាស្រ្តងាយ ។

### *លក្ខខណ្ឌ និងដំណើរការអនុម័តគំរោងយន្តការអភិវឌ្ឍន៍ស្អាត*

ក្រសួងបរិស្ថានដើរតួរនាទីជាស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត តាមរយៈការិយាល័យប្រែប្រួលអាកាសធាតុ ។ ក្រសួងបរិស្ថានជាជនបង្គោលសំរាប់យន្តការអភិវឌ្ឍន៍ស្អាត និងពិធីសារក្យូតូ និងជាលេខាធិការដ្ឋានរបស់ប្រទេសកម្ពុជាសំរាប់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

ការិយាល័យប្រែប្រួលអាកាសធាតុទទួលបន្ទុកវាយតំលៃគំរោងយន្តការអភិវឌ្ឍន៍ស្អាតដែលបានស្នើសុំ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យការអភិវឌ្ឍប្រកបដោយចីរភាពរបស់ជាតិ និងត្រូវបានអនុញ្ញាតឱ្យផ្តល់ការអនុម័តដល់គំរោងដោយអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យទាំងនោះ ។ តារាងលក្ខណៈវិនិច្ឆ័យការអភិវឌ្ឍប្រកបដោយចីរភាពមួយត្រូវបានប្រើជាឧបករណ៍ដើម្បីវាយតំលៃគំរោង ដែលមានទិដ្ឋភាព 4 គឺ : សេដ្ឋកិច្ច សង្គម បរិស្ថាន និងការផ្ទេរបច្ចេកវិទ្យា ។ អ្នករៀបចំគំរោងត្រូវដាក់ជូនឯកសារប្លង់គំរោងទៅការិយាល័យប្រែប្រួលអាកាសធាតុ ។ ផែនការតាមដាន និងត្រួតពិនិត្យមើលត្រូវបំពេញឱ្យបាននូវរាល់ការសន្យា ដូចបានចែងក្នុងឯកសាគំរោង រួមទាំងការអភិវឌ្ឍប្រកបដោយចីរភាពផងដែរ ។

### *ច្បាប់ និងបទបញ្ញត្តិផ្សេងៗរបស់ប្រទេសកម្ពុជាដែលទាក់ទងជាមួយនឹងយន្តការអភិវឌ្ឍន៍ស្អាត*

រាល់គំរោង CDM ត្រូវប្រតិបត្តិតាមច្បាប់វិនិយោគរបស់ប្រទេសកម្ពុជា ដែលជាមូលដ្ឋានច្បាប់ និងស្ថាប័នសំរាប់ការវិនិយោគបរទេសនៅក្នុងប្រទេស ។ គំរោងយន្តការអភិវឌ្ឍន៍ស្អាតផ្នែកដាំព្រៃ និងស្តារព្រៃឡើងវិញ ត្រូវគោរពតាមច្បាប់ព្រៃឈើ ដែលមានគោលបំណងធានាឱ្យបានការគ្រប់គ្រងព្រៃឈើរបស់ប្រទេសជាតិប្រកបដោយចីរភាព ។ គំរោង CDM ផ្នែកថាមពលដែលផលិតថាមពលអគ្គិសនីត្រូវគោរពតាមច្បាប់អគ្គិសនី ដែលគ្រប់គ្រងការផលិតថាមពល ។

អាស្រ័យទៅតាមប្រភេទ និងទំហំ គំរោង CDM ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជាអាចតំរូវឱ្យធ្វើវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA)។ បញ្ជីគំរោងសក្តានុពលដែលត្រូវការវាយតំលៃហេតុប៉ះពាល់បរិស្ថានរួមមាន : (1) រោងចក្រអគ្គិសនីដែលមានសមត្ថភាពផលិត 5 មេហ្គាវ៉ាត់ ឬធំជាង (2) រោងចក្រថាមពលវារីអគ្គិសនី ដែលមាន

សមត្ថភាពផលិត 1 មេហ្គាវ៉ាត់ ឬធំជាង និង (3) ដីកសិកម្ម និងកសិ-ឧស្សាហកម្ម ដែលមានទំហំ 10.000 ហិចតា ឬលើសពីនេះ ។

### *បញ្ហាហិរញ្ញវត្ថុ និងសារពើពន្ធ*

រូបិយវត្ថុរបស់សហរដ្ឋអាមេរិចគឺជារូបិយវត្ថុប្តូរប្រាក់ចំបងមួយនៅក្នុងប្រទេសកម្ពុជា ។ ក្នុងនាមជាប្រទេសពឹងផ្អែកសេដ្ឋកិច្ចសាច់ប្រាក់ ដែលមានអន្តរកម្មធនាគារនៅមានកំរិត វិនិយោគិនបរទេសទាំងឡាយអាចស្វែងរកបាននូវសេវាហិរញ្ញវត្ថុជាច្រើនប្រភេទនៅក្នុងប្រទេសនេះ ។ ធនាគារក្នុងស្រុកចូលចិត្តបញ្ចេញកម្ចីរយៈពេលខ្លី ដែលមានអត្រាការប្រាក់ខ្ពស់ជាង ២០ ភាគរយ ។ ដូច្នេះ វិនិយោគិនបរទេសកម្រពឹងអាស្រ័យលើស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក ដើម្បីខ្ចីមូលធនមកធ្វើការវិនិយោគណាស់ ។ ពុំមានការរឹតបន្តឹងលើប្រតិបត្តិការរូបិយប័ណ្ណបរទេសឡើយ រួមទាំងការផ្ទេរប្រាក់ជាលក្ខណៈអន្តរជាតិគ្រប់ប្រភេទទាំងអស់ផង ។

### *ការលើកទឹកចិត្តរបស់រដ្ឋាភិបាល*

ប្រទេសកម្ពុជា គឺជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។ ប្រទេសនេះផ្តល់ឱ្យវិនិយោគិន ដូចជាអ្នករៀបចំគំរោង CDM ជាដើម នូវកញ្ចប់ការលើកទឹកចិត្តវិនិយោគដ៏ល្អមួយ ដូចជាការកម្រិតអាករអនុគ្រោះ និងការលើកលែងពន្ធ ការផ្ទេររូបិយប័ណ្ណបរទេសដោយមិនគិតថ្លៃ ការផ្តល់ការងារឱ្យបុគ្គលិកបរទេស និងពុំមានការគ្រប់គ្រងតម្លៃ ។ ការផ្តល់ឧបត្ថម្ភធនដល់គំរោងថាមពលកកើតឡើងវិញ នឹងមានតាមរយៈមូលនិធិអគ្គិសនីភាវូនីយកម្មជនបទ ដែលផ្តល់មូលនិធិឧត្ថម្ភដោយអ្នកផ្តល់ជំនួយ ។

# 1. សេចក្តីផ្តើម

សៀវភៅមគ្គុទ្ទេសក៏ស្តីពីយន្តការអភិវឌ្ឍន៏ស្អាតនេះរៀបរៀងឡើងសំរាប់វិនិយោគិន ឬអ្នកធ្វើគំរោង ដែលចាប់អារម្មណ៏ ឬបានត្រៀមខ្លួនក្នុងការអនុវត្តគំរោង CDM នៅក្នុងប្រទេសកម្ពុជា ។ គោលបំណងរបស់សៀវភៅនេះគឺដើម្បីផ្តល់ជូននូវសេចក្តីសង្ខេបអំពីព័តិមានចាំបាច់ទាំងឡាយ សំរាប់ការអនុវត្តគំរោងឱ្យបានជោគជ័យនៅក្នុងប្រទេសកម្ពុជា រួមទាំងឯកសារយោងផ្លូវការ និងអាស័យដ្ឋានទាក់ទងព័តិមានផងដែរ ។ សៀវភៅនេះក៏ពិពណ៌នាយ៉ាងក្បោះក្បាយផងដែរអំពីនីតិវិធី និងដំណើរការអនុម័តគំរោងរបស់ស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៏ស្អាតរបស់ប្រទេសកម្ពុជានៅក្រសួងបរិស្ថាន តាមរយៈការិយាល័យប្រែប្រួលអាកាសធាតុ ដោយរួមទាំងទិសដៅអភិវឌ្ឍន៏ដោយចិរភាពផ្លូវការរបស់ប្រទេសកម្ពុជា ។ ដោយសៀវភៅនេះមានគោលបំណងចំបងសំរាប់ប្រើប្រាស់របស់អ្នកពាក់ព័ន្ធបរទេស ដែលមិនបានស្គាល់ប្រទេសកម្ពុជា ដោយបានបង្ហាញនូវលក្ខខណ្ឌសង្គមទូទៅ និងម៉ាក្រូសេដ្ឋកិច្ច ។

នៅពេលណាដែលអាចធ្វើបាន ការបកប្រែឯកសារផ្លូវការ ក្នុងទំរង់ជាអត្ថបទចុងក្រោយ ឬសេចក្តីព្រាង ក៏បានផ្តល់ជូនដែរ ។ អ្នកអានសូមពិនិត្យឯកសារផ្លូវការឱ្យបានត្រឹមត្រូវ ដើម្បីជៀសវាងការបកស្រាយខុសនូវបរិធានច្បាប់ទាំងនោះ ។ ប្រសិនបើមានភាពមិនច្បាស់លាស់ អ្នករៀបចំគំរោងសូមទាក់ទងមកការិយាល័យប្រែប្រួលអាកាសធាតុ ដែលដើរតួរនាទីជាស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៏ស្អាត និងជាជនបង្គោលអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។ ដោយសារក្របខណ្ឌច្បាប់ នីតិវិធី សង្គម សេដ្ឋកិច្ច និងបរិស្ថានតែងមានការវិវត្តជាប្រចាំ អ្នកអានគួរកត់សំគាល់ថា សៀវភៅនេះអាចផ្តល់ជូននូវសេចក្តីផ្តើមអំពីលក្ខណៈគន្លឹះនៃទិដ្ឋភាពគំរោង CDM នៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ ។ ដោយសារការវិវត្តថ្មីៗនាំឱ្យមានការផ្លាស់ប្តូរឯកសារ និងទម្រង់បែបបទមួយចំនួន ដូច្នេះអ្នករៀបចំគំរោងគួរខិតខំរកនូវឯកសារ និងទម្រង់បែបបទផ្លូវការចុងក្រោយ ពីស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ។

កម្ពុជា ជាប្រទេសនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៏ដែលទើបងើបចេញពីសង្គ្រាមដ៏យូរអង្វែង ។ ទោះជាយ៉ាងណាក៏ដោយ ជាងមួយទសវត្សរ៏កន្លងមកនេះ ប្រទេសកម្ពុជាមានការរីកចំរើនយ៉ាងខ្លាំងក្នុងការធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ចរបស់ខ្លួន និងការលើកកំពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ ។ ជាប្រទេសហត្ថលេខីមុនគេមួយនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងពិធីសារក្យូតូ ប្រទេសកម្ពុជាបានប្តេជ្ញាចិត្តចំពោះការខិតខំជាសកល ដើម្បីប្រយុទ្ធប្រឆាំងជាមួយនឹងកំណើនកំដៅពិភពលោក ។ ដោយមានជំនួយពីសហគមន៏អន្តរជាតិ ដំណើរការអនុម័តគំរោងយន្តការអភិវឌ្ឍន៏ស្អាតត្រូវបានរៀបចំឡើងយ៉ាងរលូន និងមានតម្លាភាព ។ រាជរដ្ឋាភិបាលកម្ពុជាយល់ឃើញថា យន្តការអភិវឌ្ឍន៏ស្អាតគឺជាកាលានុវត្តភាពមួយដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ព្រមជាមួយគ្នានោះ ជួយសំរេចបានទិសដៅការអភិវឌ្ឍន៏ដោយចិរភាព និងការកាត់បន្ថយភាពក្រីក្រ ។

សៀវភៅនេះចែកចេញជា 9 ជំពូក (រួមទាំងសេចក្តីផ្តើម) ដោយភ្ជាប់ជាមួយនូវឯកសារផ្លូវការលំអិតជាច្រើន ច្បាប់នៅក្នុងសេចក្តីបន្ថែមផ្នែកខាងក្រោយ ។

2. ជំពូកទី 2 ផ្តល់ជូននូវព័ត៌មានសង្ខេបនៃប្រទេសកម្ពុជា ដែលរួមមាន ពត៌មានសំខាន់ៗអំពីសង្គម សេដ្ឋកិច្ច និងនយោបាយ ។
3. ជំពូកទី 3 បង្ហាញ និងសង្ខេបអំពីតម្រូវការ និងវដ្តគំរោងយន្តការអភិវឌ្ឍន៍ស្អាត ចាប់តាំងពីការកំណត់អត្តសញ្ញាណគំរោងដំបូង រហូតដល់ការធ្វើពាណិជ្ជកម្មឥណទានការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់ ។
4. ជំពូកទី 4 ពិភាក្សាអំពីសក្តានុពលបច្ចេកទេសសំរាប់ការអនុវត្តគំរោងយន្តការអភិវឌ្ឍន៍ស្អាតនៅប្រទេសកម្ពុជា ។
5. ជំពូកទី 5 និងទី 6 បង្ហាញអំពីព័ត៌មានស្ថាប័នជាតិទាក់ទងនឹងយន្តការអភិវឌ្ឍន៍ស្អាត ដំណើរការ និងតម្រូវការអនុម័តគំរោង ។
6. ជំពូកទី 7 បង្ហាញអំពីសេចក្តីសង្ខេបនៃការវិភាគច្បាប់វិនិយោគ ច្បាប់បរិស្ថាន និងបញ្ញត្តិផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងគំរោងយន្តការអភិវឌ្ឍន៍ស្អាតក្នុងវិស័យថាមពល និងព្រៃឈើ ។
7. ជំពូកទី 8 និងទី 9 ពិភាក្សាអំពីបញ្ហាហិរញ្ញប្បទាន និងសារពើពន្ធ ក៏ដូចជាការលើកទឹកចិត្តរបស់រដ្ឋាភិបាល ។

# 2. ព័ត៌មានអំពីសង្គម សេដ្ឋកិច្ច និងនយោបាយ

## *2.1 ព័ត៌មានអំពីប្រទេស*

ប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ចន្លោះខ្សែស្របខាងជើងទី 10 និង15 និងខ្សែបណ្តោយខាងកើតទី 105 និង 108 មានផ្ទៃក្រឡាដីគោកទំហំ 181.035 គម² ចំងាយពីខាងលិចទៅខាងកើតមានប្រហែល 580 គម និងពីខាងជើងទៅខាងត្បូងមានប្រវែង 450 គម ។ ប្រទេសកម្ពុជាមានតំបន់ឆ្នេរស្ថិតនៅទិសនិរតី ដែលមាន ប្រវែងប្រហែល 435 គម ។ ប្រទេសនេះទទួលអាកាសធាតុរបបខ្យល់មូសុង ដែលចែកចេញជាពីររដូវច្បាស់លាស់ គឺរដូវវស្សាចាប់ពីខែឧសភាដល់ខែតុលា និងរដូវប្រាំងចាប់ពីខែវិច្ឆិកាដល់ខែមេសា ។ សីតុណ្ហភាពមធ្យមប្រចាំឆ្នាំមាន 28 អង្សា ជាមួយនឹងសីតុណ្ហភាពអតិបរមាមធ្យម 38 អង្សា នៅខែមេសា និងអប្បបរមាមធ្យម 17 អង្សានៅខែមករា ។

តារាងទី 2.1 : ព័តិមានសំខាន់ៗរបស់ប្រទេស

| | | |
|---|---|---|
| ការបែងចែករដ្ឋបាល | ខេត្តចំនួន 24 ស្រុកចំនួន 183 ឃុំ-សង្កាត់ចំនួន 1.609 | |
| រាជធានី | ភ្នំពេញ | |
| ផ្ទៃដី | 181.035 គម² | |
| ចំនួនប្រជាជន | 12,8 លាននាក់ (ការប៉ាន់ស្មាននៅឆ្នាំ 2004) | |
| អត្រាកំណើនប្រជាជន | 1,81%ក្នុងមួយឆ្នាំ (ការប៉ាន់ស្មាននៅឆ្នាំ 2004) | |
| អាយុកាលមធ្យម (ឆ្នាំ) | ទាំងពីរភេទ | 56,3 |
| | ប្រុស | 54,4 |
| | ស្រី | 58,3 |
| អត្រាអ្នកចេះអក្សរ (%) | ទាំងពីរភេទ | 74,4 |
| | ប្រុស | 82,1 |
| | ស្រី | 67,4 |
| លំនៅស្ថានមានអគ្គិសនីប្រើប្រាស់(%) | សរុប | 15,1 |
| | ទីក្រុង | 53,6 |
| | ជនបទ | 8,6 |
| ប្រភពថាមពលសំរាប់ចំអិនអាហារ (%) | អុស | 90,0 |
| | ធ្យូង | 5,3 |
| | ប្រេងកាត | 1,8 |
| | ឧស្ម័ន | 1,7 |
| | ឥន្ធនៈផ្សេងៗ | 1,2 |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ 2000 និង 2004*

រូបភាព 2.1 : ផែនទីប្រទេសកម្ពុជា




## *2.2 ព័ត៌មានអំពីសង្គម*

ជំរឿនទូទាំងប្រទេសដែលបានធ្វើឡើងកាលពីឆ្នាំ 1997 បានប៉ាន់ប្រមាណថា ចំនួនប្រជាជនកម្ពុជានៅឆ្នាំ 2004 មាន 12,8 លាននាក់ (*វិទ្យាស្ថានជាតិស្ថិតិ 2000 និង 2004*) ក្នុងនោះប្រហែល 80% រស់នៅតំបន់ជនបទ ។ ចំនួនទារកដែលបានកើតយ៉ាងច្រើនបន្ទាប់ពីការដួលរលំរបបខ្មែរក្រហមបានធ្វើឱ្យមានចំនួនប្រជាពលរដ្ឋក្មេងៗច្រើនប្រមាណជា 55% នៃប្រជាពលរដ្ឋទាំងអស់ដែលមានអាយុក្រោម 20 ឆ្នាំ ។ ដោយមានអត្រាកំណើនប្រចាំឆ្នាំ 2,5% ចំនួនប្រជាជនសរុបនឹងកើនឡើងទ្វេក្នុងអំឡុងពេល 20 ឆ្នាំក្រោយនេះ ។

សន្ទស្សន៍អភិវឌ្ឍន៍មនុស្សរបស់សហប្រជាជាតិ (HDI) បានវាស់វែងនូវអត្រាអាយុមធ្យម, កំរិតអ្នកចេះអក្សរ, អ្នកចូលរៀន, និងអត្រាផលទុនជាតិសរុប ។ ប្រទេសកម្ពុជាស្ថិតនៅលំដាប់ទី 130 ក្នុងចំណោមប្រទេស 177 (UNDP 2004) ។ ទោះបីជាប្រទេសនេះស្ថិតនៅក្នុងលំដាប់ខាងក្រោមនៃក្រុមប្រទេសដែលមានការអភិវឌ្ឍមធ្យម ក៏ដោយ ក៏ប្រទេសកម្ពុជាស្ថិតនៅក្រោយគេក្នុងចំនោមប្រទេសជិតខាងរបស់ខ្លួននៅក្នុងទ្វីបអាស៊ី ដែលបានបញ្ជាក់នៅក្នុងសន្ទស្សន៍អភិវឌ្ឍន៍មនុស្សដែលបានវាស់វែង ។ ដោយមានទារកស្លាប់ 90 នាក់ ក្នុងចំណោមទារកកើត 1.000 នាក់នោះ អត្រាមរណៈរបស់កូនក្មេងមានប្រហែលជាបីដងច្រើនជាងបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ប្រទេសនេះក៏មានកំរិតអ្នកផ្ទុកមេរោគអេដ៏ខ្ពស់ជាងគេនៅក្នុងតំបន់ ពោលគឺមានប្រមាណជា 150.000 ករណី ។ អត្រាអាយុកាលរបស់ប្រជាពលរដ្ឋមាន 53 ឆ្នាំ ប្រៀបធៀបជាមួយអាយុកាលមធ្យម 69 ឆ្នាំនៅក្នុងបណ្តាប្រទេសអាស៊ីប៉ាស៊ីភិចភាគអាគ្នេយ៍ ។ នៅពេលសន្ទស្សន៍អភិវឌ្ឍន៍មនុស្សមានសមាមាត្រជាមួយប្រាក់ចំណូលក្នុងមនុស្សម្នាក់ ប្រទេសកម្ពុជាមានសន្ទស្សន៍អភិវឌ្ឍន៍មនុស្សអន់ជាងភោគទ្រព្យសេដ្ឋកិច្ចរបស់ខ្លួន (MOP 1999) ។ កត្តានេះឆ្លុះបញ្ចាំងជាទូទៅថា មានការអភិវឌ្ឍទាបក្នុងភាពស្មើគ្នានៃយេនឌ័រ និងភាពខ្វះខាតធនធានមនុស្ស ។ លើសពីនេះទៅទៀត មានការអភិវឌ្ឍខុសគ្នាច្រើនរវាងប្រជាជនរស់នៅក្នុងទីក្រុង និងនៅតាមតំបន់ជនបទ ។

## *2.3 ព័ត៌មានអំពីសេដ្ឋកិច្ច*

ប្រទេសកម្ពុជាមានផលទុនជាតិសរុប (GDP) ចំនួន 278 ដុល្លារ ក្នុងមនុស្សម្នាក់ ។ វិស័យកសិកម្មតំណាងឱ្យជាងពាក់កណ្តាលនៃ GDP (តារាងទី 2) ឯវិស័យឧស្សាហកម្មភាគច្រើនជាឧស្សាហកម្មកាត់ដេរនាំចេញទៅសហរដ្ឋអាមេរិច ហើយបានរួមចំណែកបាន 15 ភាគរយ (World Bank 1999) ។ កំណើនយ៉ាងខ្លាំងនៃវិស័យកាត់ដេរបានធ្វើឱ្យមានការចាប់អារម្មណ៍ជាខ្លាំង ដោយសារតែពីមុនប្រទេសនេះទទួលនូវការខូចខាតយ៉ាងធ្ងន់ធ្ងរពីសង្គ្រាម ។ បើប្រៀបធៀបជាមួយឆ្នាំ 1995 ការនាំចេញសំលៀកបំពាក់មានតែប្រហែល 20 លានដុល្លារ ហើយនៅឆ្នាំ 2002 ការនាំចេញនេះបានកើនលើស 1,4 ពាន់លានដុល្លារ (World Bank 2004) ។ ការងារក្នុងវិស័យកសិកម្ម និងសេវាកម្ម បានកើនឡើង 2% ជារៀងរាល់ឆ្នាំ ក្នុងចន្លោះឆ្នាំ 1998 និង 2000 ដោយឡែកការងារក្នុងវិស័យឧស្សាហកម្មកើនដល់ 43% ក្នុងមួយឆ្នាំ ។ ផលិតផលសំលៀកបំពាក់កើនក្នុងមួយឆ្នាំបាន 64% រវាងឆ្នាំ 1996 និងឆ្នាំ 2000 (តារាងទី 3) ។ ការវិនិយោគផ្ទាល់ពីបរទេស មានចំនួនពាក់កណ្តាលនៃទុនអចល័ត នៅក្នុងឧស្សាហកម្មសំលៀកបំពាក់ឆ្នាំ 1998 ។ ការវិនិយោគផ្ទាល់ពីបរទេសបានឡើងខ្ពស់បំផុតនៅឆ្នាំ 1998/1999 ក្នុងចំនួនច្រើនជាង 200 លានដុល្លារ (តារាងទី 4) ។ ប្រទេសកម្ពុជាបានទទួលអត្ថប្រយោជន៍ពីប្រព័ន្ធអនុគ្រោះសំរាប់ការនាំចេញសំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិច និងសហគមន៍អឺរ៉ុប ដែលបានទាក់ទាញវិនិយោគិនក្នុងឧស្សាហកម្មកាត់ដេរ ។ ក៏ប៉ុន្តែ អ្វីដែលហៅថាកូតាសំលៀកបំពាក់ទៅកាន់ទីផ្សារសហរដ្ឋអាមេរិច ដែលចងភ្ជាប់ជាមួយការទទួលបានការនាំចេញដោយគ្មានពន្ធ នៅក្នុងការផ្លាស់ប្តូរជាមួយការធ្វើអធិការកិច្ចរបស់អង្គការពលកម្មអន្តរជាតិ បានផុតកំណត់នៅខែមករា ឆ្នាំ 2005 ។

លើសពីនេះ តំបន់មរតកពិភពលោកប្រាសាទអង្គរវត្តរបស់ប្រទេសកម្ពុជា កំពុងក្លាយជាប្រភពដ៏សំខាន់នៃរូបិយប័ណ្ណអន្តរជាតិ តាមរយៈទេសចរណ៍ ។ ដូច្នេះ កំណើនសេដ្ឋកិច្ចពឹងផ្អែកជាចំបងទៅលើវិស័យកាត់ដេរ និងទេសចរណ៍ ។ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ 1991 អត្រាតំលៃប្តូរប្រាក់ និងពាណិជ្ជកម្មត្រូវបានធ្វើដោយសេរី ។ ប្រាក់រៀល ដែលជារូបិយវត្ថុជាតិ នៅតែមានតុល្យភាពជាមួយប្រាក់ដុល្លាររបស់សហរដ្ឋអាមេរិច ដែលជាលទ្ធផលនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ប្រុងប្រយ័ត្នមួយ ( តារាងទី 6) ។

តារាងទី 2.2. តំលៃផលទុនជាតិសរុបរបស់ប្រទេសកម្ពុជា តាមសកម្មភាពសេដ្ឋកិច្ច គិតជាលានរៀល ក្នុងតំលៃបច្ចុប្បន្ន*

| ឆ្នាំ | 1993[a] | 1994[a] | 1995[a] | 1996[a] | 1997[a] | 1998[a] | 1999[a] | 2000[a] | 2001[b] | 2002[b] |
|---|---|---|---|---|---|---|---|---|---|---|
| ***កសិកម្ម, នេសាទ, និងព្រៃឈើ*** | **3,070,700** | **3,231,433** | **4,017,120** | **4,068,004** | **4,474,740** | **5,248,438** | **5,559,994** | **5,191,310** | **5,161,677** | **5,231,799** |
| ដំណាំ | 1,168,838 | 1,312,953 | 1,994,369 | 1,941,289 | 2,052,219 | 2,456,504 | 2,585,033 | 2,429,393 | 2,384,925 | 2,250,420 |
| សត្វពាហនៈ និង បសុបក្សី | 483,635 | 443,483 | 488,575 | 551,359 | 560,697 | 676,506 | 823,816 | 736,829 | 798,866 | 839,972 |
| នេសាទ | 1,133,212 | 953,216 | 1,034,432 | 1,175,590 | 1,229,092 | 1,492,028 | 1,609,571 | 1,560,819 | 1,563,807 | 1,801,255 |
| ព្រៃឈើ | 285,015 | 521,781 | 499,744 | 399,767 | 632,732 | 623,400 | 541,575 | 464,269 | 414,079 | 340,152 |
| ***ឧស្សាហកម្ម*** | **834,985** | **969,997** | **1,193,283** | **1,355,800** | **1,629,169** | **1,995,916** | **2,371,574** | **3,047,161** | **3,519,843** | **4,114,939** |
| អាជីវកម្មរ៉ែ | 13,089 | 15,951 | 19,406 | 19,548 | 20,531 | 19,342 | 26,629 | 33,544 | 39,645 | 46,614 |
| កម្មន្តសាល | 560,480 | 624,034 | 758,212 | 909,340 | 1,156,069 | 1,534,039 | 1,736,919 | 2,238,690 | 2,556,362 | 2,969,456 |
| ចំណីអាហារ, ថ្នាំជក់ និងភេសជ្ជៈ | 279,689 | 264,666 | 336,635 | 347,466 | 364,011 | 432,933 | 467,188 | 433,380 | 442,485 | 450,306 |
| វាយនភ័ណ្ឌ, សំលៀកបំពាក់ និងស្បែកជើង | 70,874 | 80,089 | 123,225 | 197,820 | 378,386 | 587,330 | 791,951 | 1,295,770 | 1,622,143 | 1,958,651 |
| គ្រឿងឈើ, ក្រដាស និង ការបោះពុម្ព | 58,255 | 115,400 | 104,739 | 132,562 | 156,053 | 228,243 | 128,780 | 109,883 | 82,909 | 101,379 |
| ផលិតផលជ័រកៅស៊ូ | 23,540 | 22,256 | 31,357 | 42,366 | 48,767 | 46,359 | 55,744 | 69,165 | 61,706 | 73,707 |

| ឆ្នាំ | 1993[a] | 1994[a] | 1995[a] | 1996[a] | 1997[a] | 1998[a] | 1999[a] | 2000[a] | 2001[b] | 2002[b] |
|---|---|---|---|---|---|---|---|---|---|---|
| ផលិតកម្មផ្សេងៗ | 128,122 | 141,622 | 162,256 | 189,125 | 208,852 | 239,174 | 293,255 | 330,493 | 347,120 | 385,413 |
| អគ្គិសនី, ឧស្ម័ន និងទឹក | 24,085 | 30,834 | 39,501 | 40,111 | 40,655 | 46,539 | 43,478 | 43,331 | 56,750 | 75,786 |
| សំណង់ | 237,331 | 299,178 | 376,164 | 386,802 | 411,914 | 395,996 | 564,547 | 731,596 | 867,086 | 1,023,083 |
| ***សេវាកម្ម*** | **2,580,382** | **2,467,038** | **2,761,061** | **3,180,179** | **3,409,622** | **3,895,383** | **4,448,412** | **4,855,582** | **5,059,726** | **5,358,302** |
| ពាណិជ្ជកម្ម | 966,170 | 891,647 | 968,470 | 1,103,962 | 1,186,986 | 1,312,805 | 1,419,253 | 1,432,380 | 1,446,004 | 1,483,513 |
| សណ្ឋាគារ និង ភោជនីយដ្ឋាន | 154,757 | 193,942 | 238,695 | 249,707 | 283,211 | 320,332 | 395,579 | 472,646 | 575,275 | 656,645 |
| ការដឹកជញ្ជូន និង ទូរគមនាគមន៍ | 376,247 | 400,190 | 449,002 | 532,916 | 569,935 | 637,975 | 778,927 | 877,650 | 947,193 | 959,963 |
| ហិរញ្ញវត្ថុ | 23,770 | 27,385 | 76,526 | 86,541 | 97,806 | 100,334 | 129,390 | 174,845 | 128,370 | 84,720 |
| រដ្ឋបាលសាធារណៈ | 142,162 | 228,500 | 233,700 | 296,156 | 305,041 | 333,214 | 388,637 | 376,603 | 359,180 | 390,477 |
| អចលនវត្ថុ និង ជំនួញ | 622,245 | 451,532 | 483,374 | 537,250 | 600,696 | 732,404 | 763,622 | 826,020 | 852,464 | 880,115 |
| សេវាកម្មផ្សេងៗ | 295,032 | 273,841 | 311,294 | 373,647 | 365,948 | 458,319 | 573,005 | 695,438 | 751,240 | 902,870 |
| ***ពន្ធលើផលិតផល និង ប្រាក់បំរុង*** | **194,500** | **334,374** | **395,285** | **483,470** | **536,920** | **594,100** | **865,301** | **870,232** | **920,702** | **1,040,437** |
| ប្រាក់បំរុង | 2,300 | 4,466 | 11,915 | 15,030 | 6,300 | 14,200 | 11,900 | 31,182 | 31,744 | 51,000 |
| តំលៃសេវាកម្ម ហិរញ្ញវត្ថុ | 14,945 | 17,217 | 72,964 | 63,192 | 123,063 | 124,475 | 114,305 | 154,780 | 118,059 | 78,280 |
| កំណើនផលិតផលក្នុងស្រុក | **6,665,622** | **6,985,624** | **8,293,785** | **9,024,262** | **9,927,388** | **11,609,362** | **13,130,976** | **13,809,506** | **14,543,889** | **15,667,197** |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ 2004

- សូមអានតារាងទី 6 សំរាប់អត្រាប្តូរប្រាក់រៀល ជាមួយប្រាក់ដុល្លារអាមេរិច

[a] ការប៉ាន់ស្មានឡើងវិញ

[b] ការប៉ាន់ស្មានដំបូង

តារាងទី 2.3 អត្រាកំណើនផលទុនជាតិសរុបរបស់កម្ពុជាតាមសកម្មភាពសេដ្ឋកិច្ច ក្នុងតំលៃបច្ចុប្បន្ន

| ឆ្នាំ | 1993/94[a] | 1994/95[a] | 1995/96[a] | 1996/97[a] | 1997/98[a] | 1998/99[a] | 1999/00[a] | 2000/01[b] | 2001/02[b] |
|---|---|---|---|---|---|---|---|---|---|
| ***កសិកម្ម, នេសាទ, និងព្រៃឈើ*** | **5.2%** | **24.3%** | **1.3%** | **10.0%** | **17.3%** | **5.9%** | **–6.6%** | **–0.6%** | **1.4%** |
| ដំណាំ | 12.3% | 51.9% | –2.7% | 5.7% | 19.7% | 5.2% | –6.0% | –1.8% | –5.6% |
| សត្វពាហនៈ និងបសុបក្សី | –8.3% | 10.2% | 12.9% | 1.7% | 20.7% | 21.8% | –10.6% | 8.4% | 5.1% |
| នេសាទ | –15.9% | 8.5% | 13.6% | 4.6% | 21.4% | 7.9% | –3.0% | 0.2% | 15.2% |
| ព្រៃឈើ | 83.1% | –4.2% | –20.0% | 58.3% | –1.5% | –13.1% | –14.3% | –10.8% | –17.9% |
| ***ឧស្សាហកម្ម*** | **16.2%** | **23.0%** | **13.6%** | **20.2%** | **22.5%** | **18.8%** | **28.5%** | **15.5%** | **16.9%** |
| អាជីវកម្មរ៉ែ | 21.9% | 21.7% | 0.7% | 5.0% | –5.8% | 37.7% | 26.0% | 18.2% | 17.6% |
| កម្មន្តសាល | 11.3% | 21.5% | 19.9% | 27.1% | 32.7% | 13.2% | 28.9% | 14.2% | 16.2% |
| ចំណីអាហារ, ថ្នាំជក់, និងភេសជ្ជៈ | –5.4% | 27.2% | 3.2% | 4.8% | 18.9% | 7.9% | –7.2% | 2.1% | 1.8% |
| វាយនភ័ណ្ឌ, សំលៀកបំពាក់ និង ស្បែកជើង | 13.0% | 53.9% | 60.5% | 91.3% | 55.2% | 34.8% | 63.6% | 25.2% | 20.7% |
| គ្រឿងឈើ, ក្រដាស និង ការបោះពុម្ព | 98.1% | –9.2% | 26.6% | 17.7% | 46.3% | –43.6% | –14.7% | –24.5% | 22.3% |
| ផលិតផលជ័រកៅស៊ូ | –5.5% | 40.9% | 35.1% | 15.1% | –4.9% | 20.2% | 24.1% | –10.8% | 19.4% |
| ផលិតកម្មផ្សេងៗ | 10.5% | 14.6% | 16.6% | 10.4% | 14.5% | 22.6% | 12.7% | 5.0% | 11.0% |
| អគ្គិសនី, ឧស្ម័ន និងទឹក | 28.0% | 28.1% | 1.5% | 1.4% | 14.5% | –6.6% | –0.3% | 31.0% | 33.5% |
| សំណង់ | 26.1% | 25.7% | 2.8% | 6.5% | –3.9% | 42.6% | 29.6% | 18.5% | 18.0% |
| ***សេវាកម្ម*** | **–4.4%** | **11.9%** | **15.2%** | **7.2%** | **14.2%** | **14.2%** | **9.2%** | **4.2%** | **5.9%** |
| ពាណិជ្ជកម្ម | –7.7% | 8.6% | 14.0% | 7.5% | 10.6% | 8.1% | 0.9% | 1.0% | 2.6% |
| សណ្ឋាគារ និង ភោជនីដ្ឋាន | 25.3% | 23.1% | 4.6% | 13.4% | 13.1% | 23.5% | 19.5% | 21.7% | 14.1% |
| ការដឹកជញ្ជូន និង ទូរគមនាគមន៍ | 6.4% | 12.2% | 18.7% | 6.9% | 11.9% | 22.1% | 12.7% | 7.9% | 1.3% |
| ហិរញ្ញវត្ថុ | 15.2% | 179.4% | 13.1% | 13.0% | 2.6% | 29.0% | 35.1% | –26.6% | –34.0% |
| រដ្ឋបាលសាធារណៈ | 60.7% | 2.3% | 26.7% | 3.0% | 9.2% | 16.6% | –3.1% | –4.6% | 8.7% |

| ឆ្នាំ | 1993/94[a] | 1994/95[a] | 1995/96[a] | 1996/97[a] | 1997/98[a] | 1998/99[a] | 1999/00[a] | 2000/01[b] | 2001/02[b] |
|---|---|---|---|---|---|---|---|---|---|
| អចលនវត្ថុ និងជំនួញ | –27.4% | 7.1% | 11.1% | 11.8% | 21.9% | 4.3% | 8.2% | 3.2% | 3.2% |
| សេវាកម្មផ្សេងៗ | –7.2% | 13.7% | 20.0% | –2.1% | 25.2% | 25.0% | 21.4% | 8.0% | 20.2% |
| ***ពន្ធលើផលិតផល និងប្រាក់បំរុង*** | **71.9%** | **18.2%** | **22.3%** | **11.1%** | **10.6%** | **45.6%** | **0.6%** | **5.8%** | **13.0%** |
| ប្រាក់បំរុង | 94.2% | 166.8% | 26.1% | –58.1% | 125.4% | –16.2% | 162.0% | 1.8% | 60.7% |
| តំលៃសេវាកម្មហិរញ្ញវត្ថុ | 15.2% | 323.8% | –13.4% | 94.7% | 1.1% | –8.2% | 35.4% | –23.7% | –33.7% |
| កំណើនផលិតផលក្នុងស្រុក | **4.8%** | **18.7%** | **8.8%** | **10.0%** | **16.9%** | **13.1%** | **5.2%** | **5.3%** | **7.7%** |

*ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ 2004*

[a] ការប៉ាន់ស្មានឡើងវិញ

[b] ការប៉ាន់ស្មានដំបូង

### តារាងទី 2.4. ជំនួយផ្លូវការពីបរទេសដល់ប្រទេសកម្ពុជា គិតជាពាន់លានរៀល

| ឆ្នាំ | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 |
|---|---|---|---|---|---|---|---|---|
| ហិរញ្ញប្បទានខាងក្រៅសរុប | 559.3 | 674.2 | 445.9 | 505.4 | 515.4 | 707.5 | 889.4 | 1,060.5 |
| ជំនួយជាថវិកា | 108.6 | 149.9 | 96.0 | 1.5 | 4.4 | 113.2 | 54.3 | 178.2 |
| ជំនួយជាគំរោង | 450.7 | 565.8 | 350.8 | 503.9 | 511.0 | 594.4 | 839.4 | 890.2 |

*ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ 2004*

### តារាងទី 2.5. សន្ទស្សន៍តំលៃអ្នកប្រើប្រាស់នៅទីក្រុងរបស់ប្រទេសកម្ពុជា

| ឆ្នាំ | 2001 | 2002 | 2003 |
|---|---|---|---|
| សន្ទស្សន៍តំលៃអ្នកប្រើប្រាស់នៅទីក្រុងរបស់ប្រទេសកម្ពុជា | 102.36 | 104.80 | 106.25 |

*ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ 2004*

### តារាងទី 2.6. អត្រាប្តូរប្រាក់រៀល ជាមួយប្រាក់ដុល្លារអាមេរិច

| ឆ្នាំ | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 |
|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលក្នុងមួយដុល្លារ | 2,666 | 3,029 | 3,824 | 3,832 | 3,879 | 3,935 | 3,948 | 3,999 |

*ប្រភព:* CDRI 2004

ប្រទេសកម្ពុជាក្លាយជាសមាជិករបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) តាំងពីឆ្នាំ 1999 មកម្ល៉េះ ហើយប្រការនេះបានផ្តល់ផលវិជ្ជមានដល់ការធ្វើសមាហរណកម្មប្រទេសចូលទៅក្នុងសេដ្ឋកិច្ចតំបន់ ។ ប្រទេសនេះក៏ជាប្រទេសទីមួយ ក្នុងចំណោមប្រទេសមានការអភិវឌ្ឍតិចតួចជាងគេ ដែលបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។ ការចូលជាសមាជិក WTO ត្រូវបានអនុម័តយល់ព្រមដោយរដ្ឋសភាជាតិ ដែលត្រួសត្រាយផ្លូវសំរាប់ការធ្វើសមាហរណកម្មបន្ថែមចូលទៅក្នុងសេដ្ឋកិច្ចពិភពលោក ។ រាជរដ្ឋាភិបាលកម្ពុជាមើលឃើញការចូលជាសមាជិក WTO ថាជាមធ្យោបាយមួយ ដើម្បីពង្រីកទីផ្សារនាំចេញ ក្នុងគោលដៅពង្រឹងការអភិវឌ្ឍឧស្សាហកម្មក្នុងស្រុកបន្ថែមទៀត ព្រោះទីផ្សារក្នុងស្រុកមានទំហំតូចពេក សំរាប់ធានានិរន្តរភាពនៃតំរូវការផលិតផលដែលផលិតក្នុងស្រុក ។ សមាជិកភាព WTO តំរូវឱ្យប្រទេសកម្ពុជាអនុម័ត និងអនុវត្តក្របខ័ណ្ឌច្បាប់និងពាណិជ្ជកម្មទំនើបមួយ ស្របទៅតាមលក្ខខណ្ឌពាណិជ្ជកម្មអន្តរជាតិ (ធនាគារពិភពលោក ឆ្នាំ 2004) ។ លក្ខខណទាំងនោះរួមមានកំណែទំរង់ដូចតទៅ : ការបង្កើតតុលាការពាណិជ្ជកម្ម កំណែទំរង់ការផ្តល់អាជ្ញាប័ណ្ណនាំចេញ កំណែទំរង់ពន្ធគយ ការអនុវត្តកិច្ចព្រមព្រៀងវិធានការ ការវិនិយោគផ្នែកពាណិជ្ជកម្ម (TRIMS) ការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាដែលទាក់ទងនឹងពាណិជ្ជកម្ម (TRIPS) ការអនុវត្តកិច្ចព្រមព្រៀងការវាយតំលៃពន្ធគយរបស់ WTO និងការប្តេជ្ញាចិត្តផ្សព្វផ្សាយគ្រប់ច្បាប់ទាំងអស់ដែលពាក់ព័ន្ធនឹង WTO តាមវិបសាយ ។ ដោយសារតែវិសាលភាពធំធេងនៃកំណែទំរង់ចាំបាច់ ធនាគារពិភពលោកបានសន្និដ្ឋានថា ប្រទេសកម្ពុជា "បានជ្រើសរើសជំរើសមិនការពារ ប៉ុន្តែប្រកួតប្រជែង" ។ ម្យ៉ាងវិញទៀត ការចូលជាសមាជិក WTO នឹងអនុញ្ញាតឱ្យព្រះរាជាណាចក្រកម្ពុជា ឈានជើងចូលទៅក្នុងទីផ្សាររបស់ប្រទេសសមាជិកដទៃទៀត តាមដែលខ្លួនចូលចិត្តជាងគេ ប៉ុន្តែនិយាយមួយបែបទៀត សមាជិកភាពនេះនឹងរឹតតែធ្វើឱ្យការប្រកួតប្រជែងពីអ្នកផលិតបរទេស ទាំងក្នុងស្រុក ទាំងលើសកលលោក កាន់តែមានសភាពខ្លាំងឡើងៗ ។

បញ្ហាប្រឈមសំរាប់ប្រទេសកម្ពុជានាពេលអនាគតដ៏ខ្លី គឺត្រូវធ្វើសេរីភាវូបកម្មសេដ្ឋកិច្ចរបស់ខ្លួនបន្ថែម និងធ្វើសមាហរណកម្មដោយរលូនចូលទៅក្នុងសេដ្ឋកិច្ចពិភពលោក តាមរយៈការអនុម័ត និងការអនុវត្តច្បាប់នានា ដែលផ្តល់លក្ខខណ្ឌអនុគ្រោះដល់សហគ្រាសឯកជន និងពង្រឹងនីតិរដ្ឋឱ្យបានរឹងប៉ឹង ។

ទាំងប្រទេសផ្តល់ជំនួយ ទាំងរដ្ឋាភិបាល បានរកឃើញបញ្ហាជាច្រើន ដែលធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ច ដូចជាកំលាំងពលកម្មដែលមានជំនាញតិចតួច ហេដ្ឋារចនាសម្ព័ន្ធសាធារណៈអន់ខ្សោយ ការិយាធិបតេយ្យរដ្ឋបាលលើសលុប (រាជរដ្ឋាភិបាលកម្ពុជា 2001 ធនាគារអភិវឌ្ឍន៍អាស៊ី 2000b ធនាគារពិភពលោក 2000) ។ ការស្រាវជ្រាវមួយលើសហគ្រាសឯកជនជាង 500 ក្នុងទីក្រុងចំនួន 5 ដែលធ្វើឡើងដោយធនាគារពិភពលោក បានរកឃើញបន្ថែមនូវបញ្ហាចំបងមួយចំនួន ដែលធ្វើឱ្យរាំងស្ទះដល់ប្រតិបត្តិការ និងកំណើនសហគ្រាសឯកជន ដូចជាការចំណាយលើការិយាធិបតេយ្យ និងនីតិរដ្ឋនៅខ្សោយ ។ ដោយទទួលស្គាល់បញ្ហាទាំងនេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្រុមការងារអន្តរក្រសួងពិសេសទទួលបន្ទុកការសម្របសម្រួលពាណិជ្ជកម្ម និងបរិស្ថានវិនិយោគ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ 2004 ធនាគារពិភពលោក ឆ្នាំ 2004) ។ ផែនការ 12 ចំនុច បង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើការកែលំអបរិស្ថានវិនិយោគ ឱ្យបានឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា និងសម្របសម្រួល

ពាណិជ្ជកម្ម ឱ្យស្របជាមួយនឹងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់ខ្លួន (ប្រអប់ទី 1) ។ ជាពិសេស លក្ខខណ្ឌសំរាប់ការផ្តល់អាជ្ញាប័ណ្ណ ការបង្កើតក្រុមហ៊ុន និងការចុះបញ្ជីការពាណិជ្ជកម្ម នឹងត្រូវបានកាត់បន្ថយ និងកែសម្រួលឡើងវិញ ។ ថ្លៃសេវាដូចគ្នា ដែលស្របទៅនឹងគោលការណ៍ WTO នឹងអនុញ្ញាតឱ្យក្រុមហ៊ុនឯកជន ចំណាយតែម្តងសំរាប់ការជំរះពន្ធគយទាំងអស់ ។

ប្រអប់ទី ២.១ ផែនការ 12 ចំណុចរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកែលំអបរិស្ថានវិនិយោគ

1. បង្កើតក្រុមការងារអន្តរស្ថាប័នទទួលបន្ទុកកំណែទំរង់ការសម្របសម្រួលពាណិជ្ជកម្ម/បរិស្ថានវិនិយោគ ។
2. បង្កើតប្រព័ន្ធវាស់វែងការបំពេញការងារដែលមានតម្លាភាព រួមទាំងការពិនិត្យឃ្លាំមើលវិស័យឯកជន ។
3. ដំណើរការសម្របសម្រួលពាណិជ្ជកម្ម ដូចជា អាជ្ញាប័ណ្ណ នីតិវិធី និងឯកសារទាំងអស់ នឹងត្រូវពិនិត្យកែសម្រួលឡើងវិញ ដើម្បីលុបចោលការត្រួតគ្នា និងលក្ខខណ្ឌអនុម័តណាដែលមិនចាំបាច់ចេញ ។ បន្ទាប់ពីមានការរៀបចំឡើងវិញ ឯកសាររដ្ឋបាលតែមួយគត់នឹងត្រូវបានប្រើប្រាស់ ហើយឯកសារដទៃទៀតនឹងត្រូវលុបបំបាត់ចោលបន្តិចម្តងៗ ។
4. ដាក់ឱ្យប្រើប្រាស់នូវយុទ្ធសាស្រ្តគ្រប់គ្រងហានិភ័យរួម ដើម្បីដាក់បញ្ចូលគ្នា និងកាត់បន្ថយគ្រប់លក្ខខណ្ឌត្រួតពិនិត្យទាំងអស់ នៃអង្គភាពត្រួតពិនិត្យផ្សេងៗគ្នា ។
5. ចាប់ផ្តើមពិនិត្យជាយុទ្ធសាស្រ្តឡើងវិញ លើតួនាទីរបស់កាំកុងត្រូល (នាយកដ្ឋានត្រួតពិនិត្យការនាំចេញនាំចូល និងបង្ក្រាបការក្លែងបន្លំ) ដើម្បីប្រើប្រាស់ចំណេះដឹងពិសេសក្នុងការត្រួតពិនិត្យគុណភាពរបស់អង្គភាពនេះ ឱ្យកាន់តែមានផលិតភាពមួយកំរិតទៀត និងប្រើប្រាស់ឱ្យបានជាអតិបរមានូវចំណេះដឹង និងធនធានរបស់អង្គភាពផ្សេងទៀត ដូចជា ទីចាត់ការគយ និងរដ្ឋាករ ជាដើម ។
6. ច្រកចេញចូលតែមួយ (Single-window) ដើម្បីគ្រប់គ្រងការធ្វើពាណិជ្ជកម្ម នឹងត្រូវបានសាកល្បង នៅកំពង់ផែក្រុងព្រះសីហនុ មុនខែធ្នូ ឆ្នាំ 2005 ។ បន្ទាប់ពីការកែសម្រួលឡើងវិញរួចហើយ ដំណើរការសម្របសម្រួលពាណិជ្ជកម្មនឹងដាក់ឱ្យប្រើប្រាស់នៅមុនខែធ្នូ ឆ្នាំ 2005 ។
7. រដ្ឋាភិបាលនឹងដាក់ឱ្យប្រើប្រាស់នូវថ្លៃសេវាកម្មដូចៗគ្នាតាមស្តង់ដា WTO ហើយសេវាកម្មនេះនឹងត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងកំរិតសេវាកម្មមួយ ។ រចនាសម្ព័ន្ធថ្លៃឈ្នួលសេវាកម្មនឹងមានលក្ខណៈជាសាធារណៈ ។
8. កែលំអប្រសិទ្ធភាពដំណើរការ និងកាត់បន្ថយថ្លៃចុះបញ្ជីពាណិជ្ជកម្ម ដែលរក្សាទុកនៅការិយាល័យលេខាធិការតុលាការពាណិជ្ជកម្ម ឱ្យនៅត្រឹម 630 ដុល្លារសហរដ្ឋអាមេរិក និងត្រូវការរយៈពេល ៣០ ថ្ងៃ ។
9. កែលំអដំណើរការជូនដំណឹងរបស់ក្រសួងការងារ ដើម្បីចាប់ផ្តើមជួលនិយោជិកឱ្យធ្វើការ ដែលត្រូវការចំណាយ 250 ដុល្លារសហរដ្ឋអាមេរិក នឹងត្រូវការពេល 30 ថ្ងៃ ដើម្បីបញ្ចប់ ។
10. សំរួលការចុះបញ្ជីពន្ធលើតំលៃបន្ថែម (VAT) ពន្ធចំណូល និងការចុះបញ្ជីការក្រុមហ៊ុន ដោយប្រើពាក្យសុំ

តែមួយ និងបង្កើតលេខសំគាល់ដូចគ្នា ។ ប្រការនេះនឹងបង្កើតឱ្យមានការសំគាល់អត្តសញ្ញាណតែមួយ និងអាចសម្របសម្រួលការចែករំលែកព័ត៌មាន រវាងអង្គភាពនានា ។

11. អនុវត្តការផ្តល់រង្វាន់ជាតិ ដើម្បីលើកកំពស់ភាពជាពលរដ្ឋជាសមូហភាព និងអភិបាលកិច្ចល្អនៅក្នុងវិស័យឯកជន។
12. ពិនិត្យឃ្លាំមើល និងធ្វើរបាយការណ៍ ។

## *2.3 ព័ត៌មានអំពីនយោបាយ*

បន្ទាប់ពីស្ថិតនៅក្រោមអាណាព្យាបាលរបស់ប្រទេសបារាំង អស់រយៈពេលជិតមួយសតវត្សរ៍រួចមក ប្រទេសកម្ពុជាបានទទួលឯករាជ្យនៅក្នុងឆ្នាំ 1953 ។ ចាប់ពីឆ្នាំ 1953 ដល់ 1970 ព្រះរាជាណាចក្រកម្ពុជាស្ថិតនៅក្រោមការដឹកនាំរបស់ព្រះអង្គម្ចាស់ នរោត្តម សីហនុ ដែលក្រោយមកបានគ្រងរាជ្យក្លាយជាព្រះមហាក្សត្រ ។ សម័យកាលនេះដែលគេតែងហៅថា "សង្គមរាស្ត្រនិយម" ជារឿយៗ ត្រូវបានចងចាំក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា ថាជារយៈពេលដែលមានវិបុលភាពផ្នែកសេដ្ឋកិច្ច និងសន្តិសុខ នៅពេលដែលហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសំខាន់ៗ មានដូចជា កំពង់ផែ អាកាសយានដ្ឋាន បណ្តាញផ្លូវទូទាំងប្រទេស កីឡាដ្ឋាន ផ្លូវរថភ្លើង និងរោងចក្រថាមពល ត្រូវបានសាងសង់ឡើងយ៉ាងគគ្រឹកគគ្រេង ។ ជាអកុសល ហេដ្ឋារចនាសម្ព័ន្ធទាំងនេះភាគច្រើន ត្រូវបានបំផ្លាញចោលអស់នៅក្នុងពេលមានសង្គ្រាម ឬលែងយកមកប្រើបានតទៅទៀត ។

ខែមេសា 1975 រាជធានីភ្នំពេញ បានធ្លាក់ទៅក្នុងកណ្តាប់ដៃខ្មែរក្រហម បន្ទាប់ពីសង្គ្រាមស៊ីវិលអស់រយៈពេល 5 ឆ្នាំ ។ ក្នុងពេលជាមួយគ្នានោះដែរ កងទ័ពសហរដ្ឋអាមេរិចបានដកចេញពីទីក្រុងសៃហ្គន ។ នៅក្រោមការដឹកនាំរបស់ ប៉ុល ពត ប្រទេសកម្ពុជាបានប្រែក្លាយទៅជាជំរំពលកម្មដ៏ធំមួយ ។ សម័យកាលនោះមានឈ្មោះថា កម្ពុជាប្រជាធិបតេយ្យ ចាប់ពីឆ្នាំ 1975 ដល់ 1979 ដែលក្នុងរយៈពេលនោះ ខ្មែរក្រហមបានសំលាប់រង្គាលប្រជាពលរដ្ឋខ្មែរប្រហែលជា 1 លាន 5 សែននាក់ (Kiernan 1998) ។ ទីក្រុងទាំងអស់នៅទូទាំងប្រទេសប្រែក្លាយជាស្ងាត់ជ្រងំ ដោយសារតែប្រជាជនត្រូវបានគេជន្លៀសឱ្យទៅធ្វើការងារកសិកម្ម ។ ប្រហែលជាមួយភាគបីនៃប្រជាពលរដ្ឋសរុបត្រូវបានគេសំលាប់ ដែលក្នុងនោះមានចំនួនភាគច្រើនជាអ្នកដែលមានការចេះដឹង ។ ខ្មែរក្រហមបានបន្សល់ទុកនូវស្លាកស្នាម ដែលមិនអាចលុបជ្រះបាន នៅលើសង្គមកម្ពុជានាពេលបច្ចុប្បន្ន ដូចជា របួសផ្លូវចិត្ត និងអំពើហឹង្សាក្នុងសង្គម ។

ក្នុងឆ្នាំ 1991 ភាគីជំលោះនយោបាយក្នុងប្រទេសកម្ពុជា បានចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស ដែលបានត្រួសត្រាយផ្លូវឱ្យមានប្រតិបត្តិការកសាងសង្គមមួយមានលក្ខណៈទូលំទូលាយបំផុតនៅក្នុងប្រវត្តិសាស្ត្ររបស់អង្គការសហប្រជាជាតិ ។ ឆ្នាំ 1992 គឺជាឆ្នាំនៃការមកដល់នៃវត្តមានរបស់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការ

សហប្រជាជាតិ (UNTAC) ដែលគ្រប់គ្រងលើប្រទេសកម្ពុជា រហូតដល់មានការបោះឆ្នោតសភាជាទូទៅមួយ ក្នុងឆ្នាំ 1993 ។

រដ្ឋធម្មនុញ្ញថ្មីមួយ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1993 ដោយព្រះមហាក្សត្រសីហនុ គឺជានិមិត្តរូបនៃការបង្រួបបង្រួមព្រះរាជាណាចក្រកម្ពុជាឡើងវិញ។ នៅក្នុងរបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញនេះ អំណាចនយោបាយត្រូវបានប្រគល់ទៅឱ្យសភាជាតិ និងរដ្ឋាភិបាល ។ បន្ទាប់ពីមានការបោះឆ្នោត ដោយមានការជួយគាំទ្រពីសំណាក់សហគមន៍អន្តរជាតិ ប្រទេសកម្ពុជាបានធ្វើឱ្យសេដ្ឋកិច្ចរបស់ខ្លួនកាន់តែមានលក្ខណៈសេរីបន្តិចម្តងៗ ដោយមានផលទុនជាតិសរុប កើនឡើងប្រហែលជា 6 ភាគរយ ក្នុងមួយឆ្នាំៗ រវាងឆ្នាំ 1993 ដល់ 1997 ។

បន្ទាប់ពីមានការបោះឆ្នោតក្នុងខែ កក្កដា ឆ្នាំ 2003 រួចមក រដ្ឋាភិបាលចំរុះមួយ ដែលកើតចេញពីគណៈបក្សនយោបាយធំៗពីរ គឺគណៈបក្សប្រជាជនកម្ពុជា (CPP) និង គណៈបក្សហ្វ៊ុនស៊ិនប៉ិច (FUNCIPEC) ត្រូវបានបង្កើតឡើង ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជាប្រមុខរាជរដ្ឋាភិបាលកម្ពុជា ហើយព្រះអង្គម្ចាស់ រណឫទ្ធិ គឺជាប្រធានសភាជាតិ ។ ព្រះមហាក្សត្រនរោត្តម សីហមុនី ដែលបានស្នងរាជ្យបន្តពីព្រះបិតារបស់ទ្រង់ព្រះមហាក្សត្រនរោត្តម សីហនុ គឺជាប្រមុខរដ្ឋ ហើយត្រូវបានឡើងសោយរាជ្យ ជាព្រះមហាក្សត្រថ្មី ក្នុងខែតុលា ឆ្នាំ 2004 ។

រដ្ឋធម្មនុញ្ញឆ្នាំ 1993 គឺជាច្បាប់កំពូលរបស់ប្រទេសកម្ពុជា ។ គ្រប់ច្បាប់ និងគោលនយោបាយទាំងអស់ ត្រូវអនុលោមទៅតាមរដ្ឋធម្មនុញ្ញនេះ ។ បុព្វកថានៃច្បាប់រដ្ឋធម្មនុញ្ញ កំណត់ប្រព័ន្ធនយោបាយរបស់កម្ពុជា ថាជា "របបប្រជាធិបតេយ្យសេរីពហុបក្ស ដែលធានាឱ្យមានការគោរពសិទ្ធិមនុស្ស និងការគោរពច្បាប់ " ។ ប្រជាពលរដ្ឋកម្ពុជាបោះឆ្នោតជ្រើសរើសតំណាងរបស់ពួកគេដោយផ្ទាល់ ដែលជាសមាជិករដ្ឋសភា ដែលមានអំណាចនីតិបញ្ញត្តិ និងសិទ្ធិក្នុងការអនុម័តច្បាប់[1] ។ ធម្មនុញ្ញភាពរបស់ច្បាប់ទាំងនេះ ត្រូវបានការពារដោយក្រុមប្រឹក្សាធម្មនុញ្ញ ។ រដ្ឋាភិបាលត្រូវបានបង្កើតឡើងដោយសំលេងពីរភាគបីនៃរដ្ឋសភា ។ នាយករដ្ឋមន្ត្រីដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ដែលជាស្ថាប័ននីតិប្រតិបត្តិ ទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយ និងកម្មវិធីជាតិ ។ រដ្ឋធម្មនុញ្ញ ត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ 1999 ដើម្បីបង្កើតស្ថាប័នព្រឹទ្ធសភា បន្ថែមលើស្ថាប័ននីតិបញ្ញត្តិដែលមានស្រាប់ ។ ស្ថាប័ននេះមានអំណាចធ្វើការត្រួតពិនិត្យឡើងវិញលើច្បាប់នានា និងតម្រូវឱ្យសភាធ្វើការពិចារណាឡើងវិញ ។ អង្គនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ របស់រដ្ឋាភិបាល បំពេញតួនាទីដោយឡែកពីគ្នា ។ លើសពីនេះទៅទៀត ព្រះមហាក្សត្រដើរតួជាប្រមុខរដ្ឋ និងសោយរាជ្យសម្បត្តិ ក្នុងនាមជានិមិត្តរូបនៃការបង្រួបបង្រួមជាតិ ប៉ុន្តែមិនត្រួតត្រា ឬដឹកនាំប្រទេសជាតិឡើយ (តារាងទី 2.2) ។

1. សូមមើលតារាងទី ៧ សំរាប់អណត្តិរបស់ការិយាល័យនីមួយៗ

តារាងទី 2.7 របបនយោបាយរបស់ប្រទេសកម្ពុជាពីឆ្នាំ 1863 ដល់ពេលបច្ចុប្បន្ន

| | |
|---|---|
| 1863 - 1953 | ស្ថិតក្រោមអាណាព្យាបាលរបស់ប្រទេសបារាំង |
| 1953 - 1970 | ព្រះរាជាណាចក្រកម្ពុជា : "សង្គមរាស្ត្រនិយម" ដោយមានព្រះអង្គម្ចាស់ នរោត្តម សីហនុ ជាប្រមុខរដ្ឋ : *រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ* ។ |
| 1970 - 1975 | សាធារណរដ្ឋខ្មែរ : ដឹកនាំដោយមានសេនាប្រមុខ លន់ ណុល ជាប្រធានាធិបតី : *សាធារណរដ្ឋ* ។ |
| 1975 - 1979 | កម្ពុជាប្រជាធិបតេយ្យ : ខ្មែរក្រហម ដឹកនាំដោយសាឡុតស (ប៉ុល ពត): *កុំម្មុយនីស្តម៉ៅនិយម* ។ |
| 1979 - 1989 | សាធារណរដ្ឋប្រជាមានិតកម្ពុជា : ដឹកនាំដោយ សម្តេច ហេង សំរិន : *សង្គមនិយម* ។ |
| 1989 - 1993 | រដ្ឋកម្ពុជា និងអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា : *សង្គមនិយមបន្ទាប់មកការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ ពីឆ្នាំ 1992* ។ |
| 1993 - បច្ចុប្បន្ន | ព្រះរាជាណាចក្រកម្ពុជា : រាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ព្រះមហាក្សត្រ នរោត្តម សីហមុនី គ្រងរាជ្យសម្បត្តិ ប៉ុន្តែមិនដឹកនាំប្រទេសឡើយ : *រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ* ។ |

តារាងទី 2.8 អណត្តិការិយាល័យសំរាប់អ្នកដឹកនាំនយោបាយ

| **នាយករដ្ឋមន្ត្រី** | **សមាជិកសភា** | **សមាជិកព្រឹទ្ធសភា** |
|---|---|---|
| ជ្រើសតាំងដោយសភា តាមរយៈការបោះឆ្នោត ។ រយៈពេល 5 ឆ្នាំ ក្នុងមួយអណត្តិ ។ ពុំមានការកំរិតក្នុងការជ្រើសរើសឡើងវិញឡើយ ។ | រយៈពេល 5 ឆ្នាំ ក្នុងមួយអណត្តិ ។ ពុំមានការកំរិត ក្នុងការជ្រើសរើសឡើងវិញឡើយ | រយៈពេលមិនទាន់កំណត់ ។ ពុំមានការកំរិតក្នុងការជ្រើសរើសឡើងវិញឡើយ |

រូបភាពទី 2.2 រចនាសម្ព័ន្ធអភិបាលកិច្ចសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា



# 3. វដ្តគំរោងយន្តការអភិវឌ្ឍន៍ស្អាត

មុនពេលអានព័ត៌មានតាមប្រទេសដែលទាក់ទងជាមួយការបង្កើត និងការអនុវត្តគំរោង CDM ជាការសំខាន់ណាស់យើងទាំងអស់គ្នាត្រូវយល់ពាក្យបច្ចេកទេស និងវិធាន CDM មួយចំនួនជាមុនសិន ។ CDM មានបែបបទ និងនីតិវិធីពិសេសរបស់វា ហើយជំពូកនេះ ពន្យល់អំពីមូលដ្ឋានគ្រឹះនៃបែបបទ និងនីតិវិធីទាំងនេះ តាមរយៈការពិនិត្យមើលវដ្តគំរោង CDM[2] ។

## *3.1 និដ្ឋភាពទូទៅនៃគំរោងយន្តការអភិវឌ្ឍន៍ស្អាត*

CDM គឺជាយន្តការមួយ ដែលប្រទេសនៅក្នុងឧបសម្ព័ន្ធទី 1 (សូមមើលសេចក្តីបន្ថែមទី 1) មានកាតព្វកិច្ចពិសេសមួយ ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG) មុនឆ្នាំ 2012 នៅក្រោមពិធីសារក្យូតូ ដោយជាមួយគ្នានោះ ជួយដល់ប្រទេសដែលមិនស្ថិតនៅក្នុងឧបសម្ព័ន្ធទី 1 ក្នុងការអនុវត្តសកម្មភាពគំរោងដើម្បីកាត់បន្ថយឬស្រូបយក (ចាប់យក) ឧស្ម័ន GHGs យ៉ាងហោចណាស់មួយ ក្នុងចំណោមឧស្ម័ន GHGs ទាំង 6 (សូមមើលប្រអប់ទី 3.1 និងរូបភាពទី 3.1) ។ ប៉ុន្តែ ប្រទេសដែលមិនស្ថិតនៅក្នុងឧបសម្ព័ន្ធទី 1 ដែលជាហត្ថលេខី និងជាប្រទេសផ្តល់សច្ចាប័នដល់ពិធីសារក្យូតូ ពុំមានកាតព្វកិច្ចក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដូចបានចែងនៅក្រោមពិធីសារនេះឡើយ ។ ការកាត់បន្ថយបរិមាណឧស្ម័នផ្ទះកញ្ចក់ក្លាយជាឥណទានមួយ ដែលគេហៅថា **ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបានបញ្ជាក់ (CERs)** ដែលប្រទេសនៅក្នុងឧបសម្ព័ន្ធទី 1 អាចប្រើប្រាស់ដើម្បីជួយសំរេចគោលដៅនៃការកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ពួកគេ នៅក្រោមពិធីសារនេះ (UNFCCC 1997)[3] ។

---

2. ចំពោះព័ត៌មានលំអិតបន្ថែម សូមអានឯកសារផ្លូវការនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ។ គ្រប់ឯកសារទាំងអស់មាននៅក្នុងវ៉ិបសាយ http://cdm.unfccc.int ។ បែបបទ និងនីតិវិធីជាមូលដ្ឋានសំរាប់ CDM ត្រូវបានបង្កើតឡើងនៅក្នុងកិច្ចព្រមព្រៀង Marrakesh (UNFCCC 2001) ។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាប្រតិបត្តិនៃ CDM ជួបប្រជុំជាប្រចាំ និងធ្វើការសំរេចលើសេចក្តីលំអិត និងថ្លែងបញ្ជាក់អំពីវិធាននានា ដែលបានដាក់ចេញនៅក្នុងកិច្ចព្រមព្រៀងនេះ ។ មានសៀវភៅជាច្រើនដែលនិយាយអំពី CDM ។ ឯកសារបោះពុម្ពផ្សាយមួយចំនួនដែលអ្នកអានគួរមើលមាន : *តារាងសង្ខេបអំពីយន្តការអភិវឌ្ឍន៍ស្អាត និងការអនុវត្តរួមគ្នា* (MOE និង IGES 2005) នឹងជួយសម្របសម្រួលការយល់ដឹងជាមូលដ្ឋានអំពីគំរោង CDM ។ អ្នកអានក៏គួរអាន *សៀវភៅណែនាំស្តីអំពី CDM សំរាប់អ្នកអភិវឌ្ឍគំរោង* និង *អ្នកធ្វើគោលនយោបាយ* (ក្រសួងបរិស្ថាននៃប្រទេសជប៉ុន មូលនិធិមជ្ឈមណ្ឌលបរិស្ថានពិភពលោក, Pacific Consultants Co., Ltd., 2004) និង *មគ្គុទេសក៍វិធីសាស្ត្រគំរោង CDM* (ក្រសួងបរិស្ថាននៃប្រទេសជប៉ុន, មូលនិធិមជ្ឈមណ្ឌលបរិស្ថានពិភពលោក, Climate Experts, Ltd., វិច្ឆិកា 2004) ។
3. CDM គឺជាយន្តការមួយក្នុងចំណោមយន្តការជាច្រើននៃពិធីសារក្យូតូ ដែលបានបង្ហាញអំពីសកម្មភាពក្នុងប្រទេស ដើម្បីកាត់បន្ថយកំរិតនៃការបញ្ចេញឧស្ម័ន GHG នៅក្នុងប្រទេសឧបសម្ព័ន្ធទី 1 ។ នៅក្រោមឯកសារវិធានរបស់ UNFCCC ពុំមានការដាក់កំហិតសំរាប់ប្រទេសនៅក្នុងឧបសម្ព័ន្ធទី 1 ឱ្យកំរិតការប្រើប្រាស់ CERs ឬឥណទានដទៃទៀត ដែលទទួលបាននៅក្រោមយន្តការនានានៃពិធីសារក្យូតូ ដើម្បីបំពេញទិសដៅកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ប្រទេសទាំងនេះទេ លើកលែងតែ CERs ដែលបានមកពីសកម្មភាពចាប់យកកាបូន (UNFCCC 2001b, 2) ។ យ៉ាងណាក៏ដោយ ប្រទេសនៅក្នុងឧបសម្ព័ន្ធទី 1 នីមួយៗ អាចបង្កើតវិធានផ្ទាល់ខ្លួន ដើម្បីធានាឱ្យបានច្បាស់ថា មានកិច្ចប្រឹងប្រែងជាច្រើនត្រូវបានធ្វើនៅក្នុងប្រទេសនោះ ។

ប្រអប់ទី 3.1 ឧស្ម័នផ្ទះកញ្ចក់ទាំង 6 ដែលបានចែងនៅក្រោមពិធីសារក្យូតូ

ឧស្ម័នផ្ទះកញ្ចក់ទាំង 6 នេះ មានសក្តានុពលកំណើនកំដៅសកល (GWP) ពុំដូចគ្នាទេ ។ GWP វាស់វែងនូវឥទ្ធិពលនៃការបំភាយឧស្ម័ន GHGs ដោយប្រៀបធៀបជាមួយនឹងឧស្ម័នកាបូនិច ($CO_2$) ។ ឧទាហរណ៍ មេតានមួយតោន មាន GWP ស្មើនឹងឧស្ម័នកាបូនិច 21 តោន ។

| ឧស្ម័នផ្ទះកញ្ចក់ | សក្តានុពលកំណើនកំដៅសកល |
|---|---|
| 1. ឧស្ម័នកាបូនិច ($CO_2$) | 1 |
| 2. ឧស្ម័នមេតាន ($CH_4$) | 21 |
| 3. ឧស្ម័នឌីអាសូតម៉ូណូអុកស៊ីត ($N_2O$) | 310 |
| 4. ឧស្ម័នអ៊ីដ្រូភ្លុយអរ៉ូកាបូន (HFCs) | 140-11,700 |
| 5. ឧស្ម័នពែភ្លុយអរ៉ូកាបូន (PFCs) | 6,500-9,200 |
| 6. ឧស្ម័នស៊ុលភួអ៊ិចសាភ្លុយអ័រ ($SF_6$) | 23,900 |

*ប្រភព : UNFCCC 1997*

រូបភាពទី 3.1 ដ្យាក្រាមបង្ហាញអំពីការបំពេញមុខងាររបស់ CDM




*ប្រភព: ក្រសួងបរិស្ថាននៃប្រទេសជប៉ុន និងIGES 2005*

## *3.2 សកម្មភាពគំរោងដែលអាចអនុវត្តបាន*

សកម្មភាពគំរោង CDM ត្រូវតែឱ្យផលជាការកាត់បន្ថយ ឬការស្រូបយក (ការចាប់យកកាបូន) ឧស្ម័ន GHGs ដែល *ពិតប្រាកដ និងដែលអាចវាស់វែងបាន* ហើយដែល *មិនអាចកើតឡើងបានទេប្រសិនបើគ្មានវត្តមាននៃសកម្មភាពគំរោងដែលបានស្នើ (ផលបន្ថែម)* (UNFCCC 2001b, 20)) ។ ម្យ៉ាងវិញទៀត ដើម្បីមានលក្ខណៈគ្រប់គ្រាន់ក្នុងការទទួលបានឥណទាន សកម្មភាពគំរោងត្រូវតែបង្ហាញថា ការបញ្ចេញឧស្ម័ន GHG ត្រូវបានកាត់បន្ថយ បើប្រៀបធៀបទៅនឹង "សេណារីយ៉ូគោល" ដែលតំណាងឱ្យការបញ្ចេញឧស្ម័ន GHG នៅក្រោមស្ថានភាពធម្មតា ។

ទិដ្ឋភាពសំខាន់មួយទៀតនៃ CDM គឺថា សកម្មភាពគំរោង CDM ដែលបានស្នើឡើងត្រូវតែបង្ហាញពីការចូលរួមចំណែករបស់ខ្លួនក្នុងកិច្ចការពារបរិស្ថាន និងគោលដៅអភិវឌ្ឍន៍ដោយចីរភាពរបស់ប្រទេសម្ចាស់គំរោង (UNFCCC 2001b , 20) ។ ការកាត់បន្ថយការបញ្ចេញឧស្ម័ន GHG តែមួយមុខ ប្រហែលជាមិនទាន់គ្រប់គ្រាន់ ដើម្បីបំពេញលក្ខខណ្ឌនេះឡើយ ។ រដ្ឋាភិបាលនៃប្រទេសម្ចាស់គំរោងជាច្រើន ផ្តល់ព័ត៌មានអំពីលក្ខខណ្ឌជាមុនរបស់ខ្លួន ដែលគេហៅថា "លក្ខណៈវិនិច្ឆ័យនៃការអភិវឌ្ឍប្រកបដោយចីរភាព" (សូមមើលជំពូកទី 5 សំរាប់សេចក្តីលំអិតបន្ថែម) ។

លើសពីនេះ មានលក្ខខណ្ឌផ្សេងទៀត ដែលមិនអនុញ្ញាតឱ្យមានការប្រើប្រាស់ជាគំរោង CDM មានដូចជា :

- ការកាត់បន្ថយការបញ្ចេញឧស្ម័នពីរោងចក្រថាមពលនុយក្លេអ៊ែរ (UNFCCC 2001b , 20)
- ការបង្វែរជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ពីប្រទេសនៅក្នុងឧបសម្ព័ន្ធទី 1 (UNFCCC 2001b, 20) និង/ឬ
- ប្រភេទសកម្មភាពគំរោងចាប់យកកាបូន ក្រៅពីការដាំព្រៃ និងស្តារព្រៃឈើឡើងវិញ (UNFCCC 2001b កថាខ័ណ្ឌ 7(a) 22) ។

តារាងទី 3.1 សង្ខេបអំពីប្រភេទសកម្មភាពគំរោងមួយចំនួនដែលអាចអនុវត្តបាន និងឧទាហរណ៍មួយចំនួន ។ ព័ត៌មានលំអិតនៅតាមប្រទេសនីមួយៗ អំពីសក្តានុពលសកម្មភាពគំរោង CDM មានក្នុងជំពូកទី 4 ។

សូមកត់សំគាល់ផងដែរថា រោងចក្រដែលមានស្រាប់ ឬដែលទើបសាងសង់ថ្មី ដែលដំណើរការរួចហើយនោះ នៅតែអាចចុះបញ្ជីជាសកម្មភាពគំរោង CDM បាន ប្រសិនបើអាចបំពេញលក្ខខណ្ឌខាងក្រោមនេះបាន (UNFCCC 2001b កថាខ័ណ្ឌ 13, 23 កថាខ័ណ្ឌ 1 [c] 5) :

- សកម្មភាពគំរោងដែលបានស្នើ ចាប់ផ្តើមនៅចន្លោះពី ថ្ងៃទី 1 ខែ មករា ឆ្នាំ 2000 និងកាលបរិច្ឆេទដែលសកម្មភាពគំរោង CDM ទីមួយត្រូវបានចុះបញ្ជីការ (ថ្ងៃទី 18 ខែ វិច្ឆិកា ឆ្នាំ 2004)
- សកម្មភាពគំរោង ត្រូវបានដាក់បញ្ជូនទៅកាន់ក្រុមប្រឹក្សាប្រតិបត្តិ CDM ដែលជាស្ថាប័នគ្រប់គ្រង CDM ដើម្បីសុំការចុះបញ្ជីការ ឱ្យបានមុនថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2005 ហើយ
- ភស្តុតាងសំរាប់ CDM ត្រូវបានយកមកធ្វើការពិចារណា នៅក្នុងដំណាក់កាលរៀបចំគំរោង ។

### *3.3 ចំណាត់ថ្នាក់សកម្មភាពគំរោង CDM*

សកម្មភាពគំរោង CDM អាចចែកចេញជា 2 ផ្នែកសំខាន់ៗ : (1) ការកាត់បន្ថយការបញ្ចេញ GHG និង (2) ការចាប់យកកាបូន (អាងស្រូបកាបូន)។ នៅក្នុងប្រភេទគំរោងសំខាន់ៗទាំងពីរនេះ មានប្រភេទគំរោងតូចៗជាច្រើនទៀតទៅតាមទំហំរបស់គំរោង (រូបភាពទី 3.2)។

រូបភាពទី 3.2 ចំណាត់ថ្នាក់ប្រភេទរង នៃសកម្មភាពគំរោង CDM




តារាងទី 3.1 ប្រភេទគំរោង ដែលអាចអនុវត្តបាននៅក្រោម CDM

| | | **វិសាលភាពតាមវិស័យ** | **ឧទាហរណ៍** | |
|---|---|---|---|---|
| 1 | សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័ន | ឧស្សាហកម្មថាមពល (ប្រភពកកើតឡើងវិញ/មិនកកើតឡើងវិញ) | ថាមពលកកើតឡើងវិញ | ថាមពលខ្យល់ ថាមពលពន្លឺព្រះអាទិត្យ វារីអគ្គិសនី កំដៅផែនដី |
| | | | ថាមពលមិនកកើតឡើងវិញ | ការផលិតរួមគ្នារវាងកំដៅ និងថាមពល (CHP); ការផ្លាស់ប្តូរឥន្ធនៈពីធ្យូងថ្ម ឬ ប្រេងឥន្ធនៈ មកជាឧស្ម័នធម្មជាតិ |
| 2 | | ការចែកចាយថាមពល | អគ្គិសនី | ខ្សែបញ្ជូន និងខ្សែចែកចាយ |
| 3 | | តំរូវការថាមពល | ប្រសិទ្ធភាពថាមពល | បរិក្ខារ និងការបំភ្លឺ ដែលមានប្រសិទ្ធភាពខ្ពស់ |
| 4 | | ឧស្សាហកម្មផលិត | ប្រសិទ្ធភាពថាមពល | បរិក្ខារដែលមានប្រសិទ្ធភាពខ្ពស់ |
| | | | ការផ្លាស់ប្តូរឥន្ធនៈ | ពីធ្យូងថ្មមកជាឧស្ម័នធម្មជាតិ បច្ចេកវិទ្យាធ្យូងថ្មស្អាត |
| 5 | | ឧស្សាហកម្មគីមី | ការផ្លាស់ប្តូរដំណើរការ | ការកាត់បន្ថយឧស្ម័នឌីអាសូតម៉ូណូអុកស៊ីត |
| 6 | | ការសាងសង់ | ការជំនួសវត្ថុធាតុដើម | វិធានការសន្សំសំចៃថាមពល ចំងាយដឹកជញ្ជូនសំរាប់រថយន្តខ្លីជាងមុន |

| | | វិសាលភាពតាមវិស័យ | ឧទាហរណ៍ | |
|---|---|---|---|---|
| 7 | | ការដឹកជញ្ជូន | ប្រសិទ្ធភាពថាមពល | កែលំអប្រសិទ្ធភាពយានយន្ត ពង្រីកផ្លូវ |
| | | | ការជំនួសឥន្ទនៈ | ជីវឥន្ទនៈ ឥន្ទនៈឧស្ម័នធម្មជាតិ |
| 8 | | ផលិតកម្មរ៉ែ | ការជំនួសឥន្ទនៈ | ការចាប់យកមេតានពីអណ្តូងរ៉ែធ្យូងថ្ម |
| 9 | | ផលិតកម្មលោហៈ | ប្រសិទ្ធភាពថាមពល | ការបង្កើនប្រសិទ្ធភាពការផលិត |
| | | | ការផ្លាស់ប្តូរដំណើរការ | ការពន្លត់ធ្យូងកូកស្ងួត |
| 10 | | ការបញ្ចេញឧស្ម័នពីការដឹកជញ្ជូនចេញពីឥន្ទនៈ (រឹង រាវ និងឧស្ម័ន) | ការជំនួសឥន្ទនៈ | ការចាប់យកនិងប្រើប្រាស់ឧស្ម័នពីអណ្តូងប្រេង |
| 11 | | ការបញ្ចេញឧស្ម័នពីការដឹកជញ្ជូនពីការផលិត និងការប្រើប្រាស់ halocarbons និងឧស្ម័នស៊ុលភួអ៊ិចសាភ្លុយអ័រ | ឧស្ម័នអ៊ីដ្រូភ្លុយអរ៉ូកាបូន | ការដុតកាកសំណល់ HFC-23 |
| 12 | | ការប្រើប្រាស់សារធាតុរំលាយ | ការជំនួសវត្ថុធាតុដើម | ការជំនួសដោយសំភារៈ ដែលបញ្ចេញ GHG តិចជាងមុន |
| 13 | | ការដឹកជញ្ជូន និងការបោះចោលកាកសំណល់ | ការជំនួសឥន្ទនៈ | ការចាប់យកឧស្ម័នពីទីលានចាក់សំរាម<br>ប្រព្រឹត្តិកម្មសំណល់រាវ<br>ប្រព្រឹត្តិកម្មសំណល់សត្វ |
| 14 | ការចាប់យកកាបូន | ការស្តារព្រៃឈើ និងការដាំព្រៃ | ការស្តារព្រៃ | |
| | | | ការដាំព្រៃ | |
| 15 | | កសិកម្ម | | ការចៀសវាងផលិតកម្មមេតានពីការពុកផុយជីវម៉ាស |

*ប្រភព: UNFCCC 2005a; វិទ្យាស្ថានផិមប៊ីណា (Pembina) 2003; Houghton et al. 1997; សាជីវកម្មស្គីម៉ីហ្ស៊ូ (Shimizu) 2004; និងគំនិតរបស់អ្នកនិពន្ធ*

### 3.4 គំរោង CDM ខ្នាតតូច

បើទោះបីជា CDM ត្រូវបានបង្កើតឡើង ដើម្បីជំរុញឱ្យមានការអភិវឌ្ឍដោយចីរភាពនៅក្នុងប្រទេសម្ចាស់គំរោងក៏ដោយ ក៏ជាទូទៅការអនុវត្តសកម្មភាពគំរោង CDM ខ្នាតតូច ដែលមានអត្ថប្រយោជន៍ដល់ការអភិវឌ្ឍសហគមន៍ប្រកបដោយចីរភាព មានការចំណាយយ៉ាងខ្ពស់ ហើយទទួលបានផលចំណេញតិច ។ ដើម្បីជួយសំរួលដល់ការរៀបចំសកម្មភាព CDM ខ្នាតតូច UNFCCC បានបង្កើតបែបបទ និងនីតិវិធីរហ័សមួយ (fast-track) ដែលផ្តល់នូវការអនុគ្រោះមួយចំនួន ។ សកម្មភាពគំរោងមួយដែលមានលក្ខណៈគ្រប់គ្រាន់ជាគំរោង CDM ខ្នាតតូច លុះត្រាតែគំរោង

នោះអាចបំពេញបាននូវលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌទាំង 3 ដូចខាងក្រោម (UNFCCC 2001b កថាខ័ណ្ឌ 6 [c], 21):

- *ប្រភេទទី 1 :* សកម្មភាពគំរោងថាមពលកកើតឡើងវិញ ដែលមានសមត្ថភាពផលិតអតិបរមារហូតដល់ 15 មេហ្គាវ៉ាត់ (ឬសមមូល)
- *ប្រភេទទី 2 :* សកម្មភាពគំរោងប្រសិទ្ធភាពថាមពល ដែលកាត់បន្ថយការប្រើប្រាស់ថាមពល ផ្នែកខាងការផ្គត់ផ្គង់ និង/ឬ ផ្នែកខាងអ្នកប្រើប្រាស់ ក្នុងចំនួនរហូតដល់ 15 ហ្គីហ្គាវ៉ាត់ម៉ោង ក្នុងមួយឆ្នាំ
- *ប្រភេទទី 3 :* សកម្មភាពគំរោងដទៃទៀត ដែលកាត់បន្ថយការបញ្ចេញឧស្ម័នដោយសកម្មភាពមនុស្សពីប្រភព និងដែលអាចបញ្ចេញសមមូលឧស្ម័នកាបូនិច ($CO_2e$) តិចជាង 15 គីឡូតោនក្នុងមួយឆ្នាំ ។

សកម្មភាពគំរោង CDM ខ្នាតតូច ទទួលបានអត្ថប្រយោជន៍ពីបុព្វសិទ្ធិជាច្រើន ដែលអាចឱ្យសកម្មភាពគំរោងទាំងនេះពន្លឿនដំណើរការចុះបញ្ជីការរបស់ខ្លួន ។ សេចក្តីលំអិតនៃរបបពិសេស ដែលផ្តល់ទៅឱ្យគំរោងខ្នាតតូចនានា មាននៅក្នុងទិដ្ឋភាពរួមនៃវដ្តគំរោង CDM (វគ្គ 3.7) ។

លក្ខណៈពិសេសដែលអាចអនុវត្តបានតែចំពោះសកម្មភាពគំរោង CDM ខ្នាតតូច គឺការដាក់បញ្ចូលគ្នាជាក្រុម (bundling) និងការដាក់ពង្រាយដាច់ពីគ្នា (debundling) ។ ***ការដាក់បញ្ចូលគ្នាជាក្រុម*** គឺត្រូវប្រមូលផ្តុំគំរោងទាំងឡាយណាដែលមានទំហំតូចពេក ដើម្បីទាក់ទាញការវិនិយោគ តាមរយៈចំណូល CER បន្ថែមឱ្យនៅជាក្រុម ។ តាមរយៈការប្រើប្រាស់ផែនការដាក់បញ្ចូលគ្នាជាក្រុម គំរោងតូចៗអាចមានប្រសិទ្ធភាពផ្នែកចំណាយ ជាហេតុធ្វើឱ្យមានការទាក់ទាញចំណូល CER គ្រាន់បង្គួរ ។ គំរោងតាមសហគមន៍ជាច្រើន (ដូចជាវ៉ារីអគ្គិសនី) និងគំរោងសំរាប់សហគ្រាសខ្នាតតូច និងខ្នាតមធ្យមមួយចំនួនទៀត ដែលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍប្រកបដោយចីរភាព ជារឿយៗប្រឈមនឹងការលំបាកក្នុងការទាក់ទាញចំណាប់អារម្មណ៍សំរាប់ការវិនិយោគឱ្យបានគ្រប់គ្រាន់ ដោយពុំមានការគាំទ្រជាសាធារណៈក្នុងកំរិតបង្គួរមួយ ។ គំរោងទាំងនេះអាចប្រើប្រាស់ផែនការបញ្ចូលគ្នាជាក្រុម ដើម្បីធ្វើឱ្យកាន់តែប្រសើរនូវភាពអាចរកផលចំណេញហិរញ្ញវត្ថុជាទូទៅរបស់ខ្លួន ។ ពុំមានការកំរិតចំនួនគំរោងដែលអាចដាក់បញ្ចូលគ្នាតែមួយនៅក្រោមវិធាន UNFCCC បច្ចុប្បន្ននោះទេ ដរាបណាទំហំសរុបនៃសកម្មភាពគំរោងដែលដាក់បញ្ចូលគ្នាមិនលើសពីទំហំកំណត់សំរាប់សកម្មភាពគំរោង CDM ខ្នាតតូច ។ ខណៈពេលដែលគេអាចដាក់គំរោងតូចៗបញ្ចូលគ្នាបាន គំរោងខ្នាតធំៗមិនអាចបំបែកឱ្យទៅជាគំរោងតូចៗ ក្នុងទំហំដែលមាននៅក្នុងវិធាន CDM ខ្នាតតូច (ប្រអប់ទី 3.2) បាននោះទេ ដើម្បីកុំឱ្យមាននរណាម្នាក់កេងយកប្រយោជន៍ពីនីតិវិធីរហ័ស (fast-track) និងផែនការតំលៃប្រសិទ្ធភាពសំរាប់គំរោង CDM ខ្នាតតូច ។ ខណៈពេលដែលផែនការដាក់បញ្ចូលគ្នាអាចជាដំណោះស្រាយល្អមួយសំរាប់គំរោងតូចៗ ដែលមានអត្ថប្រយោជន៍ចំពោះការអភិវឌ្ឍប្រកបដោយចីរភាព នៅក្នុងការអនុវត្តជាក់ស្តែង ក៏មានការលំបាកជាច្រើនដែលត្រូវប្រឈម ដូចជានៅក្នុងការបង្កើតផែនការមួយ ដើម្បីពិនិត្យតាមដានសកម្មភាពគំរោងដែលដាក់បញ្ចូលគ្នាទាំងអស់ ។

ប្រអប់ទី 3.2 របៀបធ្វើការកំណត់ថាតើគំរោងមួយអាចយកមកពិចារណា បំបែកទៅជាគំរោងតូចៗ បានដែរឬទេ

| |
|---|
| UNFCCC (UNFCCC 2002, 27) ទទួលស្គាល់សកម្មភាពគំរោងខ្នាតតូចនានាថាមានសិទ្ធិបំបែកខ្លួន ចេញពីសកម្មភាពគំរោងធំមួយបាន ប្រសិនបើគំរោងនោះត្រូវបានចុះបញ្ជីការរួចទៅហើយ ឬក៏រំពឹងថានឹងត្រូវបានចុះបញ្ជីការ ជាសកម្មភាពគំរោង CDM ខ្នាតតូច ហើយប្រសិនបើមានគំរោងរបៀបនោះ គំរោងនោះត្រូវ :<br>• ជាគំរោងដែលមានអ្នកចូលរួមក្នុងគំរោងដដែល<br>• នៅក្នុងគំរោង និងប្រភេទបច្ចេកវិទ្យា/វិធានការដូចគ្នា<br>• ត្រូវបានចុះបញ្ជីការក្នុងរយៈពេល 2 ឆ្នាំមុន<br>• មានព្រំដែនគំរោងស្ថិតនៅក្នុងចំងាយ 1 គីឡូម៉ែត្រ នៃព្រំដែនគំរោងខ្នាតតូចដែលបានស្នើឡើង នៅចំណុចដែលជិតបំផុត ។ |

## *3.5 វិស័យព្រៃឈើ និងយន្តការអភិវឌ្ឍន៍ស្អាត*

នៅក្រោមវិធានបច្ចុប្បន្ន គំរោង CDM អាចអនុវត្តបានតែចំពោះសកម្មភាពគំរោងដាំព្រៃ និងស្តារព្រៃឡើងវិញ (A/R) តែប៉ុណ្ណោះ ដែលជាសកម្មភាពគំរោងស្រូបយកកាបូន ហើយសកម្មភាពគំរោងទាំងនោះត្រូវបានកំណត់ដូចខាងក្រោមនេះ (UNFCCC 2001a កថាខ័ណ្ឌ 1 (b), (c), 58):

- *ការដាំព្រៃ* គឺជាការផ្លាស់ប្តូរដោយសកម្មភាពមនុស្សផ្ទាល់ ធ្វើឱ្យដីដែលគ្មានព្រៃអស់រយៈពេលយ៉ាងហោចណាស់ 50 ឆ្នាំ ឱ្យក្លាយទៅជាដីព្រៃ តាមរយៈការដាំដុះ ការបណ្តុះគ្រាប់ពូជរុក្ខជាតិ និង/ឬ ការលើកកំពស់ប្រភពគ្រាប់ពូជធម្មជាតិ ដែលធ្វើឡើងដោយសកម្មភាពមនុស្ស ។
- *ការស្តារព្រៃឡើងវិញ* គឺជាការផ្លាស់ប្តូរពីដីដែលធ្លាប់មានព្រៃឈើពីមុនមក តែត្រូវគេកាប់បំផ្លាញអស់ មកជាដីមានព្រៃឈើវិញ ។ សំរាប់ដំណាក់កាលកាតព្វកិច្ចទីមួយ សកម្មភាពស្តារព្រៃនឹងកំរិតត្រឹមតែការស្តារព្រៃដែលកើតមានឡើងនៅលើប្រភេទដី ដែលពុំមានព្រៃឈើមុនថ្ងៃទី 31 ខែធ្នូ ឆ្នាំ 1989 តែប៉ុណ្ណោះ ។

សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីទទួលសកម្មភាពគំរោង CDM ដាំព្រៃ និង/ឬ ស្តារព្រៃឡើងវិញ (A/R) បានស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត (DNA) នៃប្រទេសនោះចាំបាច់ត្រូវកំណត់និយមន័យព្រៃឈើ និងរាយការណ៍ទៅក្រុមប្រឹក្សាប្រតិបត្តិ CDM អំពីប៉ារ៉ាម៉ែតខាងក្រោមនេះ (UNFCCC 2003 កថាខ័ណ្ឌ 7-8, 17) បន្ថែមលើលក្ខខណ្ឌចូលរួមជាទូទៅ នៅក្នុង*របបបទ និងនីតិវិធី CDM* (ឧបសម្ព័ន្ធនៃសេចក្តីសំរេចចិត្ត 17/ CP.7):

ក. គំរបព្រៃអប្បបរមា មានរវាងពី 10 ទៅ 30 ភាគរយ

ខ. ទំហំដីអប្បបរមានៅចន្លោះរវាងពី 0,05 ទៅ 1 ហិចតា

គ. កំពស់ដើមឈើអប្បបរមា នៅចន្លោះរវាងពី 2 ទៅ 5 ម៉ែត្រ ។

UNFCCC កំណត់សកម្មភាពគំរោងដាំព្រៃ និងស្តារព្រៃឡើងវិញខ្នាតតូចថា "សកម្មភាពគំរោងទាំងឡាយណាដែលគេរំពឹងថានឹងអាចចាប់យកឧស្ម័នផ្ទះកញ្ចក់បាន ជាឧស្ម័នកាបូនិច ($CO_2$) 8 គីឡូតោន ក្នុងមួយឆ្នាំ តាមរយៈអាងស្រូបកាបូន និងត្រូវបានបង្កើត ឬអនុវត្តឡើងដោយសហគមន៍ ដែលមានចំណូលទាប ដូចដែលបានកំណត់ដោយប្រទេសម្ចាស់គំរោង "（UNFCCC 2003 កថាខ័ណ្ឌ 1 [I], 16） ។ អ្នករៀបចំគំរោងគួរយល់ដឹងថា បើទោះបីជាសកម្មភាពគំរោងដាំព្រៃ និងស្តារព្រៃឡើងវិញខ្នាតតូច អាចស្រូបយកឧស្ម័ន $CO_2e$ បានជាង 8 គីឡូតោន ក្នុងមួយឆ្នាំក៏ដោយ ក៏គ្មានការចេញឥណទានណាមួយត្រូវបានអនុញ្ញាតសំរាប់ការចាប់យកឧស្ម័នកាបូនិច ដែលច្រើនហួសពីការកំណត់ឡើយ ។

បើទោះបីជាវដ្តគំរោងស្រដៀងគ្នាទៅនឹងវដ្តគំរោង នៃគំរោងសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នដ៏ទៃទៀតក៏ដោយ ក៏សកម្មភាពគំរោងដាំព្រៃ និងស្តារព្រៃឡើងវិញសំរាប់ CDM ចាំបាច់ត្រូវធ្វើតាមវិធានមួយផ្សេងទៀតរបស់ UNFCCC ។ ភាពខុសគ្នាគួរឱ្យកត់សំគាល់មួយចំនួនមានដូចជា របៀបគណនាការចាប់យកកាបូនពីការបញ្ចេញ GHG និង CERs ត្រូវបានគេចេញឱ្យ (សូមមើលវគ្គ 3.7.3 ស្តីពីការកំណត់លក្ខខណ្ឌរបស់គំរោងមួយ) ។

## *3.6 ឥណទាន និងរយៈពេលផ្តល់ឥណទាន*

លក្ខណៈសំខាន់មួយក្នុងចំណោមលក្ខណៈសំខាន់ៗជាច្រើនរបស់សកម្មភាពគំរោង CDM គឺថា សកម្មភាពគំរោងទាំងនេះអាចបង្កើតឥណទានបញ្ចេញឧស្ម័នដែលអាចដោះដូរបាន (CERs)[4] ។ តារាងទី 3.2 សង្ខេបពីជំរើសផ្សេងៗសំរាប់រយៈពេលផ្តល់ឥណទាន និងប្រភេទឥណទាន ដែលត្រូវចេញឱ្យសំរាប់ការកាត់បន្ថយការបញ្ចេញ GHG និងសកម្មភាពគំរោងស្តារ និងដាំឈើឡើងវិញ ។

4. អ្នកចូលរួមពីប្រទេសកំពុងអភិវឌ្ឍន៍អាចលក់ ឬផ្ទេរឥណទាន ទៅឱ្យអ្នកចូលរួមគំរោងពីប្រទេសឧស្សាហកម្មជឿនលឿន ។ ប៉ុន្តែប្រទេសកំពុងអភិវឌ្ឍន៍មិនត្រូវបានអនុញ្ញាតឱ្យលក់ដូរឥណទានដោយសេរី នៅក្នុងទីផ្សារធ្វើពាណិជ្ជកម្មលើការបញ្ចេញឧស្ម័នឡើយ ។

តារាងទី 3.2 ឥណទាន និងរយៈពេលផ្តល់ឥណទាន សំរាប់សកម្មភាពគំរោង CDM

| | សកម្មភាពគំរោងកាត់បន្ថយការបញ្ចេញ GHG | សកម្មភាពគំរោង A/R |
|---|---|---|
| រយៈពេលផ្តល់ឥណទាន | i. 7 ឆ្នាំ ដោយមានជំរើសបន្តឡើងវិញបាន 2 ដង (រយៈពេលផ្តល់ឥណទានសរុប = 21 ឆ្នាំ) | i. អតិបរមា 20 ឆ្នាំ ដោយមានជំរើសបន្តឡើងវិញបាន 2 ដង (រយៈពេលឥណទានសរុប = 60 ឆ្នាំ) |
| | ii. 10 ឆ្នាំ ដោយពុំមានជំរើសបន្តឡើងវិញ | ii. អតិបរមា 30 ឆ្នាំ ដោយពុំមានជំរើសបន្តឡើងវិញ |
| ប្រភេទឥណទាន | CERs | i. CERs បណ្តោះអាសន្ន (tCERs) : ចាប់យកឧស្ម័ន GHG សុទ្ធដែលសំរេចបានតាមរយៈគំរោងអាងស្តុកកាបូន ចាប់តាំងពីពេលចាប់ផ្តើមគំរោង ដែលនឹងត្រូវជំនួសដោយឥណទានផ្សេងទៀតនៃពិធីសារក្យូតូ មុនពេលបញ្ចប់កាតព្វកិច្ចជាបន្តបន្ទាប់ ។ |
| | | ii. CERs រយៈពេលវែង (lCERs) : ការចាប់យកឧស្ម័ន GHG សុទ្ធ តាមរយៈអាងស្តុកកាបូន ដែលសំរេចបានតាមរយៈសកម្មភាពគំរោង នៅក្នុងចន្លោះពេលផ្សេងផ្ទាត់នីមួយៗ ។ |

*ប្រភព :* UNFCCC 2001b, កថាខ័ណ្ឌ 49, 37; UNFCCC 2003, កថាខ័ណ្ឌ 23, 1 និង កថាខ័ណ្ឌ 38, 24 ។

រាល់ការបន្តរយៈពេលផ្តល់ឥណទានសារជាថ្មី តំរូវឱ្យមានការពិនិត្យឡើងវិញទៅលើសេណារីយ៉ូគោលរបស់សកម្មភាពគំរោងបន្ថយការបញ្ចេញឧស្ម័ន GHG និងទាំងសកម្មភាពគំរោងចាប់យកកាបូន ។ ប្រទេសនៅក្នុងឧបសម្ព័ន្ធទី 1 នីមួយៗ អាចបន្តក្នុងកំរិតអតិបរមា 2,5 ភាគរយ នៃបរិមាណដែលបានកំណត់របស់ខ្លួន រហូតដល់កំឡុងពេលកាតព្វកិច្ចកាត់បន្ថយឧស្ម័នបន្ទាប់ (next committment period) (ដែលគ្រោងនឹងចាប់ផ្តើម ចាប់ពីឆ្នាំ 2013 តទៅ)[5] ។ បន្ថែមពីលើនេះទៅទៀត មានកំរិតមួយដែលត្រូវបានដាក់លើឥណទានសកម្មភាពគំរោង A/R CDM យ៉ាងហោចណាស់ សំរាប់កំឡុងពេលកាតព្វកិច្ចកាត់បន្ថយឧស្ម័នទីមួយ (first committment period) ដែលការកំណត់នេះបានចែងថា " មិនឱ្យលើសពី 1 ភាគរយ នៃឆ្នាំបញ្ចេញឧស្ម័នគោលរបស់ភាគី [ក្នុងឧបសម្ព័ន្ធ ទី 1] នោះប្រាំដង " (CP/2001/13/Add.2, កថាខ័ណ្ឌ 7 [b], 22) ។

ការគណនាការចាប់យកបរិមាណឧស្ម័ន GHG សុទ្ធ ដោយសកម្មភាពគំរោងដាំព្រៃ និងស្តារព្រៃឡើងវិញសំរាប់គំរោង CDM ត្រូវបានពិពណ៌នា នៅក្នុងវគ្គលក្ខខណ្ឌគោលនៃជំពូកនេះ (3.7.3) ។

5. ចំនួនសរុបនៃបរិមាណឯកតា ដែលបានកំណត់ទៅឱ្យភាគីនៅក្នុងឧបសម្ព័ន្ធទី 1 គណនាដោយយកការបញ្ចេញនៅឆ្នាំគោល ដកការកាត់បន្ថយការបញ្ចេញឧស្ម័នគោលដៅចេញ ។

### 3.7 និដ្ឋភាពរួមនៃវដ្តគំរោង CDM

នៅក្នុងខែធ្នូ ឆ្នាំ 2001 អ្នកចរចាបានបង្កើតបែបបទ និងនីតិវិធីនៃគោលនយោបាយការប្រែប្រួលអាកាសធាតុជាអន្តរជាតិ ដែលរួមមាន វិធាន និងបទបញ្ញត្តិគំរោង CDM ដែលត្រូវបានបង្កើតឡើង ដូចគ្នានឹងកិច្ចព្រមព្រៀងម៉ារ៉ាកេសដែរ [6] ។ ក្រុមប្រឹក្សាប្រតិបត្តិនៃគំរោងយន្តការអភិវឌ្ឍន៍ស្អាត ត្រូវបានបង្កើតឡើង ឱ្យដើរតួនាទីជាលេខាធិការដ្ឋានរបស់ UNFCCC ដើម្បីត្រួតពិនិត្យដំណើរការគំរោង CDM ។ ដើម្បីចុះបញ្ជីការជាសកម្មភាពគំរោង CDM បាន អ្នកស្នើគំរោងចាំបាច់ត្រូវធ្វើតាមដំណាក់កាលនានា ដូចដែលមានចែងលំអិតនៅក្នុងរូបភាពទី 3.3 ។

#### 3.7.1 ការបង្កើតគំរោង

ដំណាក់កាលទីមួយនៅក្នុងការបង្កើតគំរោង CDM គឺត្រូវកំណត់សកម្មភាពគំរោងមួយ និងត្រូវពិនិត្យថា តើសកម្មភាពគំរោងនេះ អាចមានសិទ្ធិសំរាប់អនុវត្តគំរោង CDM បានដែរឬទេ ។ ក្នុងការប្រមូលព័ត៌មានពីស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត (DNA) លក្ខខណ្ឌនានាដែលស្ថាប័នជាតិនេះតំរូវឱ្យមាន និងនីតិវិធីដើម្បីទទួលបានការអនុម័តគំរោង គឺជាការសំខាន់ផងដែរ ។ ដោយសារតែគំរោង CDM គឺជាយន្តការមួយ ដែលត្រូវបានបង្កើតឡើងដើម្បីរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ព័ត៌មានពី DNA នៃប្រទេសម្ចាស់គំរោង មានសារៈសំខាន់ខ្លាំងណាស់ នៅក្នុងការកំណត់សិទ្ធិអនុវត្តគំរោងដែលបានស្នើនៅក្រោមគំរោង CDM ។ ប្រទេសមួយចំនួនកំណត់លក្ខណៈវិនិច្ឆ័យនៃការអភិវឌ្ឍប្រកបដោយចីរភាពបានយ៉ាងច្បាស់លាស់ ហើយ DNAs ខ្លះមានបញ្ជីមួយស្តីអំពីប្រភេទគំរោងអាទិភាព CDM ។ អ្នករៀបចំគំរោងក៏គួរកំណត់នៅត្រង់ដំណាក់កាលនេះផងដែរ ថាតើសកម្មភាពគំរោងដែលបានស្នើនោះមានទំហំធំ ឬទំហំតូច ព្រោះលក្ខខណ្ឌផ្សេងគ្នាអាចយកមកអនុវត្ត ដើម្បីបំពេញលក្ខខណ្ឌសកម្មភាពគំរោងខ្នាតតូច (UNFCCC 2002 កថាខ័ណ្ឌ 9, 20) ដូចជា :

- ឯកសារប្លង់គំរោង (PDD) ដែលងាយយល់ (រួមទាំងការធ្វើតេស្តលើផលបន្ថែម)
- កំណត់ជាមុនវិធីសាស្ត្រគោល ដែលងាយស្រួលយល់ ដោយបែងចែកទៅតាមប្រភេទគំរោង
- ផែនការពិនិត្យតាមដានដែលងាយស្រួលយល់
- លទ្ធភាពជួលស្ថាប័នប្រតិបត្តិការតែមួយដដែល សំរាប់ការផ្តល់សុពលភាព ការផ្ទៀងផ្ទាត់ និងការបញ្ជាក់
- កាត់បន្ថយការបង់ប្រាក់ដល់ UNFCCC ដើម្បីរ៉ាប់រងលើចំណាយរដ្ឋបាល និងថ្លៃចុះបញ្ជីការ (UNFCCC 2002 កថាខ័ណ្ឌ 21, 220)
- ពន្លឿនរយៈពេលនៃការវាយតំលៃលើការចុះបញ្ជីការធម្មតា (រយៈពេលចុះបញ្ជីការសំរាប់គំរោងធម្មតាគឺ 8 សប្តាហ៍ បន្ទាប់ពីថ្ងៃទទួលការស្នើសុំចុះបញ្ជីការ) (UNFCCC 2002 កថាខ័ណ្ឌ 24, 23) ។

---

6. កិច្ចព្រមព្រៀងម៉ារ៉ាកេស ត្រូវបានចុះហត្ថលេខានៅឯសន្និសីទនៃភាគីជាសមាជិក (COP) នៅក្នុងសម័យប្រជុំលើកទី 7 ដែលត្រូវបានរៀបចំឡើងនៅទីក្រុងម៉ារ៉ាកេស ប្រទេសម៉ារ៉ុក ក្នុងឆ្នាំ 2001 ។ កិច្ចព្រមព្រៀងនេះបានអនុម័តលើវិធានប្រតិបត្តិរបស់ពិធីសារក្យូតូជាច្រើន ហើយបានបង្កើតបែបបទ និងនីតិវិធីជាច្រើនសំរាប់ CDM (UNFCCC 2001b) ។

អ្នករៀបចំគំរោងជាច្រើនក៏ចាប់ផ្តើមស្វែងរកអ្នកទិញ CERs ដែលមានសក្តានុពលផងដែរ ។ ដើម្បីសំរួលដល់ការពិភាក្សា ពួកគេបង្កើតសេចក្តីសង្ខេបនៃការពិពណ៌នាគំរោង ដែលគេហៅថា ឯកសារគោលគំនិតគំរោង (PIN) ឬ ឯកសារផ្តើមគំនិតគំរោង (PCN)។ អង្គភាពអ្នកផ្តល់ជំនួយមួយចំនួន ដែលទិញ CERs មានបែបបទពាក្យសុំជាស្តង់ដាររបស់ពួកគេ ហើយអង្គភាពផ្សេងទៀតអាចប្រើប្រាស់បែបបទ PIN របស់ធនាគារពិភពលោក ឬបែបទ PCN ដែលផ្តល់ឱ្យដោយរដ្ឋាភិបាលប្រទេសម្ចាស់គំរោង ។

រូបភាពទី 3.3 ទិដ្ឋភាពទូទៅនៃវដ្តគំរោង CDM

| | |
|---|---|
| 1. ធ្វើផែនការសកម្មភាពគំរោង CDM មួយ | *អ្នកចូលរួមក្នុងគំរោង* គួរគិតថា<br>1. សកម្មភាពគំរោងដែលបានគ្រោង នឹងជួយឱ្យមានការអភិវឌ្ឍន៍ដោយចីរភាព នៅក្នុងប្រទេសម្ចាស់គំរោងឬទេ និង<br>2. សកម្មភាពគំរោងដែលបានគ្រោងគឺជាសកម្មភាពផលបន្ថែម |
| 2. រៀបចំឯកសារគំរោង (PDD) | *អ្នកចូលរួមក្នុងគំរោង* គួរ<br>1. ប្រើទំរង់ស្តង់ដារឯកសារប្លង់គំរោង PDD ពីវិបសាយរបស់ UNFCCC ហើយបំពេញទៅតាមសេចក្តីណែនាំ ដែលផ្តល់ឱ្យដោយ CDM EB |
| 3. ទទួលបានការអនុម័តពីភាគីដែលពាក់ព័ន្ធនីមួយៗ | *អ្នកចូលរួមក្នុងគំរោង* គួរ<br>1. ស្វែងយល់អំពីដំណើរការនៃការផ្តល់ការឯកភាពរបស់ភាគីដែលពាក់ព័ន្ធ និងលក្ខខណ្ឌទាំងអស់របស់អាជ្ញាធរជាតិដែលត្រូវបានចាត់តាំង (DNAs) និង<br>2. ទទួលបានការអនុម័តជាលាយលក្ខណ៍អក្សរនៃការចូលរួមដោយស្ម័គ្រចិត្តពី DNAs |
| 4. ការផ្តល់សុពលភាព និងការចុះបញ្ជីការ | *អ្នកចូលរួមក្នុងគំរោង* គួរ<br>1. ឱ្យមានការផ្តល់សុពលភាពធ្វើឡើង ដោយអង្គភាពប្រតិបត្តិការ ដែលត្រូវបានចាត់តាំង (DOE) ដែលទទួលស្គាល់ដោយ CDM EB និង<br>2. ចេញថ្លៃចុះបញ្ជីការទៅឱ្យ CDM EB<br>***DOE*** នឹងបញ្ជូនគ្រប់ឯកសារដែលចាំបាច់ទាំងអស់ទៅឱ្យ CDM EB និងសុំចុះបញ្ជីការគំរោង |
| 5. ការពិនិត្យតាមដានសកម្មភាពគំរោង CDM | *អ្នកចូលរួមក្នុងគំរោង* គួរ<br>(a) ពិនិត្យតាមដាន ទៅតាមផែនការពិនិត្យ ហើយរាយការណ៍ទៅកាន់អង្គភាពប្រតិបត្តិការ |
| 6. ការផ្ទៀងផ្ទាត់ និងការបញ្ជាក់ | *អង្គភាពប្រតិបត្តិការ* គួរ<br>1. ផ្ទៀងផ្ទាត់លទ្ធផលនៃការពិនិត្យតាមដាន និងបញ្ជាក់ពីចំនួនពិតប្រាកដនៃការកាត់បន្ថយការបញ្ចេញ GHG ដែលជាលទ្ធផលនៃសកម្មភាពគំរោង និង<br>2. រាយការណ៍ពីលទ្ធផលទៅកាន់ CDM EB |
| 7. ការចេញ CERs | ***CDM EB*** នឹង<br>1. ចេញចំនួន CERs ដែលបានបញ្ជាក់ ក្នុងរយៈពេល 15 ថ្ងៃ បន្ទាប់ពីបានទទួលសំណើសុំចេញ និង<br>2. កាត់ "ចំណែកចំណាយ" ចេញពី CERs ដែលបានចេញឱ្យ |

### 3.7.2 ការរៀបចំឯកសារប្លង់គំរោង

អ្នកស្នើគំរោងចាំបាច់ត្រូវរៀបចំឯកសារប្លង់គំរោង (PDD) ដើម្បីចុះបញ្ជីការជាសកម្មភាពគំរោង CDM បាន ។ PDD បង្ហាញព័ត៌មានទាក់ទងនឹងទិដ្ឋភាពបច្ចេកទេស និងទិដ្ឋភាពរចនាសម្ព័ន្ធរបស់សកម្មភាពគំរោង ហើយគឺជាព័ត៌មានយ៉ាងសំខាន់សំរាប់ការផ្តល់សុពលភាព ការចុះបញ្ជីការ និងការផ្ទៀងផ្ទាត់គំរោង ដូចដែលបានតំរូវនៅក្រោមកិច្ចព្រមព្រៀងម៉ារ៉ាកេស ។ នាពេលបច្ចុប្បន្ននេះ បែបបទផ្សេងៗ មានសំរាប់ប្រភេទគំរោងខាងក្រោម :

- សកម្មភាពគំរោងកាត់បន្ថយការបញ្ចេញ GHG ទំហំធំធម្មតា
- សកម្មភាពគំរោងកាត់បន្ថយការបញ្ចេញ GHG ទំហំតូច (អាចយកមកប្រើប្រាស់សំរាប់គ្រប់សកម្មភាពគំរោងទាំងអស់ លើកលែងតែការដាំព្រៃ/ការស្តារព្រៃឡើងវិញចេញ)
- សកម្មភាពគំរោងដាំព្រៃ/ស្តារព្រៃឡើងវិញ

សមាសភាគទូទៅនៃឯកសារប្លង់គំរោង រួមមាន (UNFCCC 2001b សេចក្តីបន្ថែម B 43-45)[7] :

- ការពិពណ៌នាជាទូទៅអំពីសកម្មភាពគំរោង
- វិធីសាស្ត្រគោល
- រយៈពេលអនុវត្តសកម្មភាពគំរោង/រយៈពេលផ្តល់ឥណទាន
- ការបង្ហាញហេតុផលសំរាប់ផលបន្ថែម
- វិធីសាស្ត្រ និងផែនការពិនិត្យតាមដាន
- ការគណនាការបញ្ចេញ GHG ពីប្រភពបញ្ចេញ
- ផលប៉ះពាល់មកលើបរិស្ថាន
- មតិយោបល់របស់អ្នកពាក់ព័ន្ធ ។

### 3.7.3 លក្ខខណ្ឌគោល

ការបង្កើត "សេណារីយ៉ូគោល" (ឬដែលគេតែងហៅថា "លក្ខខណ្ឌគោល") គឺជាផ្នែកមួយសំខាន់ណាស់នៅក្នុងការរៀបចំសកម្មភាពគំរោង CDM ។ លក្ខខណ្ឌគោលកំណត់ "មូលដ្ឋាន" ដើម្បីយកទៅធ្វើការគណនាបរិមាណនៃការកាត់បន្ថយការបញ្ចេញ GHG សុទ្ធ និងឥណទានកាបូន ។ សេណារីយ៉ូគោលពិពណ៌នាអំពីកំរិតនៃការបញ្ចេញ GHG នៅមុនពេលដាក់ឱ្យអនុវត្តសកម្មភាពគំរោង CDM ដែលបានស្នើ ។ ដូចដែលបានបង្ហាញនៅក្នុងរូបភាព 3.4 បរិមាណនៃការបញ្ចេញឧស្ម័នដែលបានកាត់បន្ថយ ឬចាប់យកនៅក្នុងព្រំដែនគំរោងប៉ុណ្ណោះដោយនៅក្នុងរយៈពេលផ្តល់ឥណទាន នឹងត្រូវបានចាត់ទុកថាជាការកាត់បន្ថយការបញ្ចេញឧស្ម័នដោយផ្ទាល់ ។

---

7. សៀវភៅមគ្គុទេសក៍នេះរៀបរាប់ដោយសង្ខេប អំពីគោលគំនិតរបស់លក្ខខណ្ឌគោល និង ផលបន្ថែម ប៉ុន្តែ សេចក្តីណែនាំពេញលេញ និងសេចក្តីលំអិតនៃលក្ខខណ្ឌសំរាប់ PDDs មានតាមរយៈវិបសាយ http://cdm.unfccc.int ។

រូបភាពទី 3.4 សេណារីយ៉ូគោល




សំរាប់សកម្មភាពគំរោងបន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទំហំធម្មតា កិច្ចព្រមព្រៀងម៉ារ៉ាកេសអនុញ្ញាតឱ្យរៀបចំលក្ខខណ្ឌគោលសំរាប់គំរោងនេះ ដោយប្រើប្រាស់វិធីមួយ ក្នុងចំណោមវិធីទាំង 3 ដូចខាងក្រោមនេះ (UNFCCC 2001b កថាខ័ណ្ឌ 48, 37)[8] :

1. ការបញ្ចេញឧស្ម័នជាក់ស្តែងមានស្រាប់ ឬដែលធ្លាប់មានកាលពីមុន
2. ការបញ្ចេញឧស្ម័នពីបច្ចេកវិទ្យាមួយ ដែលតំណាងឱ្យសកម្មភាពទាក់ទាញផ្នែកសេដ្ឋកិច្ច ដោយគិតគូរទៅលើឧបសគ្គនានា ដែលធ្វើឱ្យរាំងស្ទះដល់ការវិនិយោគ
3. ការបញ្ចេញឧស្ម័នជាមធ្យមរបស់សកម្មភាពគំរោងស្រដៀងៗគ្នា ដែលបានអនុវត្តកាលពី 5 ឆ្នាំមុន នៅក្រោមស្ថានភាពសង្គម សេដ្ឋកិច្ច បរិស្ថាន និងបច្ចេកវិទ្យាស្រដៀងគ្នា ហើយការអនុវត្តការងារស្ថិតនៅក្នុងចំណោមគំរោងធំៗ 20 ភាគរយ នៃប្រភេទរបស់សកម្មភាពគំរោងទាំងនោះ ។

មានវិធីផ្សេងៗ ដើម្បីធ្វើការគណនាសេណារីយ៉ូគោល និងការកាត់បន្ថយការបញ្ចេញ GHG ។ អ្នករៀបចំគំរោងអាចស្នើសុំវិធីសាស្ត្រថ្មីមួយ ដើម្បីបង្កើតសេណារីយ៉ូគោល ឬប្រើប្រាស់វិធីសាស្ត្រស្តង់ដារ *(វិធីសាស្ត្ររួម)* ឬវិធីសាស្ត្រដែលត្រូវបានអនុម័តរួចទៅហើយ ។ រហូតដល់ខែមិថុនា ឆ្នាំ 2005 មានវិធីសាស្ត្ររួមចំនួន 3 និងវិធីសាស្ត្រដែលបានអនុម័តរួចទៅហើយចំនួន 22 (សូមមើលសេចក្តីបន្ថែមទី II) ។

ការកាត់បន្ថយការបញ្ចេញឧស្ម័ន និងលក្ខខណ្ឌគោល ត្រូវបានកំណត់ឡើងតាមរយៈការបង្កើតព្រំដែនគំរោង ដែលគ្របដណ្តប់ "រាល់ការបញ្ចេញឧស្ម័ន GHG ដោយសកម្មភាពមនុស្សពីប្រភពទាំងអស់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកចូលរួមក្នុងគំរោង ហើយមានសារៈសំខាន់ និងកើតឡើងយ៉ាងសមហេតុសមផលដោយសកម្មភាពគំរោង

8. ឯកសារនេះមាននៅលើវ៉ិបសាយ http://cdm.unfccc.int/Reference/COPMOP ។

CDM" (UNFCCC 2001b កថាខ័ណ្ឌ 52, 37) ។ អ្នករៀបចំគំរោងចាំបាច់ត្រូវពិនិត្យមើលថា តើមាន "ការលេចចេញការបញ្ចេញឧស្ម័ននៅកន្លែងដទៃទៀត" នៅក្នុងសកម្មភាពគំរោងដែលបានស្នើដែរឬទេ ។ *ការលេចចេញការបញ្ចេញឧស្ម័ននៅកន្លែងដទៃទៀត* គឺជាការបញ្ចេញ GHG ខាងក្រៅព្រំដែនគំរោង ដែល "អាចវាស់វែងបាន" និង "ដែលកើតឡើង" ដោយសារតែសកម្មភាពគំរោង (UNFCCC 2001b កថាខ័ណ្ឌ 52, 37) ។ ការកាត់បន្ថយការបញ្ចេញឧស្ម័ន GHG សរុបចាំបាច់ត្រូវតែដកចេញនូវការបញ្ចេញឧស្ម័ននៅកន្លែងដទៃទៀត ។

សំរាប់សកម្មភាពគំរោងខ្នាតតូច UNFCCC ផ្តល់នូវវិធីសាស្ត្រគោលងាយស្រួលយល់មួយ ដើម្បីសំរួលដល់អ្នករៀបចំគំរោងពីបន្ទុកដែលចែងលំអិតពីលក្ខខណ្ឌគោល និងថ្លៃចំណាយខ្ពស់ដែលពាក់ព័ន្ធ (សូមមើលសេចក្តីបន្ថែមទី 3) ។

សំរាប់សកម្មភាពគំរោងស្តារព្រៃនិងដាំព្រៃឡើងវិញសំរាប់ CDM អ្នកស្នើគំរោងអាចជ្រើសរើសវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រទាំង 3 ខាងក្រោមនេះ (UNFCCC 2001b កថាខ័ណ្ឌ 22, 21) :

i. "គំរោងដែលមានស្រាប់ ឬដែលធ្លាប់មាន ដូចជាការផ្លាស់ប្តូរដែលអាចអនុវត្តបាននៅក្នុងស្តុកកាបូន ក្នុងព្រំដែនគំរោង"[9]

ii. "ការផ្លាស់ប្តូរស្តុកកាបូននៅក្នុងអាងកាបូននៅក្នុងព្រំដែនគំរោង ពីការប្រើប្រាស់ដីដែលតំណាងឱ្យសកម្មភាពដែលមានភាពទាក់ទាញផ្នែកសេដ្ឋកិច្ច ដោយគិតគូរអំពីឧបសគ្គនានាដែលរារាំងដល់ការវិនិយោគ"

iii. "ការផ្លាស់ប្តូរស្តុកកាបូននៅក្នុងអាងស្តុកការបូន នៅក្នុងព្រំដែនគំរោង ពីការប្រើប្រាស់ដីដែលសមស្របជាងគេនៅពេលដែលគំរោងចាប់ផ្តើម" ។

ការគណនាការស្រូបយក GHG សុទ្ធ ដោយអាងស្រូបកាបូន ត្រូវបានបង្ហាញនៅក្នុងរូបភាព 3.5 ។

រូបភាពទី 3.5 សេណារីយ៉ូគោល និងការស្រូបយកឧស្ម័ន GHG ដោយអាងស្តុកកាបូន




---

9. អាងកាបូនគឺជាជីវម៉ាសលើដី ជីវម៉ាសក្រោមដី កំទេចមែកឈើ ឈើងាប់ និងកាបូនសរីរាង្គក្នុងដី (UNFCCC 2003 កថាខ័ណ្ឌ 1[a] 16) ។

រូបភាពទី 3.6 ពន្យល់ពីវិធីសាស្ត្រគោល ដើម្បីគណនាសម្រួប GHG សុទ្ធដោយសកម្មភាពគំរោង A/R CDM ។

រូបភាពទី 3.6 ការគណនាសម្រួបឧស្ម័ន GHG សុទ្ធដោយអាងស្រូបកាបូន

| | | | | | | |
|---|---|---|---|---|---|---|
| **<u>ការស្រូបយក GHG សរុប ជាក់សែង្ត ដោយអាងស្រូបកាបូន</u>**<br>ចំនួនសរុបនៃការផ្លាស់ប្តូរស្តុកកាបូនដែលអាចផ្ទៀងផ្ទាត់បាន នៅក្នុងអាងកាបូន នៅក្នុងព្រំដែនគំរោង ដកកំណើនការបញ្ចេញ GHGs ពីប្រភព ដោយសារតែការអនុវត្តសកម្មភាពគំរោង ។ | — | **<u>ការស្រូបយក GHG គោល សរុបដោយអាងស្រូបកាបូន</u>**<br>ចំនួនសរុបនៃការផ្លាស់ប្តូរស្តុកកាបូននៅក្នុងអាងកាបូន នៅក្នុងព្រំដែនគំរោង ដែលអាចកើតមានឡើង នៅពេលគ្មានសកម្មភាពគំរោង CDM ។ | — | **<u>ការលេចឧស្ម័ននៅខាងក្រៅព្រំដែនសកម្មភាពគំរោង</u>**<br>កំណើនការបញ្ចេញ GHG ពីប្រភព ដែលកើតឡើងនៅខាងក្រៅព្រំដែនសកម្មភាពគំរោងដែលអាចវាស់វែងបាន និងដែលកើតឡើងដោយសកម្មភាពគំរោង។ | = | ការស្រូបយកឧស្ម័ន GHG សុទ្ធដោយអាងស្តុកកាបូន |

*ប្រភព : UNFCCC 2003, កថាខ័ណ្ឌ 1(f), 16*

សំរាប់សកម្មភាពគំរោងដាំព្រៃ និងស្តារព្រៃឡើងវិញខ្នាតតូច ក្រុមប្រឹក្សាប្រតិបត្តិយន្តការអភិវឌ្ឍន៍ស្អាត (EB) នឹងបង្កើតលក្ខខណ្ឌគោលងាយយល់សំរាប់សកម្មភាពខាងក្រោមនេះ (UNFCCC 2004, សេចក្តីបន្ថែម B កថាខ័ណ្ឌ 4, 38) :

ក. វាលស្មៅទៅជាដីព្រៃ

ខ. ដីដាំដុះទៅជាដីព្រៃ

គ. ដីសើមទៅជាដីព្រៃ

ឃ. ដីតាំងទីលំនៅទៅជាដីព្រៃ

### 3.7.4 ផលបន្ថែម (Additionality)

*ផលបន្ថែម (Additionality)* គឺជាទិដ្ឋភាពសំខាន់មួយទៀតរបស់គំរោង CDM ។ ផលបន្ថែមគឺជាការបង្ហាញហេតុផលថា សកម្មភាពគំរោង CDM ដែលបានស្នើ មិនមែនជាសេណារីយ៉ូគោលនោះទេ ។ ក្រុមប្រឹក្សាប្រតិបត្តិ CDM ដាក់ឱ្យប្រើប្រាស់ **ឯកសារផលបន្ថែម (additionality tools)** (រូបភាពទី 3.7) នៅឯកិច្ចប្រជុំលើកទី 16 របស់ខ្លួន (UNFCCC 2004b) ។ មិនមែនមានន័យថា ចាំបាច់ត្រូវតែប្រើឯកសារផលបន្ថែមនោះទេ ប៉ុន្តែគួរតែប្រើវា ។

រូបភាពទី 3.7 ការវាយតំលៃគំរោង ដោយប្រើមធ្យោបាយផលបន្ថែម

**ជំហាន 0 : ការពិនិត្យជំហានដំបូង ដោយផ្អែកទៅលើកាលបរិច្ឆេទចាប់ផ្តើមរបស់សកម្មភាពគំរោង**

- គំរោង ដែលត្រូវបានអនុវត្តមុនពេលចុះបញ្ជីការ* ហើយ មានភស្តុតាងគ្រប់គ្រាន់ ដើម្បីបង្ហាញថា CDM ត្រូវបានយកមកពិចារណា នៅពេលរៀបចំគំរោង → ***មើលតាមជំហានទី 1***
- គំរោង ដែលត្រូវបានអនុវត្តក្រោយពេលចុះបញ្ជីការ → ***មើលតាមជំហានទី 1***

↓

**ជំហាន 1 : ការកំណត់ជំរើសចំពោះសកម្មភាពគំរោង ដោយអនុលោមទៅតាមច្បាប់ និងបទបញ្ញត្តិនាពេលបច្ចុប្បន្ន**

- មានជំរើសដែលគួរឱ្យជឿជាក់ និងប្រាកដនិយមមួយចំនួន ចំពោះសកម្មភាពគំរោងដែលបានស្នើ នៅក្រោមលក្ខខណ្ឌច្បាប់ និងបទបញ្ញត្តិនាពេលបច្ចុប្បន្ន និងការអនុវត្តច្បាប់ → ***មើលតាមជំហានទី 2 ឬ 3***

↓

**ជំហាន 2 : ការវិភាគការវិនិយោគ**

វិធីសាស្ត្រ (ប្រើវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រខាងក្រោម):
- *ការវិភាគថ្លៃដើមសាមញ្ញ*
- *ការវិភាគការប្រៀបធៀបការវិនិយោគ (ដោយប្រើសូចនាករហិរញ្ញវត្ថុ)*
- *ការវិភាគចំនុចគោល (ប្រើចំនុចគោលសំរាប់សូចនាករហិរញ្ញវត្ថុ)*

ប្រសិនបើសកម្មភាពគំរោងដែលបានស្នើមានភាពទាក់ទាញផ្នែកសេដ្ឋកិច្ច ឬហិរញ្ញវត្ថុតិចជាង ជំរើសផ្សេងទៀត ដោយគ្មានចំណូលពីការលក់ CERs ។

→ ***មើលតាមជំហានទី 4***

**ជំហាន 3 : ការវិភាគឧបសគ្គរាំង**

ឧបសគ្គដែលអាចកើតមានឡើង (ឧទាហរណ៍)
- *ឧបសគ្គផ្នែកវិនិយោគ*
- *ឧបសគ្គផ្នែកបច្ចេកវិទ្យា*
- *ឧបសគ្គដោយសារតែការអនុវត្ត*
- *ឧបសគ្គដទៃទៀត*

សកម្មភាពគំរោងដែលបានស្នើរមានឧបសគ្គ ចំពោះការអនុវត្ត បើមិនបានចុះបញ្ជីការនៅក្រោម CDM ហើយឧបសគ្គដូចគ្នានេះនឹងមិនរាំងយ៉ាងហោចណាស់ ជំរើសចំនួនមួយ មិនឱ្យមានការអនុវត្ត ។

→ ***មើលតាមជំហានទី 4***

↓

**ជំហាន 4 : ការវិភាគការអនុវត្តរួម (បន្ថែមលើជំហាន 2 និង 3)**

- សកម្មភាពគំរោងដែលបានស្នើ ត្រូវបានបង្ហាញដោយភស្តុតាងឯកសារយ៉ាងគ្រប់គ្រាន់ថា វាមិនមានប្រភេទសកម្មភាពស្រដៀងគ្នា នៅក្នុងការអនុវត្តទេនោះ (ដូចជា ការប្រើបច្ចេកវិទ្យាថ្មី) → ***មើលតាមជំហានទី 5***
- សកម្មភាពគំរោងដែលបានស្នើ ត្រូវបានបង្ហាញដោយភស្តុតាងឯកសារយ៉ាងគ្រប់គ្រាន់ថា ពិបាកក្នុងការអនុវត្ត ដោយគ្មានការលើកទឹកចិត្ត CDM នៅក្នុងវត្តមានរបស់សកម្មភាពប្រភេទស្រដៀងគ្នារបស់សកម្មភាពគំរោង → ***មើលតាមជំហានទី 5***

↓

**ជំហាន 5 : ផលប៉ះពាល់នៃការចុះបញ្ជីការ CDM**

- មានការពន្យល់ដោយពេញចិត្តថា ការឯកភាព និងការចុះបញ្ជីការសកម្មភាពគំរោងអាចលុបបំបាត់ ឬកាត់បន្ថយឧបសគ្គនៅក្នុងជំហាន 2 ឬ 3 ។

→ **សកម្មភាពគំរោង ដែលបានស្នើ CDM គឺជាផលបន្ថែម ។**

*គំរោង ដែលត្រូវបានជ្រើសរើសក្រោយថ្ងៃទី 1 មករា 2000 អាចនៅតែយកមកពិចារណាថាជាគំរោង CDM ។

សំរាប់សកម្មភាពគំរោងខ្នាតតូច អ្នកស្នើគំរោងចាំបាច់ត្រូវបង្ហាញហេតុផលលើផលបន្ថែមរបស់ខ្លួន ដោយប្រើយ៉ាងហោចណាស់នូវឧបសគ្គមួយដែលបានរៀបរាប់នៅក្នុងតារាង 3.3 ។

តារាងទី 3.3 លក្ខណៈវិនិច្ឆ័យសំរាប់ការបង្ហាញហេតុផលលើផលបន្ថែមសំរាប់សកម្មភាពគំរោង CDM ខ្នាតតូច

| | |
|---|---|
| ឧបសគ្គផ្នែកការវិនិយោគ | ជំរើសដែលអាចផ្តល់ផលចំណេញផ្នែកហិរញ្ញវត្ថុច្រើនជាងចំពោះសកម្មភាពគំរោង អាចបង្កឱ្យមានការបញ្ចេញឧស្ម័នកាន់តែច្រើនជាងមុន ។ |
| ឧបសគ្គផ្នែកបច្ចេកវិទ្យា | ជំរើសដែលមិនសូវមានបច្ចេកវិទ្យាទំនើប ចំពោះសកម្មភាពគំរោងដែលមានហានិភ័យតិច ដោយសារតែភាពមិនប្រាកដប្រជាផ្នែកអនុវត្តន៍ការងារ ឬចំណែកទីផ្សារទាបនៃបច្ចេកវិទ្យាថ្មី ដែលយកមកអនុវត្តសំរាប់សកម្មភាពគំរោង ហើយអាចបង្កឱ្យមានការបញ្ចេញឧស្ម័នកាន់តែច្រើនជាងមុន ។ |
| ឧបសគ្គដោយសារតែការអនុវត្តទូទៅ | ការអនុវត្តទូទៅ ឬលក្ខខណ្ឌគោលនយោបាយ ឬបទបញ្ញត្តិដែលមានស្រាប់ អាចនាំទៅដល់ការប្រើប្រាស់បច្ចេកវិទ្យា ដែលមានការបញ្ចេញឧស្ម័នខ្ពស់ជាង ។ |
| ឧបសគ្គដទៃទៀត | ក្នុងករណីពុំមានសកម្មភាពគំរោង - សំរាប់មូលហេតុមួយផ្សេងទៀត ដែលបានកំណត់ដោយអ្នកចូលរួមក្នុងគំរោង ដូចជាឧបសគ្គផ្នែកស្ថាប័ន ច្បាប់ ឬព័ត៌មាន ធនធានគ្រប់គ្រង សមត្ថភាពអង្គភាព ធនធានហិរញ្ញវត្ថុ ឬសមត្ថភាពនៅមានកំរិត ដើម្បីទទួលយកបច្ចេកវិទ្យាថ្មី - ការបញ្ចេញឧស្ម័នអាចកាន់តែមានកំរិតខ្ពស់ ។ |

*ប្រភព : UNFCCC 2002, កថាខ័ណ្ឌ B, ឯកសារអម A, 26; UNFCCC CDM EB 7, 19*

### 3.7.5 ការទទួលបានការអនុម័តពីប្រទេសម្ចាស់គំរោង

អ្នកលើកគំរោង CDM ចាំបាច់ត្រូវទទួលបានការអនុម័តជាលាយលក្ខណ៍អក្សរពី DNA នៃប្រទេសម្ចាស់គំរោង ដើម្បីចុះបញ្ជីការគំរោងរបស់ពួកគេជាមួយនឹងក្រុមប្រឹក្សាប្រតិបត្តិ CDM ។ ជាទូទៅ "ប្រទេសម្ចាស់គំរោង" គឺសំដៅទៅលើទាំងប្រទេសនៅក្នុងឧបសម្ព័ន្ធទី 1 និងប្រទេសដែលមិនស្ថិតនៅក្នុងឧបសម្ព័ន្ធទី 1 ។ ទោះជាយ៉ាងណាក៏ដោយ គំរោងមួយអាចនៅតែចុះបញ្ជីការជាគំរោង CDM ដោយពុំចាំបាច់មានប្រទេសក្នុងឧបសម្ព័ន្ធទី 1 ចូលរួម នៅពេលចុះបញ្ជីទេ (UNFCCC CDM EB 2005a កថាខ័ណ្ឌ 57, 8) ។ គំរោងប្រភេទនេះគេហៅថាគំរោង CDM "ឯកតោភាគី" ខុសពីគំរោង CDM "ទ្វេរភាគី" (មានការចូលរួមពីប្រទេសក្នុងឧបសម្ព័ន្ធទី 1 ផង និងប្រទេសមិននៅក្នុងឧបសម្ព័ន្ធទី 1 ផង) ។ ទោះជាយ៉ាងនេះក៏ដោយ មិនមានន័យថា គំរោងឯកតោភាគីត្រូវបានលើកលែងទាំងស្រុងមិនឱ្យមានលិខិតអនុម័តគំរោងពី DNA របស់ប្រទេសក្នុងឧបសម្ព័ន្ធទី 1 នោះទេ ។ នៅពេលអ្នករៀបចំគំរោងឯកតោភាគីបានរកឃើញអ្នកទិញ CERs ពីប្រទេសក្នុងឧបសម្ព័ន្ធទី 1 រួចហើយ ហើយស្នើឱ្យក្រុមប្រឹក្សាប្រតិបត្តិ CDM ផ្ទេរ CERs ទៅកាន់ដៃគូរបស់ខ្លួន ក្រុមប្រឹក្សាប្រតិបត្តិ CDM នឹងតំរូវឱ្យមានលិខិតអនុម័តពីប្រទេសក្នុងឧបសម្ព័ន្ធទី 1 ដែលចូលរួមក្នុងគំរោង ។ លិខិតអនុម័តគួរមានដាក់បញ្ចូលសេចក្តីថ្លែងខាងក្រោម ដោយអនុលោមទៅតាមលក្ខខណ្ឌដែលបានកំណត់នៅក្រោម UNFCCC (UNFCCC 2005b កថាខ័ណ្ឌ 29, 32; UNFCCC CDM EB 2004 c, 1) ៖

- ប្រទេសនោះបានផ្តល់សច្ចាប័នទៅលើពិធីសារក្យូតូ

- ស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតត្រូវបញ្ជាក់ថា សកម្មភាពគំរោង CDM ដែលបានស្នើឡើង កើត ឡើងដោយសារការចូលរួមដោយស្ម័គ្រចិត្ត
- (សំរាប់តែប្រទេសដែលជាម្ចាស់គំរោងប៉ុណ្ណោះ) សកម្មភាពគំរោង CDM ដែលបានស្នើឡើងនឹងចូលរួម ចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព ។

បើទោះបីជាប្រទេសនីមួយៗដែលចូលរួមក្នុងគំរោង CDM ចាំបាច់ត្រូវបង្កើត DNA សំរាប់ CDM និងបង្ហាញ ពីនីតិវិធី និងភាពចាំបាច់ដើម្បីអនុម័តគំរោងក៏ដោយ ក៏នៅមានប្រទេសមួយចំនួនកំពុងស្ថិតនៅក្នុងដំណើរការរៀបចំ និងបង្កើតវិធានទាំងនេះ ។ គួរកត់សំគាល់ថា ប្រទេសមួយចំនួនត្រូវការឯកសារគោលគោលគំនិតគំរោង (PCN) ឬ ឯកសារប្លង់គំរោង សំរាប់ផ្តល់ការអនុម័តពី DNA ។

### 3.7.6 ការផ្តល់សុពលភាព និងការចុះបញ្ជីការ

ការផ្តល់សុពលភាព គឺជាការវាយតំលៃឯករាជ្យទៅលើឯកសារប្លង់គំរោង ដោយប្រៀបធៀបជាមួយនឹងលក្ខខណ្ឌ របស់ UNFCCC (បែបបទ និងនីតិវិធី CDM កថាខ័ណ្ឌ 34 ទំព័រទី 34) ។ ក្រុមប្រឹក្សាភិបាល CDM ផ្តល់ អំណាចទៅឱ្យអង្គភាពភាគីទី 3 ដែលគេស្គាល់ថាជា អង្គភាពប្រតិបត្តិការដែលបានចាត់តាំង (DOEs) ដើម្បីផ្តល់ សុពលភាពដល់ឯកសារប្លង់គំរោង (ប្រអប់ទី 3.4) ។ ការផ្តល់សុពលភាព រួមមានការពិនិត្យលើចំនុចខាងក្រោម នេះ[10] :

- លក្ខខណ្ឌនៃការចូលរួមត្រូវបានបំពេញយ៉ាងពេញលេញ (ដូចជា ការចូលរួមដោយស្ម័គ្រចិត្ត ការបង្កើត DNA រួចជាស្រេច និងជាភាគីនៃពិធីសារក្យូតូ)
- យោបល់របស់អ្នកពាក់ព័ន្ធត្រូវបានជំរុញឱ្យមានសង្ខេប និងយកមកធ្វើការពិចារណា
- ការវិភាគ ឬការវាយតំលៃលើហេតុប៉ះពាល់បរិស្ថាន ត្រូវបានធ្វើឡើង ស្របទៅតាមលក្ខខណ្ឌរបស់ប្រទេស ម្ចាស់គំរោង
- ការកាត់បន្ថយការបញ្ចេញ GHG គឺជាផលបន្ថែម
- វិធីសាស្ត្រពិនិត្យតាមដាន និងលក្ខខណ្ឌគោលដែលបានអនុម័ត ត្រូវបានយកមកប្រើប្រាស់ ឬវិធីសាស្ត្រថ្មី មួយត្រូវបានដាក់ស្នើ ដើម្បីសុំការអនុម័ត
- សកម្មភាពគំរោងដែលបានស្នើ អនុលោមទៅតាមគ្រប់លក្ខខណ្ឌទាំងអស់ផ្សេងៗទៀត និងសេចក្តីសំរេចនានា ដែលធ្វើឡើងដោយ COP/MOP និង CDM EB ។

10. DOEs ត្រូវបានទទួលស្គាល់ជាលក្ខណៈច្បាប់ និងត្រូវបានចាត់តាំងដោយ CDM EB រហូតដល់ទទួលបានការបញ្ជាក់ពីកិច្ចប្រជុំនៃបណ្តាភាគី/ កិច្ចប្រជុំភាគីពិធីសារក្យូតូ (COP/MOP) ។

ប្រអប់ទី 3.3 អង្គភាពប្រតិបត្តិការដែលត្រូវបានចាត់តាំង

DOE គឺជាអង្គភាពភាគីទី 3 ដែលទទួលបានការអនុញ្ញាត ឱ្យធ្វើការផ្តល់សុពលភាព ឬការផ្ទៀងផ្ទាត់ និងការបញ្ជាក់លើសកម្មភាពគំរោង CDM (សំរាប់សេចក្តីលំអិតស្តីពីការផ្ទៀងផ្ទាត់ និងការបញ្ជាក់ សូមមើលវគ្គ 3.7.8) ។ សំរាប់សកម្មភាពគំរោងទំហំធម្មតា ត្រូវឱ្យមាន DOE ផ្សេងគ្នាមួយ ដើម្បីធ្វើការផ្តល់សុពលភាព និងការផ្ទៀងផ្ទាត់/ការបញ្ជាក់ ។ ទោះជាយ៉ាងណាក្តី បន្ទាប់ពីមានការស្នើសុំ CDM EB អាចផ្តល់ការអនុញ្ញាតឱ្យ DOE តែមួយធ្វើគ្រប់សកម្មភាពទាំងអស់ (UNFCCC 2002 កថាខ័ណ្ឌ 27[e], 32) ការផ្តល់ការអនុញ្ញាតនេះ ជាធម្មតា ផ្តល់ឱ្យតែចំពោះសកម្មភាពគំរោងខ្នាតតូចតែប៉ុណ្ណោះ (UNFCCC 2002 កថាខ័ណ្ឌ 9, 20)។ បញ្ជី DOEs មានតាមរយៈវិបសាយ http://cdm.unfccc.int/DOE/list ។ អ្នកអានគួរដឹងថា DOEs អាចធ្វើការផ្តល់សុពលភាព ឬការផ្ទៀងផ្ទាត់/ការបញ្ជាក់សំរាប់សកម្មភាពគំរោង នៅក្រោមវិសាលភាពតាមវិស័យ ដែលត្រូវបានអនុញ្ញាត (សូមមើលវិបសាយ http://cdm.unfccc.int សំរាប់បញ្ជីប្រភេទវិសាលភាពតាមវិស័យ) ។

DOE រៀបចំរបាយការណ៍នៃការផ្តល់សុពលភាព រួចដាក់ជូន CDM EB ដោយភ្ជាប់ជាមួយនឹង PDD លិខិតអនុម័តពីប្រទេសម្ចាស់គំរោង និងការពន្យល់ពីរបៀបដែលមតិនានាត្រូវបានយកមកធ្វើការពិចារណា ដើម្បីស្នើសុំការចុះបញ្ជីការ ។ ការចុះបញ្ជីការត្រូវឱ្យមានការចំណាយលើថ្លៃរដ្ឋបាល អាស្រ័យទៅតាមទំហំសកម្មភាពគំរោង (សូមមើលតារាងទី 3.4) ។ បន្ទាប់ពីមានការបញ្ជាក់ថាបានទទួលការបង់ថ្លៃសំរាប់ការចុះបញ្ជីការ និងឯកសារដែលត្រូវបានបំពេញរួចរាល់អស់ហើយនោះ CDM EB ដាក់របាយការណ៍ផ្តល់សុពលភាព និង PDD របស់សកម្មភាពគំរោងលើវិបសាយ UNFCCC ដើម្បីសុំមតិយោបល់របស់សាធារណៈជន ។ ប្រសិនបើពុំមានការរៀបចំតាមរយៈការស្នើសុំឱ្យមានការពិនិត្យឡើងវិញ ពីភាគីដែលចូលរួមនោះទេ ឬយ៉ាងហោចណាស់សមាជិកចំនួន 3 រូបរបស់ CDM EB ទេនោះ សកម្មភាពគំរោងដែលបានស្នើអាចចុះបញ្ជីការ ក្នុងរយៈពេល 8 សប្តាហ៍សំរាប់សកម្មភាពគំរោង CDM ទំហំធម្មតា និងរយៈពេល 4 សប្តាហ៍ សំរាប់សកម្មភាពគំរោង CDM ខ្នាតតូច (UNFCCC 2001b, 34-36) ។

តារាងទី 3.4 ថ្លៃចុះបញ្ជីការសំរាប់គំរោង CDM

| ទំហំ CERs ដែលបង្កើតឡើងជារៀងរាល់ឆ្នាំ ( គិតជាតោននៃ $CO_2$ ) | ថ្លៃ (USD) |
|---|---|
| < = 15.000 | 5.000 |
| > 15.000 និង < = 50.000 | 10.000 |
| > 50.000 និង < = 100.000 | 15.000 |
| > 100.000 និង < = 200.000 | 20.000 |
| > 200.000 | 30.000 |

*ប្រភព : UNFCCC CDM EB 2002*

### 3.7.7 ការពិនិត្យតាមដានសកម្មភាពគំរោង CDM

អ្នកលើកគំរោង ត្រូវពិនិត្យតាមដានការកាត់បន្ថយការបញ្ចេញឧស្ម័ន ឬការស្រូបកាបូនជាក់ស្តែង ដែលកើតឡើង នៅពេលអនុវត្តគំរោង ។ ការពិនិត្យតាមដាន រួមមាន "ការប្រមូល និងការចងក្រងគ្រប់ទិន្នន័យពាក់ព័ន្ធទាំងអស់ដែលចាំបាច់ សំរាប់ការកំណត់លក្ខខណ្ឌគោល ការវាស់វែងការបញ្ចេញឧស្ម័នដោយសកម្មភាពមនុស្ស ពីប្រភពឧស្ម័នផ្ទះកញ្ចក់ (GHG) នៅក្នុងព្រំដែនគំរោងរបស់សកម្មភាពគំរោង CDM និងការបញ្ចេញឧស្ម័ននៅកន្លែងផ្សេងទៀត ដែលពាក់ព័ន្ធ " (UNFCCC 2005b, 10) ។ ដូច្នេះ ផែនការពិនិត្យតាមដាន ចាំបាច់ត្រូវមានការឯកភាពពី CDM EB មុនពេលចុះបញ្ជីការ ។ ដូចគ្នានឹងវិធីសាស្រ្តគោលផងដែរ មានវិធីសាស្រ្តពិនិត្យតាមដាន ដែលត្រូវបានឯកភាព និងវិធីសាស្រ្តពិនិត្យតាមដានងាយៗ សំរាប់សកម្មភាពគំរោងខ្នាតតូច ។

សំរាប់សកម្មភាពគំរោង A/R CDM ទំហំធម្មតា ទិន្នន័យដែលបានប្រមូល និងចងក្រងទុក គួរអាចកំណត់ពីការស្រូបយក GHG សរុបជាក់ស្តែង ដោយអាងស្រូបកាបូន ។ នេះមានន័យថា ជាដំបូងផែនការពិនិត្យឃ្លាំមើលគួរកំណត់បច្ចេកទេស និងវិធីសាស្រ្តនានា ដែលអាចយកមកប្រើប្រាស់ សំរាប់ការធ្វើប៉ាន់គំរូ និងគណនាអាងកាបូននីមួយៗ និងការបញ្ចេញ GHG ពីប្រភព ។ សំរាប់សកម្មភាពគំរោង A/R CDM ខ្នាតតូច លក្ខខណ្ឌពិនិត្យតាមដានដែលត្រូវបានសម្រាយឱ្យងាយស្រួលយល់ នឹងត្រូវបង្កើតឡើងដោយ CDM EB ហើយផ្សព្វផ្សាយឱ្យយល់ដឹងជាសាធារណៈ (UNFCCC 2004, សេចក្តីបន្ថែម B, កថាខ័ណ្ឌ 4, 38) ។

### 3.7.8 ការផ្ទៀងផ្ទាត់ និងការបញ្ជាក់

បន្ទាប់ពីការកាត់បន្ថយការបញ្ចេញ GHG ជាក់ស្តែងត្រូវបានពិនិត្យ និងរាយការណ៍ទៅឱ្យ DOE ដោយអ្នកលើកគំរោងរួចហើយ DOE ធ្វើសកម្មភាពផ្ទៀងផ្ទាត់ខាងក្រោមនេះ ដើម្បីបញ្ជាក់ពីភាពពិតប្រាកដរបស់របាយការណ៍ ។ DOE ធ្វើសកម្មភាពខាងក្រោមនេះ នៅក្រោមការពិនិត្យផ្ទៀងផ្ទាត់ (UNFCCC 2001b កថាខ័ណ្ឌ 62 [a–g], 39):

- ពិនិត្យមើលថា តើរបាយការណ៍ពិនិត្យតាមដាន បំពេញទៅតាមលក្ខខណ្ឌរបស់ PDD ដែលបានចុះបញ្ជីដែរឬទេ
- ពិនិត្យមើលថា តើវិធីសាស្ត្រពិនិត្យតាមដាន ត្រូវបានប្រើប្រាស់បានយ៉ាងត្រឹមត្រូវដែរឬទេ
- មានការចុះពិនិត្យនៅនឹងកន្លែង ឬស្នើសុំព័ត៌មានបន្ថែមពីអ្នកលើកគំរោង បើចាំបាច់
- ផ្តល់អនុសាសន៍ ទៅឱ្យអ្នកលើកគំរោង សំរាប់ការពិនិត្យឡើងវិញលើវិធីសាស្ត្រពិនិត្យតាមដាននានា សំរាប់រយៈពេលផ្តល់ឥណទានពេលអនាគត
- កំណត់ការកាត់បន្ថយការបញ្ចេញ GHG ជាក់ស្តែង ពីសកម្មភាពគំរោង CDM

DOE រៀបចំរបាយការណ៍ផ្ទៀងផ្ទាត់ និងរបាយការណ៍បញ្ជាក់ ដែលរបាយការណ៍ទាំង 2 នេះនឹងផ្សព្វផ្សាយជាសាធារណៈ ។ របាយការណ៍បញ្ជាក់ រៀបរាប់អំពីបរិមាណកាត់បន្ថយការបញ្ចេញ GHG ដែលបានផ្ទៀងផ្ទាត់ហើយ ។

### 3.7.9 ការចេញ CERs

បន្ទាប់ពី CDM EB ទទួលបានការស្នើសុំឱ្យចេញ CERs រួចហើយ CDM EB ចេញបរិមាណ CERs ដែលបានបញ្ជាក់ ក្នុងរយៈពេល 15 ថ្ងៃ ប្រសិនបើភាគីដែលពាក់ព័ន្ធនៅក្នុងសកម្មភាពគំរោង ឬយ៉ាងហោចណាស់សមាជិកចំនួន 3 របស់ CDM EB មិនស្នើឱ្យមានការពិនិត្យឡើងវិញទេនោះ ។ បរិមាណ CERs សុទ្ធ បន្ទាប់ពីកាត់ "ចំណែកប្រាក់ចំណាយ" សំរាប់បន្សាំ [ទៅនឹងការប្រែប្រួលអាកាសធាតុ] និងចំណាយរដ្ឋបាលរួចហើយ[11] ត្រូវទុកនៅក្នុងគណនីមួយយ៉ាងសមស្រប នៃការិយាល័យចុះបញ្ជីគំរោង CDM ក្រោមការគ្រប់គ្រងរបស់ CDM EB ។ ថ្លៃចំណាយសំរាប់បន្សាំគឺ 2% នៃចំនួន CERs ដែលបានចេញឱ្យ (UNFCCC 2001b កថាខ័ណ្ឌ 15, 23) ខណៈពេលដែលភាគរយនៃថ្លៃចំណាយសំរាប់ការងាររដ្ឋបាល នៅពុំទាន់បានកំណត់នៅឡើយ ។ គំរោង CDM ខ្នាតតូច អាចទទួលបានអត្ថប្រយោជន៍ពីកំរិតទាបជាងនៃចំណែកប្រាក់ចំណាយ បើប្រៀបធៀបទៅនឹងគំរោង CDM ទំហំធម្មតា (UNFCCC 2002 កថាខ័ណ្ឌ 21, 22) ។ គំរោង A/R ត្រូវបានលើកលែងចំណែកបង់ថ្លៃចំណាយលើបន្សាំ (UNFCCC 2004, (d), 26) ។

11. មាត្រា 12 កថាខ័ណ្ឌ 8 នៃពិធីសារក្យូតូ (UNFCCC 1997) ចែងថា "ចំណែកប្រាក់ចំណាយពីសកម្មភាពគំរោងដែលបានបញ្ជាក់ត្រូវបានប្រើប្រាស់ ដើម្បីរ៉ាប់រងចំណាយរដ្ឋបាល និងដើម្បីជួយភាគីប្រទេសកំពុងអភិវឌ្ឍ ដែលងាយរងគ្រោះជាពិសេស ចំពោះផលប៉ះពាល់អវិជ្ជមាន ដើម្បីបំពេញចំណាយលើសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ" ។

# 4. សក្តានុពលសំរាប់គំរោង CDM នៅក្នុងប្រទេសកម្ពុជា

ជំពូកនេះពិពណ៌នាអំពីសក្តានុពលសំរាប់ការអភិវឌ្ឍគំរោង CDM នៅក្នុងវិស័យថាមពល និងព្រៃឈើ របស់ប្រទេសកម្ពុជា ។ ផ្នែកទីមួយរៀបរាប់ដោយសង្ខេបអំពីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ ហើយផ្នែកទីពីរបង្ហាញពីការវាយតំលៃលើសក្តានុពលសំរាប់គំរោង CDM ក្នុងវិស័យថាមពល តាមប្រភេទធនធានដែលមាន ។ លើកលែងតែថាមពលវារីអគ្គិសនីចេញ រហូតមកដល់សព្វថ្ងៃនេះ ការធ្វើការកំណត់គំរោងនៅមានកំរិត ។ ទាំងនេះនឹងតំរូវឱ្យអ្នករៀបចំគំរោង CDM ធ្វើកិច្ចការកំណត់គំរោងកាន់តែជាក់លាក់បន្ថែមទៀត ។ ផ្នែកទីពីររៀបរាប់ពីនិន្នាការនៃការកាប់ព្រៃឈើ និងការជាប់ទាក់ទិនរបស់វា សំរាប់សកម្មភាពដាំព្រៃ/ស្តារព្រៃ ដែលអាចធ្វើបាន ដូចជាការដាំដើមឈើជាទ្រង់ទ្រាយធំ និងព្រៃសហគមន៍ខ្នាតតូច ជាដើម ។

## *4.1 សេចក្តីសង្ខេបនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងប្រទេសកម្ពុជា*

សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិឆ្នាំ 1994 បានបង្ហាញថា ប្រទេសកម្ពុជាបានស្រូបយកឧស្ម័នផ្ទះកញ្ចក់ គិតជាសមមូលឧស្ម័នកាបូនិច ($CO_2e$) ចំនួន 59.708 ហ្គីហ្គាក្រាម (Gg) ហើយបញ្ចេញឧស្ម័នផ្ទះកញ្ចក់ គិតជា $CO_2e$ ចំនួន 64.850 ។ ដូច្នេះ នៅក្នុងឆ្នាំ 1994 កម្ពុជា គឺជាប្រទេសអាងស្រូបកាបូនមួយ ដោយបានស្រូបយកកាបូនសរុបចំនួន 5.142 Gg គិតជា $CO_2e$ ។

ប្រភពសំខាន់នៃការបញ្ចេញឧស្ម័ន $CO_2$ គឺវិស័យការផ្លាស់ប្តូរការប្រើប្រាស់ដី និងព្រៃឈើ (LUCF: 97%) បន្ទាប់មកគឺវិស័យថាមពល (3%) ។ ការរួមចំណែកពីវិស័យឧស្សាហកម្មសរុបក្នុងការបញ្ចេញឧស្ម័ន $CO_2$ មានតិចតួច ។ សមត្ថភាពនៃវិស័យការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ ដើម្បីស្រូបយកឧស្ម័ន $CO_2$ គឺ 43% ខ្ពស់ជាងការបញ្ចេញឧស្ម័ន $CO_2$ ពីវិស័យការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ ។ ដូច្នេះសរុបមក វិស័យនេះអាចទូទាត់ការបញ្ចេញ GHGs ទាំងអស់ពីវិស័យផ្សេងៗទៀត ។ ការបញ្ចេញឧស្ម័ន $CO_2$ ពីវិស័យការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ មានប្រហែល 45.214 Gg វិស័យថាមពលប្រហែល 1.272 Gg និងវិស័យឧស្សាហកម្មប្រហែល 50 Gg ហើយការស្រូបដោយវិស័យការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ គឺ 64.850 Gg ។

ការបញ្ចេញមេតាន ($CH_4$) មានប្រហែល 445 Gg ដែលក្នុងនោះ 76% ចេញពីវិស័យកសិកម្ម 17% ចេញពីវិស័យការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ 5% ពីថាមពល និង 2% ពីការគ្រប់គ្រងសំណល់ ។ ការបញ្ចេញ $CH_4$ ពីវិស័យកសិកម្មច្រើនមកពីការចិញ្ចឹមសត្វក្នុងស្រុក (54%) និងដំណាំស្រូវ (44%) ។ ការបញ្ចេញឧស្ម័នឌីអាសូតម៉ូណូអុកស៊ីត ($N_2O$) សរុបប្រហែល 12 Gg ច្រើនចេញពីដីកសិកម្ម (64%) និងការចិញ្ចឹមសត្វ (35%) នៅក្នុងវិស័យកសិកម្ម ។ ដោយធ្វើការបំលែងបរិមាណនៃការបញ្ចេញ $CH_4$ និង $N_2O$ ឱ្យទៅជាសក្តានុពលនៃកំណើនកំដៅ

សកល (GWP) ដែលគិតជាសមមូលឧស្ម័នកាបូនិច $CO_2$ e[12] ការបញ្ចេញឧស្ម័នកាបូនិចមាន 74% ឧស្ម័នមេតានមាន 18% និង $N_2O$ មាន 8% នៃការបញ្ចេញ GHG សរុប (សូមមើលរូបភាពទី 4.1) ។

រូបភាព 4.1 ចំណែកនៃការបញ្ចេញ GHGs ធំៗទាំងបី (A) និង ការញ្ចេញ $CO_2$e សរុប (B) តាមវិស័យ




## *4.2 សក្តានុពលសំរាប់គំរោង CDM នៅក្នុងវិស័យថាមពល*

### 4.2.1 ទិដ្ឋភាពទូទៅ

ក្រៅពីជីវម៉ាស ប្រទេសកម្ពុជាមានប្រភពថាមពលមិនមែននុយក្លេអ៊ែរមួយចំនួនតូច ដែលមានស្រាប់នៅក្នុងប្រទេស និងមួយចំនួនតូចទៀត កំពុងត្រូវបានរុករក ។ ថាមពលឈើតំណាងឱ្យជាង 80% នៃការប្រើប្រាស់ថាមពលជាតិសរុប (MIME 1997) ។ ប្រទេសនេះអាស្រ័យស្ទើរតែទាំងស្រុង លើការនាំចូលឥន្ធនៈផូស៊ីល ដូចជាប្រេងម៉ាស៊ូត និងប្រេងខ្មៅ សំរាប់ការផលិតថាមពលអគ្គិសនី ។ ការស្រាវជ្រាវរុករកប្រេង និងឧស្ម័នធម្មជាតិ នៅក្នុងដែនសមុទ្រ ត្រូវបានធ្វើឡើងក្នុងរយៈពេលជាង 10 ឆ្នាំ នេះដោយទទួលបានជោគជ័យផង និងបរាជ័យជាច្រើនផង ។ ការខួងសាកល្បងបានបង្ហាញពីសក្តានុពលនៃឧស្ម័នធម្មជាតិក្នុងសមុទ្រមានចំនួនច្រើន ប៉ុន្តែពុំទាន់បានកំណត់ នៅក្នុងដែនទឹករបស់កម្ពុជានៃឈូងសមុទ្រថៃ ។ ការទាញយកឧស្ម័ននៅក្នុងសមុទ្រ ដែលមានភាពចំណេញផ្នែកពាណិជ្ជកម្ម ប្រហែលជាមិនអាចសំរេចបាន យ៉ាងហោចណាស់នៅក្នុងរយៈពេល 5 ឆ្នាំទៀតឡើយ (Williamson et al 2004) ។

ជំរឿនប្រជាជនឆ្នាំ 1998 បានរាយការណ៍ថា ប្រជាពលរដ្ឋតិចជាង 15 ភាគរយ មានអគ្គិសនីប្រើប្រាស់ (NIS 1999) ។ ប្រទេសកម្ពុជាមានថ្លៃប្រើប្រាស់អគ្គិសនីខ្ពស់ជាងគេ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងកំរិតនៃការប្រើប្រាស់ទាបជាងគេ (ADB 2000a) ។ ថ្លៃអគ្គិសនីមានចាប់ពី 0.09 ដុល្លារ ក្នុងមួយគីឡូវ៉ាត់ម៉ោង (kWh) រហូតដល់ $0.53/kWh សំរាប់សេវាកម្មរដ្ឋ ហើយអាចខ្ពស់ជាងឆ្ងាយ សំរាប់បណ្តាញអគ្គិសនីខ្នាតតូច ដែលផ្គត់ផ្គង់

---

12. សក្តានុពលកំណើនកំដៅផែនដី (GWP) គិតជាហ្គីហ្គាក្រាមនៃការបញ្ចេញ $CO_2$e ក្នុងមួយ Gg នៃការបញ្ចេញ GHG ។ មេតានមាន 21 Gg ក្នុងមួយ Gg នៃ $CH_4$ ដែលបានបញ្ចេញ ។ ឧស្ម័នឌីអាសូតម៉ូណូអុកស៊ីតមាន 310 Gg ក្នុងមួយ Gg នៃ $N_2O$ ដែលបានបញ្ចេញ ។

សេវាកម្ម ដោយសហគ្រាសអគ្គិសនីជនបទ (REEs) (De Lopez 2003; Hundley 2003) ។ អ្នកផ្គត់ផ្គង់សេវាកម្មអគ្គិសនីធំជាងគេគឺអគ្គិសនីកម្ពុជា (EDC) ដែលជាក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីរដ្ឋ បើទោះបីជាក្រុមហ៊ុននេះអាចគ្របដណ្តប់ត្រឹមតែក្រុងភ្នំពេញ (អតិថិជន 100.000 នាក់) និងទីរួមខេត្តចំនួន 3 គឺក្រុងព្រះសីហនុ សៀមរាប និងកំពង់ចាម (EDC 2001) ក៏ដោយ ។ សមត្ថភាពប្រតិបត្តិការរបស់ក្រុមហ៊ុននេះ ត្រូវបានបង្កើនជាលំដាប់ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយដោយអនុលោមតាមលំនាំសកលនៃសេរីភាវូបនីយកម្មទីផ្សារថាមពល វិប្បធម៌នៃការគ្រប់គ្រង និងសាជីវកម្មរបស់ក្រុមហ៊ុននេះបានទទួលនូវការផ្លាស់ប្តូរឆ្ពោះទៅសំរេចគោលដៅរយៈពេលវែង នៃការក្លាយជាក្រុមហ៊ុនអគ្គិសនីដែលមានការប្រកួតប្រជែងគ្នា ។

ក្រៅពីតំបន់គ្របដណ្តប់របស់ EDC ម៉ាស៊ីនភ្លើងឯករាជ្យតូចៗ គឺជាអ្នកផលិតអគ្គិសនី ។ មាន REE ប្រហែលជាចំនួន 600 មានបណ្តាញអគ្គិសនីខ្នាតតូច ដើរដោយប្រេងម៉ាស៊ូត ដើម្បីផ្គត់ផ្គង់ថាមពលអគ្គិសនី ទៅឱ្យអតិថិជនប្រហែល 60.000 នាក់ (Meritec 2001) ។ មានហាងសាកអាគុយប្រហែលជា 8.000 ទៀត ផ្តល់សេវាកម្មទៅឱ្យសហគមន៍ជនបទ ។ ជាធម្មតា REE មានទំហំតូច ហើយជាអាជីវកម្មតាមមូលដ្ឋាន ដែលមានម៉ាស៊ីនភ្លើងប្រើប្រេងម៉ាស៊ូត ដែលបណ្តាញចែកចាយមានតង់ស្យុងទាប ។ ជាទូទៅ អ្នកផ្គត់ផ្គង់ថាមពលតូចៗទាំងនេះ ខ្វះខាតការប្រកាន់ខ្ជាប់ទៅតាមស្តង់ដាសុវត្ថិភាព និងបច្ចេកទេស មានការបាត់បង់ថាមពលតាមប្រព័ន្ធខ្ពស់ និងប្រើគ្រឿងឧបករណ៍នៅមានលក្ខណៈអន់ថយ ។ លើសពីនេះទៅទៀត ការផ្គត់ផ្គង់សេវាកម្មអគ្គិសនីដោយអ្នកផ្គត់ផ្គង់តាមមូលដ្ឋានទាំងនេះមានក៏រិតតែចំពោះកន្លែង ដែលអាចរកចំណេញបានខ្ពស់ (ADB និង NRECA 2002) តែប៉ុណ្ណោះ ។

យុទ្ធសាស្ត្រវិស័យថាមពលរបស់ប្រទេសកម្ពុជា ពីឆ្នាំ 1999 ដល់ 2016 ត្រូវបានបង្កើតឡើង ដោយមានការគាំទ្រពីធនាគារពិភពលោក (ធនាគារពិភពលោក និង HECEC1998) ។ នៅដំណាក់កាលទីមួយ នៃយុទ្ធសាស្ត្រនេះ ខ្សែបញ្ជូនដែលមានកំលាំង 220 វ៉ុល នឹងត្រូវតំឡើងពីព្រំដែនវៀតណាម មកទីក្រុងភ្នំពេញ ហើយដំណាក់កាលទីពីរមានការតំឡើងខ្សែបញ្ជូនពីប្រទេសថៃ មកខេត្តសៀមរាប (អង្គរវត្ត) តាមខេត្តកសិកម្មនៅផ្នែកខាងជើងរបស់កម្ពុជា ។ ដោយមានការផ្តល់មូលនិធិពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) រាជរដ្ឋាភិបាលកម្ពុជាកំពុងបន្តការអនុវត្តដំណាក់កាលទីមួយ ដែលគេរំពឹងថា នឹងត្រូវបានបញ្ចប់មុនឆ្នាំ 2007 (ធនាគារពិភពលោក និង HECEC 1998) ។

សក្តានុពលរបស់កម្ពុជា សំរាប់គំរោងថាមពលប្រកបដោយចីរភាព នៅក្រោម CDM ត្រូវបានវាយតំលៃតាមរយៈឯកសារ ដែលមានស្រាប់ (De Lopez 2003; Williamson et al. 2004) ។ របាយការណ៍ទាំងនេះសន្និដ្ឋានថា គំរោងថាមពលប្រកបដោយចីរភាពដែលជាទីសង្ឃឹមជាងគេនៅក្នុងប្រទេសកម្ពុជា គឺនៅក្នុងវិស័យថាមពលវារីអគ្គិសនី ជីវម៉ាស និងប្រសិទ្ធភាពថាមពល ។ ជាពិសេស គំរោងខ្នាតតូច ដែលមានសិទ្ធិប្រើវិធីសាស្ត្រងាយ ផ្តល់នូវសក្តានុពលធំជាងគេ សំរាប់ការកាត់បន្ថយការបញ្ចេញ GHG ហើយក្នុងពេលជាមួយគ្នានេះដែរ ចូលរួមចំណែកក្នុងការសំរេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ដោយចីរភាពរបស់ប្រទេស ។

### 4.2.2 សក្តានុពលសំរាប់គំរោង CDM នៅក្នុងវិស័យថាមពលវារីអគ្គិសនី

ធនាគារអភិវឌ្ឍន៍អាស៊ី បានប៉ាន់ប្រមាណថា ប្រទេសកម្ពុជាមានសក្តានុពលសំរាប់ការផលិតថាមពលវារីអគ្គិសនី ដែលមានសមត្ថភាពផលិតបានចំនួន 8.600 MW ហើយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) ប៉ាន់ប្រមាណថា មានចំនួន 10.000 MW (Hundley 2003) ។ បើយកតាមការប៉ាន់ប្រមាណរបស់ ADB ហើយដោយសន្មតថាមេគុណសមត្ថភាព (capacity factor) មានចំនួន 50 ភាគរយ នោះសក្តានុពលការផលិតអគ្គិសនីពីវារីអគ្គិសនីត្រូវបានគេប៉ាន់ប្រមាណថា មានចំនួន 37.668 GWh ក្នុងមួយឆ្នាំ ។ នេះគឺប្រហែលជា 70 ដង នៃទិន្នផលប្រចាំឆ្នាំរបស់ EDC ។ ប្រហែលជា 50 ភាគរយ នៃសមត្ថភាពសក្តានុពលនេះមានទីតាំងនៅលើទន្លេមេគង្គ 40 ភាគរយនៅតាមដៃទន្លេនេះ និង 10 ភាគរយនៅតាមតំបន់ឆ្នេរប៉ែកនិរតី ។

ការវាយតំលៃជាលើកដំបូង លើធនធានវារីអគ្គិសនីរបស់កម្ពុជា ត្រូវបានធ្វើឡើង ដោយលេខាធិការដ្ឋានទន្លេមេគង្គ នៅដើមទសវត្សឆ្នាំទី 1970 ។ ការសិក្សានេះបានប៉ាន់ប្រមាណថា សក្តានុពលរបស់ប្រទេសកម្ពុជាសំរាប់ថាមពលវារីអគ្គិសនី គឺមានយ៉ាងហោចណាស 2.376 MW នៅក្នុងអាងទន្លេមេគង្គផ្នែកខាងក្រោម និង 988 MW ខាងក្រៅអាង (លេខាធិការដ្ឋានមេគង្គ 1971, 1973) ។ គំរោងសរុបចំនួន 24 និង 11 តាមលំដាប់លំដោយ ត្រូវបានកំណត់ឡើងជាដំបូង ដោយការសិក្សានេះ សំរាប់អាងរងទឹកភ្លៀងនីមួយៗ ។ នាពេលថ្មីៗនេះ ការសិក្សាមុនពេលវិនិយោគចំនួនពីរ ត្រូវបានធ្វើឡើងទៅលើសក្តានុពលវារីអគ្គិសនីខ្នាតតូច និងមីក្រូវារីអគ្គិសនី ក្នុងប្រទេសកម្ពុជា (Meritec 2001) ។ ការសិក្សាលើសក្តានុពលវារីអគ្គិសនីខ្នាតតូច បានកំណត់គំរោងចំនួន 68 ដែលមានចាប់ពីទំហំ 0,65 ដល់ 4,2 MW ។ ការសិក្សាទៅលើគំរោងវារីអគ្គិសនីខ្នាតតូចសំរាប់សហគមន៍បានកំណត់គំរោងដែលអាចធ្វើទៅបានចំនួន 45 ។ ការវិភាគលទ្ធភាពរបស់គំរោងចំនួន 6 ក្នុងចំណោមគំរោងទាំងនេះ ដែលមានចាប់ពីទំហំ 32 ដល់ 246 kW ត្រូវបានធ្វើឡើង ។

### 4.2.3 សក្តានុពលសំរាប់គំរោង CDM នៅក្នុងជីវថាមពល

ប្រទេសកម្ពុជាមានធនធានថាមពលជីវម៉ាសជាច្រើន ដែលរួមមានដំណាំកសិកម្ម និងសំណល់សត្វជាច្រើនប្រភេទ ដូចជា អង្កាម លាមកសត្វ សំណល់ទីក្រុង និងសំណល់រាវ ជាដើម (De Lopez 2003) ។ ដោយសន្មតថាប្រសិទ្ធភាពបំលែងជាមធ្យមមាន 34% នោះសក្តានុពលសំរាប់ការផលិតថាមពល ត្រូវបានគេប៉ាន់ប្រមាណថា មានចំនួន 18.852 GWh ក្នុងមួយឆ្នាំ (Williamson et al. 2004) ។ ការប៉ាន់ប្រមាណនេះគិតទៅលើសក្តានុពលជីវម៉ាសសំរាប់ប្រទេសទាំងមូលពីសំណល់នានា ដូចជាសំណល់ដំណាំកសិកម្មសំខាន់ៗទាំងអស់ រួមជាមួយនឹងការចិញ្ចឹមសត្វ សំណល់រាវ និងសំណល់ទីក្រុង ។

ធនធានជីវថាមពលរបស់កម្ពុជាជាច្រើនត្រូវបានប្រើប្រាស់រួចទៅហើយ សំរាប់ការអនុវត្តនានា ដូចជាការចំអិនម្ហូបអាហារ និងចំណីសត្វជាដើម ។ ការប្រើប្រាស់ដែលមានស្រាប់ និងលទ្ធភាពរកបាននៃជំរើសប្រភពផ្សេងទៀត គឺជាចំណុចសំខាន់ ដែលត្រូវយកមកពិចារណា នៅពេលធ្វើការវាយតំលៃលើសក្តានុពលគំរោងជីវថាមពល ។ ឧទាហរណ៍

គំរោងដែលស្នើប្រើប្រាស់អង្កាមចេញពីម៉ាស៊ីនកិនស្រូវ ដើម្បីផ្តល់ថាមពលទៅឱ្យម៉ាស៊ីនកិនស្រូវ អាចនាំឱ្យខ្វះខាតធនធានឥន្ធនៈសំរាប់ចំអិនអាហាររបស់សហគមន៍ដែលនៅជុំវិញ (Williamson et al.2004; De Lopez 2003) ។

ការវាយតំលៃលើសក្តានុពលសំរាប់ការប្រើប្រាស់សំណល់កសិកម្ម ជាប្រភពជីវថាមពលនៅក្នុងប្រទេសកម្ពុជាក៏ត្រូវបានធ្វើឡើងផងដែរ ដោយអង្គការអភិវឌ្ឍន៍ថាមពលថ្មី និងបច្ចេកវិទ្យាឧស្សាហកម្ម (NEDO 2002) ។ ស្រូវ អំពៅ និងពោត គឺជាដំណាំបីមុខសំខាន់ ដែលត្រូវបានដាំដុះជាទូទៅ ហើយដែលគេអាចយកសំណល់របស់ទាំងនោះមកផលិតជាថាមពល ។ ការផលិតស្រូវក្នុងស្រុកប្រចាំឆ្នាំ 2001 មានចំនួន 4,04 លានតោន អំពៅចំនួន 0,16 លានតោន និងពោតសចំនួន 0,10 លានតោន (MAFF 2002) ។ ខេត្តចំនួន 3 ផលិតស្រូវប្រចាំឆ្នាំលើសពី 400.000 តោន ហើយខេត្តចំនួន 3 ផលិតអំពៅលើសពី 20.000 តោនក្នុងមួយឆ្នាំ ។ ផលិតកម្មស្រូវ និងអំពៅមាននៅក្នុងខេត្តផ្សេងៗគ្នា ។ ផ្ទុយទៅវិញ ផលិតកម្មពោតច្រើននៅផ្តុំគ្នា ដោយភាគច្រើនដាំនៅក្នុងខេត្តបាត់ដំបង ។ ខេត្តកំពង់ចាម ដែលស្ថិតនៅភាគកណ្តាលប្រទេស គឺជាតំបន់ដែលមានសក្តានុពលធនធានថាមពលជីវម៉ាសខ្ពស់ជាងគេ ។ ផលិតកម្មប្រចាំឆ្នាំក្នុងឆ្នាំ 2000 សំរាប់ដំណាំស្រូវមាន 465.733 តោន អំពៅ 25.310 តោន និងពោត 15.649 តោន ។ ទីតាំងនៅជិតទីក្រុង និងវត្តមានបណ្តាញផ្លូវគោក និងផ្លូវទឹកគ្រប់គ្រាន់ ធ្វើឱ្យតំបន់នេះអាចមានសង្ឃឹមសំរាប់ការសាងសង់រោងចក្រផលិតថាមពល ដោយប្រើជីវម៉ាស ។

ខេត្តជាច្រើន ត្រូវបានកំណត់ថាមានសក្តានុពល អាចប្រើប្រាស់អង្កាម ដើម្បីផលិតថាមពល ។ ម៉ាស៊ីនកិនស្រូវមានស្រាប់ ដែលដំណើរការដោយសហគ្រិនជនបទឯករាជ្យ ប្រើប្រាស់បច្ចេកវិទ្យាធម្មតា ហើយសមត្ថភាពកិនតូចៗដូចជាអាចផលិតអង្ករបានពី 2 ទៅ 3 តោនក្នុងមួយម៉ោង ។ កត្តានេះបង្ហាញថា ជាទូទៅគេចាំបាច់ត្រូវប្រមូលអង្កាមពីម៉ាស៊ីនកិនស្រូវនៅកន្លែងផ្សេងៗគ្នា មកកាន់ទីតាំងរួមមួយ ។ ការសិក្សាមួយដែលផ្តល់មូលនិធិដោយ COGEN 3 ដែលទទួលមូលនិធិពីសហគមន៍អឺរ៉ុប បានកំណត់ក្រុមម៉ាស៊ីនកិនស្រូវ នៅក្នុងខេត្តបាត់ដំបង និងបន្ទាយមានជ័យ ដែលមានបរិមាណអង្កាមគ្រប់គ្រាន់ សំរាប់រោងចក្រអគ្គិសនី ដែលអាចផលិតថាមពលបាន 1 MW និងតិចជាងនេះ (De Lopez et al. 2003) ។

កម្មវិធីរបស់ COGEN 3 បានធ្វើការសិក្សាមុនពេលវិនិយោគមួយ សំរាប់គំរោងផលិតអគ្គិសនី និងកំដៅ ដើរដោយអង្កាម ដែលមានសមត្ថភាពផលិតថាមពលបាន 1,5 MW នៅម៉ាស៊ីនកិនស្រូវអង្គរកសិកម្មរុងរឿង ដែលស្ថិតនៅជាយក្រុងភ្នំពេញ ។ ផលិតកម្មអង្កាមរបស់ម៉ាស៊ីនកិនស្រូវនេះ ត្រូវបានគេរំពឹងថា អាចផលិតអគ្គិសនីបានគ្រប់គ្រាន់ ដើម្បីបំពេញតំរូវការរបស់ម៉ាស៊ីនកិនស្រូវនេះ ដូច្នេះអាចជំនួសម៉ាស៊ីនភ្លើងដើរដោយម៉ាស៊ូតបាន ។ ចំហាយទឹកដែលភាយចេញពីឡកំដៅ នឹងឆ្លងកាត់តាមកន្លែងផ្លាស់ប្តូរកំដៅ ហើយនឹងត្រូវប្រើប្រាស់ ដើម្បីសម្ងួតស្រូវមុនពេលកិន ។ ការសិក្សាបញ្ជាក់ថា ចំណាយគំរោងសរុបមានចំនួន 3,34 លានអឺរ៉ូ និងមានអត្រាបង្វិលប្រាក់ត្រឡប់មកវិញ (IRR) ចំនួន 26,9 ភាគរយ ។ នាពេលបច្ចុប្បន្ននេះ អ្នកលើកគំរោង កំពុងស្វែងរកការផ្តល់ហិរញ្ញប្បទានមុនពេលបន្តការងារទៅមុខទៀត (COGEN 3 2004) ។

### 4.2.4 សក្តានុពលសំរាប់គំរោង CDM នៅក្នុងថាមពលពន្លឺព្រះអាទិត្យ

ប្រទេសកម្ពុជាទទួលបានពន្លឺព្រះអាទិត្យក្នុងកំរិតខ្ពស់ល្មមពេញមួយឆ្នាំ ។ ម៉ូដែលការបញ្ចេញរស្មីព្រះអាទិត្យសកលរបស់អង្គការ NASA របស់សហរដ្ឋអាមេរិច បានប៉ាន់ប្រមាណថា ថាមពលពន្លឺព្រះអាទិត្យមធ្យមប្រចាំថ្ងៃមានប្រហែល 5,10 kWh ក្នុងមួយម៉ែត្រការ៉េ ដោយមានគម្លាតមធ្យមប្រចាំខែ 11 ភាគរយ（Meritec 2001）។ សក្តានុពលអតិបរមាតាមទ្រឹស្តី ដើម្បីទាញយកថាមពលពន្លឺព្រះអាទិត្យអាចត្រូវគណនា តាមរយៈការប៉ាន់ប្រមាណផ្ទៃអតិបរមាសរុបរបស់ប្រទេស ដែលអាចប្រើសំរាប់តម្លើងឧបករណ៍ប្រមូល （អាចជាផ្ទាំងកញ្ចក់ពន្លឺព្រះអាទិត្យ [PV] ឬឧបករណ៍ប្រមូលកំដៅព្រះអាទិត្យ） ហើយបន្ទាប់មកគណនាសមត្ថភាពសក្តានុពលផលិតថាមពលត្រង់ចំណុចខ្ពស់បំផុត ដោយសន្មតយកតួលេខប្រសិទ្ធភាពបំលែងសំរាប់បច្ចេកវិទ្យាណាមួយ ។ វិធីសាស្ត្រនេះបញ្ជាក់ថា ផ្ទៃដីរបស់ប្រទេសកម្ពុជាចំនួន 0,02 ភាគរយ សក្តិសមសំរាប់ការតំឡើង PV ។ ជាមួយនឹងបច្ចេកវិទ្យានាពេលបច្ចុប្បន្នអាចមានអនុភាពបង្កើតថាមពលខ្ពស់បំផុតរហូតដល់ 4.189 MW ហើយផលិតអគ្គិសនីបានប្រហែល 21 GWh ក្នុងមួយថ្ងៃ ។ មានន័យថា ក្នុងរយៈពេលមួយឆ្នាំ បច្ចេកវិទ្យានេះអាចផលិតអគ្គិសនីបានប្រហែលជា 13 ដង នៃថាមពលប្រចាំឆ្នាំសរុបដែល EDC បានផលិត（Williamson et al. 2004）។ ផ្ទៃដីដែលអាចប្រើបានសំរាប់បច្ចេកវិទ្យានេះមិនមែនឧបសគ្គចំបងបំផុតក្នុងការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ឱ្យកាន់តែច្រើនឡើង នៅក្នុងប្រទេសកម្ពុជានោះទេ ។ លទ្ធភាពអនុវត្តគំរោងបាននៅក្នុងរយៈពេលខ្លី ត្រូវបានកំណត់ដោយថ្លៃថាមពល លទ្ធភាពបង់ថ្លៃ និងការយល់ដឹង ។ ឧបសគ្គចំបងចំពោះការប្រើប្រាស់បច្ចេកវិទ្យា PV អាចជាថ្លៃវិនិយោគដំបូងខ្ពស់ និងការយល់ដឹងទាបអំពីបច្ចេកវិទ្យានេះ នៅប្រទេសកម្ពុជា（Burgeap and Kosan Engineering 2001）។

### 4.2.5 សក្តានុពលសំរាប់គំរោង CDM នៅក្នុងថាមពលខ្យល់

ទិន្នន័យសមស្របពីការសង្កេតតាមដាន ដើម្បីវាយតំលៃធនធានថាមពលខ្យល់របស់កម្ពុជាឱ្យបានល្អិតល្អន់ នៅពុំទាន់មាននៅឡើយទេ ។ *សៀវភៅផែនទីធនធានថាមពលខ្យល់នៃតំបន់អាស៊ីអាគ្នេយ៍* របស់ធនាគារពិភពលោក（Truewind Solutions LLC 2001）ព្យាករណ៍ពីសក្តានុពលថាមពលខ្យល់របស់ប្រទេសនោះ ដោយមានកំរិតច្បាស់ក្នុងលំហ 1 km ។ ស្ថិតិទាំងនេះត្រូវបានគណនានៅត្រង់កំពស់ 30 ម៉ែត្រ និង 65 ម៉ែត្រ ពីលើផ្ទៃដី ហើយមានបញ្ចូលល្បឿនខ្យល់មធ្យមប្រចាំឆ្នាំ និងរបាយប្រេកង់ ។ សៀវភៅផែនទីនេះត្រូវបានបង្កើតឡើង ដោយប្រើប្រាស់ proprietary finite element model ដោយផ្អែកលើទិន្នន័យឧតុនិយម និងសណ្ឋានដី ប៉ុន្តែមិនមែន ជាទិន្នន័យខ្យល់ជាក់ស្តែង ពីប្រព័ន្ធសង្កេតតាមដានលើផ្ទៃដីទេ ។ ដូច្នេះ ទិន្នន័យនេះគួរយកទៅប្រើប្រាស់ដោយ ប្រយ័ត្នប្រយែង ហើយត្រូវមានការត្រួតពិនិត្យនៅនឹងកន្លែងសមស្រប មុនពេលធ្វើការសន្និដ្ឋានអំពីភាពអាចអនុវត្តបាននូវគំរោងណាមួយ（Truewind Solutions LLC 2001）។ យោងតាមផែនទីនេះ តំបន់ខ្ពស់រាប និងជួរភ្នំរបស់កម្ពុជា គឺជាទីតាំងដែលមានសក្តានុពលថាមពលខ្យល់ខ្ពស់ ។ គេប៉ាន់ប្រមាណថា ផ្ទៃដីសរុបចំនួន 345 km$^2$ មានល្បឿនខ្យល់ប្រចាំឆ្នាំមធ្យមលើសពី 7 ម៉ែត្រក្នុងមួយវិនាទី (m/s) ដែលស្មើនឹងប្រហែលជា 1.380 MW នៃសមត្ថភាពតួប៊ីនខ្យល់ជា

សក្ដានុពលអាចផលិតថាមពលអគ្គិសនីប្រចាំឆ្នាំបាន 3.627 GWh (Williamson et al. 2004) ។ តួលេខនេះគិតតែលើសក្ដានុពលសំរាប់តួប៊ីនខ្យល់ជាលក្ខណៈពាណិជ្ជកម្មធំៗតែប៉ុណ្ណោះ ខណៈពេលដែលមានសក្ដានុពលល្អនៅក្នុងប្រទេសកម្ពុជា សំរាប់គំរោងថាមពលខ្យល់ខ្នាតតូចនៅតាមភូមិ ។ ផែនទីនេះប៉ាន់ប្រមាណថា ប្រជាពលរដ្ឋជនបទចំនួន 6 ភាគរយរស់នៅក្នុងតំបន់ដែលមានល្បឿនខ្យល់មធ្យមប្រចាំឆ្នាំពី 5 ទៅ 7 m/s ក្នុងកំរិត 30 ម៉ែត្រខ្ពស់ពីផ្ទៃដីដែល គ្រប់គ្រាន់សំរាប់គំរោងថាមពលខ្យល់ខ្នាតភូមិ ។ ប្រសិនបើ 50 ភាគរយនៃគ្រួសារជនបទ នៅក្នុងតំបន់មានខ្យល់ ទាំងនេះ តម្លឹងម៉ាស៊ីនភ្លើងដើរដោយខ្យល់ 400-W នោះសមត្ថភាពតម្លើងសរុប អាចប្រហែលស្មើនឹង 22 MW ដែល អាចបង្កើតថាមពលអគ្គិសនីប្រហែលជា 39 GWh ក្នុងមួយឆ្នាំ ។ រហូតមកដល់ពេលបច្ចុប្បន្ន តួប៊ីនខ្យល់ដែលត្រូវបានតម្លើងនៅក្នុងប្រទេសកម្ពុជាមានតែប្រភេទខ្នាតតូចតែប៉ុណ្ណោះ ដែលជាទូទៅមានសមត្ថភាពប្រហែល 400-W ហើយ ជាអំណោយនៃគំរោងបង្ហាញពហុភាគី ឬទិញដោយគ្រួសារឯកជន ដើម្បីសាកអាគុយប្រើប្រាស់សំរាប់ផ្ទះនៅតាមទី ជនបទ ដែលគ្មានបណ្ដាញអគ្គិសនី ។

រដ្ឋាភិបាលនៃរដ្ឋផ្លង់ឌ័រ ប្រទេសបែលស៊ិច បានបញ្ចប់ការសាងសង់ស្ថានីយអង្កេតតាមដានខ្យល់ នៅជិតក្រុងព្រះសីហនុ កាលពីខែមករា ឆ្នាំ 2003 ដែលរួមមានដងក្ដោងកំពស់ 30 ម៉ែត្រ ហើយមានឧបករណ៍វាស់ល្បឿនខ្យល់ និងព្រួញចង្អុលទិសខ្យល់នៅចុងកំពូល នៅរយៈកំពស់ 20 ម៉ែត្រពីដី ។ ការពិនិត្យទិន្នន័យបានចាប់ផ្ដើម កាលពីដើមខែកុម្ភៈ ឆ្នាំ 2003 ហើយនាពេលបច្ចុប្បន្ននេះ គឺជាទិន្នន័យថាមពលខ្យល់ដែលមានគុណភាពខ្ពស់ តែមួយគត់នៅក្នុងប្រទេស (Williamson et al. 2004) ។

### 4.2.6 សក្ដានុពលសំរាប់គំរោង CDM នៅក្នុងប្រសិទ្ធភាពថាមពល

ការសន្សំសំចៃជាសក្ដានុពលសរុបរបស់ប្រទេសកម្ពុជា ពីវិធានការប្រសិទ្ធភាពថាមពល ត្រូវបានប៉ាន់ប្រមាណថាមានប្រហែលជា 467 GWh ក្នុងមួយឆ្នាំ ឬការសន្សំសំចៃថាមពល 29 ភាគរយ (Williamson et al. 2004) ។ តារាងទី 9 សង្ខេបពីប្រភេទគំរោងប្រសិទ្ធភាពថាមពល ដែលអាចធ្វើទៅបាន និងដែលសមស្រប សំរាប់វិស័យថាមពល ឧស្សាហកម្ម ពាណិជ្ជកម្ម និងតាមលំនៅដ្ឋាន ។ ការសន្សំសំចៃជាសក្ដានុពលមធ្យមពីគំរោងនីមួយៗត្រូវបានប៉ាន់ស្មាន ដោយផ្អែកលើការសិក្សា និងចំណុចគោលឧស្សាហកម្ម ដែលពាក់ព័ន្ធ ។

- *វិស័យថាមពល :* អ្នកផលិត និងអ្នកផ្គត់ផ្គង់ចរន្តអគ្គិសនី ដូចជាក្រុមហ៊ុនរដ្ឋ IPPs, REEs និងក្រុមហ៊ុននានាដែលជាម្ចាស់ និងប្រតិបត្តិការម៉ាស៊ីនភ្លើងផ្ទាល់ខ្លួនរបស់ពួកគេ ។ (ក្រុមហ៊ុនទាំងនេះក៏អាចស្ថិតនៅក្នុងវិស័យពាណិជ្ជកម្មផង និងឧស្សាហកម្មផង អាស្រ័យទៅលើអាជីវកម្មចំបងរបស់ពួកគេ ។)
- *វិស័យឧស្សាហកម្ម :* គ្រប់ក្រុមហ៊ុនទាំងអស់ ដែលពាក់ព័ន្ធជាមួយនឹងសកម្មភាពផលិត ដូចជាឡឥដ្ឋ រោងចក្រកាត់ដេរ រោងចក្រកែច្នៃថ្មាំជក់ ។ល។
- *វិស័យពាណិជ្ជកម្ម :* សណ្ឋាគារ អគារការិយាល័យ ភោជនីយដ្ឋាន មជ្ឈមណ្ឌលហាងលក់ទំនិញ និងមន្ទីរពេទ្យ ។
- *វិស័យលំនៅដ្ឋាន :* លំនៅដ្ឋានឯកជនទាំងអស់ ។

តារាងទី 4.1 គំរោងប្រសិទ្ធភាព និងការសន្សំសំចៃថាមពលប្រកបដោយសក្តានុពល ដែលបានកំណត់

| ប្រភេទគំរោង | ការពិពណ៌នាអំពីគំរោង | ការសន្សំសំចៃ ថាមពលជាសក្តានុពល |
|---|---|---|
| *វិស័យថាមពល* | | |
| ការផលិត | • កែលំអគ្រឿងម៉ាស៊ីនឱ្យកាន់តែមានប្រសិទ្ធភាពតាមប្លង់ទំនើប, ជ្រើសរើសទំហំម៉ាស៊ីនសមស្រប និងយុទ្ធសាស្ត្រត្រួតពិនិត្យ, តម្លើងឧបករណ៍ពិនិត្យ, កែលំអកម្មវិធីថែទាំ និងគ្រប់គ្រងថាមពល | 15%<br>200 GWh/ឆ្នាំ |
| ការចែកចាយ | • ធ្វើឱ្យបានប្រសើរនូវប្លង់បណ្តាញដើម្បីធ្វើឱ្យបន្ទុកមានតុល្យភាព, បង្កើតទំហំឧបករណ៍ចំលងអគ្គិសនីនិងគុណភាពដើម្បីកាត់បន្ថយការបាត់បង់, តម្លើងម៉ាស៊ីនកែតំរូវមេគុណថាមពល | 10%<br>12 GWh/ឆ្នាំ |
| ការផលិតអគ្គិសនី និងកំដៅរួមគ្នា | • ទាញយកប្រយោជន៍ពីកំដៅដែលបោះបង់ចោលសំរាប់ប្រើប្រាស់ក្នុងការកំដៅ ឬធ្វើឱ្យត្រជាក់នៅនឹងកន្លែង (ឬលក់ទៅឱ្យរោងចក្រ អគារ ។ល។ ដែលនៅជិតខាង) | 30%<br>60 GWh/ឆ្នាំ |
| *វិស័យឧស្សាហកម្ម* | | |
| ប្រព័ន្ធចំហាយទឹក | • រៀបចំឡកំដៅឱ្យបានល្អជាងមុន, រុំបំពង់បង្ហូរ, សំអាតនិងថែទាំកន្លែងចាប់ចំហាយទឹក (steam traps), កំដៅទឹកជាមុនដោយប្រើកំដៅដែលបោះបង់ចោល, ជួសជុលកន្លែងជ្រាបលេច, តម្លើងម៉ាស៊ីនត្រួតពិនិត្យ, កែលំអកម្មវិធីថែទាំនិងគ្រប់គ្រងថាមពល | 15%<br>4 GWh/ឆ្នាំ |
| ការបំភ្លឺ | • កែលំអប្លង់ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពលឱ្យនៅតិចជាអប្បបរមា ដោយប្រើដំបូលកញ្ចក់ បង្អួច ការបំភ្លឺកន្លែងធ្វើការងារ, កែលំអបច្ចេកវិទ្យាជាមួយនឹងឧបករណ៍ដែលមានប្រសិទ្ធភាពខ្ពស់ កញ្ចក់បំផ្លាត កូនជ្រុក និងឧបករណ៍ពិនិត្យតង់ស្យុង, កែលំអការត្រួតពិនិត្យដោយស្វ័យប្រវត្តិនិងដោយដៃ ដោយប្រើ occupancy sensors, ឧបករណ៍ពន្លឺ រេអូស្តារ និងឧបករណ៍បិទបើកតាមពេល | 15%<br>2 GWh/ឆ្នាំ |
| ឡឥដ្ឋ | • សាងសង់ឡមានប្រសិទ្ធភាពខ្ពស់ (ដូចជា ឡឈរ) ដើម្បីកាត់បន្ថយការបាត់បង់កំដៅឱ្យនៅតិចជាអប្បបរមា, ប្រើប្រាស់កំដៅដែលខាតបង់ និងធ្វើឱ្យដំណើរការផលិតមិនឈប់, បន្ថែមអង្គធាតុសរីរាង្គនៅក្នុងឥដ្ឋ ដូចជាអង្កាម, តម្លើងឧបករណ៍តាមដាន ដើម្បីធ្វើឱ្យកាន់តែប្រសើរនូវលំហូរដំណើរការនិងការប្រើប្រាស់ថាមពល | 50%<br>138 GWh/ឆ្នាំ |

| ប្រភេទគំរោង | ការពិពណ៌នាអំពីគំរោង | ការសន្សំសំចៃថាមពលជាសក្តានុពល |
|---|---|---|
| ការផលិតអគ្គិសនី និងកំដៅរួមគ្នា | • ទាញយកប្រយោជន៍ពីកំដៅដែលភាយចេញពីម៉ាស៊ីនភ្លើង ហើយប្រើប្រាស់សំរាប់កំដៅ ឬធ្វើឱ្យត្រជាក់ នៅនឹងកន្លែង (ឬ លក់ទៅឱ្យរោងចក្រ អគារ ។ល។ ដែលនៅជិតខាង) | 30%<br>13 GWh/ឆ្នាំ |
| *វិស័យពាណិជ្ជកម្ម* | | |
| ការបំភ្លឺ | • កែលំអប្លង់ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពលឱ្យនៅតិចជាអប្បបរមា ដោយប្រើដំបូលកញ្ចក់ បង្អួច ការបំភ្លឺកន្លែងការងារ និងបែងចែកតំបន់, បង្កើនបច្ចេកវិទ្យាជាមួយនឹងឧបករណ៍ដែលមានប្រសិទ្ធភាពខ្ពស់ កញ្ចក់បំផ្លាត អំពូលភ្លើង កូនជ្រុក និងឧបករណ៍ពិនិត្យតង់ស្យុង, កែលំអការត្រួតពិនិត្យដោយស្វ័យប្រវត្តិនិងដោយដៃ ដោយប្រើ occupancy sensors, ឧបករណ៍ពន្លឺ រេអូស្តារ និងឧបករណ៍បិទបើកតាមពេល | 15%<br>7 GWh/ឆ្នាំ |
| ម៉ាស៊ីនត្រជាក់ | • រៀបចំប្លង់អាគារឱ្យបានប្រសើរដើម្បីបន្ថយការបាត់បង់ភាពត្រជាក់ឱ្យបានច្រើនជាអតិបរមា, កាត់បន្ថយការទទួលពន្លឺព្រះអាទិត្យផ្ទាល់ឱ្យនៅតិចជាអប្បបរមា (ឧ. ដាំដើមឈើយកម្លប់), ប្រើប្រាស់ទីកន្លែងឱ្យបានសមស្រប ដើម្បីចៀសវាងធ្វើឱ្យត្រជាក់កន្លែងដែលមិនប្រើ, ប្រើកង្ហារពិដានប្រសិនបើអាច, កែលំអបច្ចេកវិទ្យា ដោយប្រើមេត្រជាក់និងប្រេងរំអិលដែលល្អ ម៉ាស៊ីនបូមកំដៅ កង្ហារបឺតកំដៅចេញ, កែលំអប្រព័ន្ធត្រួតពិនិត្យដោយប្រើ comfort and occupancy sensors ឧបករណ៍បិទបើកតាមពេល និងបើអាច night-purge function | 40%<br>70 GWh/ឆ្នាំ |
| ការកំដៅទឹក | • រៀបចំប្រព័ន្ធឱ្យបានល្អប្រសើរ ដោយប្រើឧបករណ៍រួម ឬឧបករណ៍តូចៗ ដាច់ពីគ្នា, កាត់បន្ថយចំងាយពីប្រភពប្រើប្រាស់, បន្ថយសីតុណ្ហភាពទឹកសំរាប់ការប្រើប្រាស់, ទាញយកប្រយោជន៍ពីកំដៅខាតបង់ពីកន្លែងដែលមាន (ពីរោងចក្រ ឬម៉ាស៊ីនត្រជាក់ដែលនៅជិតខាង), ប្តូរទៅប្រើបច្ចេកវិទ្យាពន្លឺព្រះអាទិត្យបើអាច, ចៀសវាងប្រព័ន្ធផ្ទុកអគ្គិសនី, រុំបំពង់បង្ហូរ, កាត់បន្ថយការប្រើប្រាស់ទឹកដោយជួសជុលកន្លែងធ្លាយឬជ្រាប, ប្រើប្រាស់ទុយោ ក្បាលរ៉ូប៊ីណេ និងចំពួយផ្កាឈូកដែលមានប្រសិទ្ធភាព | 95%<br>26 GWh/ឆ្នាំ |
| ការផលិតអគ្គិសនី និងកំដៅរួមគ្នា | • ទាញយកប្រយោជន៍ពីកំដៅដែលសាយភាយពីម៉ាស៊ីនភ្លើង យកទៅប្រើសំរាប់កំដៅ និងធ្វើឱ្យត្រជាក់នៅនឹងកន្លែង ដូចជាកំដៅទឹក ម៉ាស៊ីនត្រជាក់ និងទូទឹកកក (ឬលក់ទៅឱ្យរោងចក្រ អាគារ ។ល។ ដែលនៅជិត) | 30%<br>12 GWh/ឆ្នាំ |

| ប្រភេទគំរោង | ការពិពណ៌នាអំពីគំរោង | ការសន្សំសំចៃថាមពលជាសក្តានុពល |
|---|---|---|
| *វិស័យលំនៅដ្ឋាន* | | |
| ចង្ក្រានប្រសិទ្ធភាព | • ផ្សព្វផ្សាយពីប្លង់ចង្ក្រានប្រសិទ្ធភាព ដោយកែលំអកន្លែងទប់កំដៅ និងលំហូរខ្យល់ ដើម្បីបង្កើនចំហេះ និងប្រសិទ្ធភាពកំដៅ | 30%<br>6.530 GWh/ឆ្នាំ |
| អំពូលភ្លើងសន្សំសំចៃថាមពល | • ប្តូរអំពូលប្រើរេស៊ីស្តង់ដោយអំពូលភ្លើងសន្សំសំចៃថាមពលដែលប្រើថាមពលតិចជាងមុន ដែលផ្តល់ការបំភ្លឺដូចគ្នា និងមានអាយុកាលប្រើប្រាស់យូរជាង ( ឧ. ជំនួសអំពូលប្រើរេស៊ីស្តង់ 25-W ដោយអំពូលម៉ែត្រ 7- W ) | 72%<br>61 GWh/ឆ្នាំ |

*ប្រភព :* *Williamson et al. 2004*

## *4.3 វិស័យព្រៃឈើ*

### 4.3.1 និន្នាការកាប់ព្រៃឈើ និងសិទ្ធិទទួលជាគំរោង CDM

រហូតមកដល់បច្ចុប្បន្ន ពុំទាន់មានការវាយតំលៃផ្លូវការណាមួយត្រូវបានធ្វើឡើង លើសក្តានុពលរបស់ប្រទេសកម្ពុជា សំរាប់គំរោងស្តារព្រៃ និងដាំព្រៃ ដូចដែលបានកំណត់ដោយ CDM នៅឡើយទេ ។ ទំហំដី ដែលអាចយកមកធ្វើសកម្មភាពអាងស្រូបកាបូន ឬហៅម្យ៉ាងទៀតថា " ដីក្យូតូ " នៅពុំទាន់បានកំណត់នៅឡើយទេ ។ នៅក្រោម CDM ការស្តារព្រៃឡើងវិញ អាចធ្វើនៅលើដី ដែលពុំដែលមានព្រៃសោះ ចាប់តាំងពីថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 1989 មក រីឯការដាំព្រៃអាចកើតមានឡើងនៅលើដី ដែលពុំដែលមានព្រៃសោះ អស់រយៈពេល 50 ឆ្នាំមកហើយ ។ គំរោងព្រៃឈើ CDM ខ្នាតតូច ដែលជាគំរោងស្រូបយកសមមូលឧស្ម័នកាបូនិចតិចជាង 8 គីឡូតោនក្នុងមួយឆ្នាំ និងអនុវត្តដោយសហគមន៍ដែលមានចំណូលទាប នឹងទទួលបានអត្ថប្រយោជន៍ ពីវិធីសាស្ត្រងាយ ។

ការវាយតម្លៃលើព្រៃឈើរបស់ប្រទេសកម្ពុជា ដែលអាចជឿទុកចិត្តបានជាងគេ ត្រូវបានធ្វើឡើងដោយការចាប់រូបភាពពីផ្កាយរណប ក្នុងឆ្នាំ 1993 និង 1997 ។ នៅក្នុងឆ្នាំ 1993 ដីព្រៃមានប្រហែលជា 11.3 លានហិចតា ឬ 62 ភាគរយនៃផ្ទៃដីសរុប ។ នៅចន្លោះឆ្នាំ 1973 និង 1993 ប្រទេសនេះបាត់បង់ព្រៃឈើអស់ 1.4 លានហិចតា ( ធនាគារពិភពលោក 1996) ។ ក្នុងឆ្នាំ 1997 ដីព្រៃមានប្រមាណ 58 ភាគរយ ឬ 10.5 លានហិចតា ដែលបង្ហាញថា ប្រទេសកម្ពុជាបានបាត់បង់ដីព្រៃអស់ 0,8 លានហិកតា បន្ថែមទៀត ( ធនាគារពិភពលោក 1999) ។ ទោះយ៉ាងណាក្តី ក៏សារពើភ័ណ្ឌទាំងនេះពុំបានបង្ហាញពីគុណភាពនៃធនធានព្រៃឈើខាងក្រោមគំរបឡើយ ។ ការកាប់ព្រៃឈើបានកើនឡើងគួរឱ្យកត់សំគាល់ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ 1990 ជាមួយនឹងកំណើនស្ថេរភាពនយោបាយ ។ នៅក្នុងឆ្នាំ 1994 រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតប្រព័ន្ធសម្បទានព្រៃឈើ ដែលផ្តល់សិទ្ធិកាប់ព្រៃទៅឱ្យក្រុមហ៊ុនឯកជន ប៉ុន្តែក៏រិតជាក់ស្តែងនៃការកាប់មានរហូតទៅដល់ 5 ដង ច្រើនជាងការអនុញ្ញាតឱ្យកាប់ប្រចាំឆ្នាំចំនួន 500,000 ម៉ែត្រគូប ( ក្រសួងបរិស្ថានកម្ពុជា 1998; IDA 1998) ទៅទៀត ។ ដូច្នេះហើយ ធនធានព្រៃឈើភាគច្រើន ដែលមាន

ភាពទាក់ទាញខាងពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា ប្រហែលជាត្រូវបានគេកាប់រួចអស់ទៅហើយ (CDRI 2002; IFSR 2004) ។

ដោយសារតែព្រៃឈើជាច្រើនរបស់ប្រទេសកម្ពុជាត្រូវបានធ្វើអាជីវកម្ម ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ 1990 មក ដីព្រៃរេចរឹលដែលមានសិទ្ធិទទួលជាគំរោង CDM បាន អាចមានកំរិតតិចតួច ។ ផែនការបរិស្ថានជាតិ ឆ្នាំ 1996 បង្ហាញពីការប៉ាន់ប្រមាណទៅលើការបាត់បង់ដីព្រៃ នៅក្នុងខេត្តជាច្រើនរបស់ប្រទេសកម្ពុជា នៅចុងទសវត្សរ៍ឆ្នាំ 1980 (តារាងទី 4.2) ។ ដូចដែលបានបង្ហាញនៅក្នុងតារាងទី 4.3 ខេត្តដែលនៅកណ្តាលផ្ទៃប្រទេស (កណ្តាល តាកែវ កំពង់ឆ្នាំង កំពង់ស្ពឺ ព្រៃវែង ស្វាយរៀង និងកំពង់ចាម) បានបាត់បង់ព្រៃឈើពីពាក់កណ្តាល រហូតដល់ទាំងស្រុង នៅមុនចុងទសវត្សរ៍ឆ្នាំ 1980 (ក្រសួងបរិស្ថានកម្ពុជា 1998) ។ ដូច្នេះ ផ្ទៃដីធំៗនៅក្នុងខេត្តទាំងនេះ អាចឆ្លើយតបទៅនឹងកាលបរិច្ឆេទចុងក្រោយ គឺថ្ងៃទី 31 ខែធ្នូ ឆ្នាំ 1989 សំរាប់សកម្មភាពស្តារព្រៃឡើងវិញ ។ ប៉ុន្តែបណ្តាខេត្តទាំងនេះជាតំបន់ដែលមានប្រជាពលរដ្ឋរស់នៅច្រើន ដែលមានន័យថា ដីគ្មានព្រៃទំនងជាត្រូវបានដាំដុះ ឬកាន់កាប់រួចទៅហើយ ។ នេះអាចមានន័យថា ជាការផ្លាស់ប្តូរទំរង់ប្រើប្រាស់ដីធ្លី សំរាប់សម្បទានខ្នាតធំ ។ ស្រដៀងគ្នានេះដែរ បណ្តាខេត្តដែលធ្លាប់មានការបាត់បង់ដីព្រៃតិចតួច នៅមុនចុងទសវត្សរ៍ឆ្នាំទី 1980 ទំនងជាមានដីដែលអាចមានសិទ្ធិទទួលជាគំរោង CDM តិចតួច ព្រោះការបាត់បង់ព្រៃឈើបានកើតឡើងនៅក្រោយឆ្នាំ 1990 ។ ខេត្តទាំងនេះរួមមាន ព្រះវិហារ រតនៈគីរី ស្ទឹងត្រែង បាត់ដំបង កំពង់ធំ ពោធិសាត់ សៀមរាប កោះកុង និងមណ្ឌលគីរី ។

តារាងទី 4.2 និន្នាការបាត់បង់ព្រៃឈើក្នុងប្រទេសកម្ពុជា តាមបណ្តាខេត្ត

| ខេត្ត | ភាគរយនៃដីព្រៃនៅចុងទសវត្សរ៍ឆ្នាំទី 1980 | ភាគរយនៃការបាត់បង់ |
|---|---|---|
| កណ្តាល | 0 | 100 |
| តាកែវ | 0 | 100 |
| កំពង់ឆ្នាំង | 1-5 | 92 |
| កំពង់ស្ពឺ | 15 | 75 |
| ព្រៃវែង | 1-5 | 66 |
| ស្វាយរៀង | 1-5 | 66 |
| កំពង់ចាម | 30 | 50 |
| កំពត | 40 | 33 |
| ក្រចេះ | 85 | 6 |
| ព្រះវិហារ | 85 | 6 |
| រតនៈគីរី | 80 | 6 |
| ស្ទឹងត្រែង | 85 | 6 |

| ខេត្ត | ភាគរយនៃដីព្រៃនៅចុងទសវត្សរ៍ឆ្នាំទី 1980 | ភាគរយនៃការបាត់បង់ |
|---|---|---|
| បាត់ដំបង | 55 | 0 |
| បន្ទាយមានជ័យ | គ្មានតួលេខ | គ្មានតួលេខ |
| កំពង់ធំ | 60 | 0 |
| ពោធិសាត់ | 60 | 0 |
| សៀមរាប | 60 | 0 |
| កោះកុង | 90 | 0 |
| មណ្ឌលគិរី | 90 | 0 |

*ប្រភព : NEAP 1998*

ការសិក្សាទៅលើអត្រាដីព្រៃ ដែលទទួលបានតាមរយៈការប្រើប្រាស់ការវិភាគ Landsat spectral ដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងអង្គការស្បៀងអាហារនិងកសិកម្មរបស់សហប្រជាជាតិ (FAO 1994) បង្ហាញស្រដៀងគ្នានេះថា បណ្ដាខេត្តដាច់ស្រយាល ដូចជា ព្រះវិហារ រតនៈគីរី ស្ទឹងត្រែង កោះកុង មណ្ឌលគីរី និង ក្រចេះ មានអត្រាដីព្រៃលើសពី 80 ភាគរយ ក្នុងឆ្នាំ 1985-87 និងក្នុងឆ្នាំ 1992/93 ។ ខេត្តធំៗទាំង 4 នេះ មានផ្ទៃដីច្រើនជាង 12.000 $km^2$ ។ បណ្ដាខេត្តនៅភាគកណ្ដាលប្រទេស ដូចជា កណ្ដាល តាកែវ ព្រៃវែង និង ស្វាយរៀង មានដីព្រៃតិចតួច ចាប់តាំងពីឆ្នាំ 1985-87 មកម្ល៉េះ ដែលមានអត្រាចាប់ពី 6 ដល់ 25 ភាគរយ ។ ប៉ុន្តែ ខេត្តទាំងនេះមានប្រជាពលរដ្ឋរស់នៅកកកុញ ហើយខេត្តនីមួយៗមានផ្ទៃដីតូចជាង 5,000 $km^2$ ។ ខេត្តបាត់ដំបង និង កំពង់ធំ គឺជាខេត្តធំតែពីរគត់ ដែលមានដីព្រៃពី 50 ទៅ 60 ភាគរយ ក្នុងឆ្នាំ 1985-87 ។

តារាងទី 4.3 ដីព្រៃតាមបណ្ដាខេត្តក្នុងឆ្នាំ 1985-87 និង 1992/93

| ខេត្ត | ដីព្រៃក្នុងឆ្នាំ 1985-87 ($km^2$) | ភាគរយនៃដីព្រៃ 1985-87 | ដីព្រៃក្នុងឆ្នាំ 1992/93 ($km^2$) | ភាគរយនៃដីព្រៃ 1992/93 | ផ្ទៃដីសរុប ($km^2$) |
|---|---|---|---|---|---|
| កណ្ដាល | 923 | 25% | 748 | 20% | 3,663 |
| តាកែវ | 541 | 16% | 437 | 13% | 3,430 |
| កំពង់ឆ្នាំង | 2,753 | 52% | 2,397 | 45% | 5,278 |
| កំពង់ស្ពឺ | 4,370 | 65% | 4,447 | 66% | 6,756 |
| ព្រៃវែង | 407 | 8% | 155 | 3% | 4,847 |
| ស្វាយរៀង | 204 | 7% | 171 | 6% | 2,850 |
| កំពង់ចាម | 3,910 | 42% | 3,510 | 38% | 9,358 |
| កំពត | 2,971 | 59% | 2,850 | 57% | 5,020 |
| ក្រចេះ | 10,773 | 89% | 10,059 | 83% | 12,061 |

| ខេត្ត | ដីព្រៃក្នុងឆ្នាំ 1985-87 (km²) | ភាគរយនៃដីព្រៃ 1985-87 | ដីព្រៃក្នុងឆ្នាំ 1992/93 (km²) | ភាគរយនៃដីព្រៃ 1992/93 | ផ្ទៃដីសរុប (km²) |
|---|---|---|---|---|---|
| ព្រះវិហារ | 12,627 | 93% | 12,891 | 95% | 13,586 |
| រតនះគីរី | 11,782 | 94% | 11,595 | 92% | 12,561 |
| ស្ទឹងត្រែង | 10,546 | 94% | 10,636 | 95% | 11,175 |
| បាត់ដំបង | 6,824 | 55% | 6,330 | 51% | 12,501 |
| បន្ទាយមានជ័យ | 1,740 | 23% | 2,321 | 31% | 7,480 |
| កំពង់ធំ | 8,079 | 62% | 7,771 | 59% | 13,076 |
| ពោធិសាត់ | 8,199 | 72% | 8,133 | 71% | 11,457 |
| សៀមរាប | 10,479 | 67% | 9,817 | 62% | 15,726 |
| កោះកុង | 11,686 | 90% | 11,956 | 92% | 12,963 |
| មណ្ឌលគីរី | 12,866 | 94% | 13,098 | 96% | 13,702 |

*ប្រភព ៖ UNDP និង FAO 1998*

ទិន្នន័យដែលមាន អាចផ្តល់តែការប៉ាន់ប្រមាណទូលំទូលាយ លើភាពសមស្របរបស់ដីធ្លី សំរាប់គំរោងស្តារព្រៃនៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ ។ ដោយសារតែនិន្នាការបាត់បង់ព្រៃជាប្រវត្តិសាស្ត្រនៅក្នុងប្រទេស ពោលគឺកំណើននៃសកម្មភាពកាប់ព្រៃចាប់ពីដើមទសវត្សរ៍ឆ្នាំទី 1990 មក ផ្ទៃដីព្រៃរេចរឹលមួយភាគធំដែលមាននាពេលបច្ចុប្បន្ននេះអាចមិនមានលក្ខណៈសមស្របសំរាប់គំរោង CDM ។ ភស្តុតាងនានាបង្ហាញថា ផ្ទៃដីមួយភាគធំរបស់ប្រទេសកម្ពុជាធ្លាប់មានព្រៃឈើក្នុងឆ្នាំ 1985-87 និងក្នុងឆ្នាំ 1992/93 ។ បណ្តាខេត្ត ដែលជាប្រវត្តិសាស្ត្រធ្លាប់មានដីព្រៃតិចតួចគឺជាខេត្តដែលមានប្រជាជនរស់នៅច្រើន និងជាដីកសិកម្ម ។ សកម្មភាពស្តារព្រៃឡើងវិញនៅទីកន្លែងទាំងនោះចាំបាច់ត្រូវផ្លាស់ប្តូរដីកសិកម្ម ឱ្យក្លាយជាដីព្រៃវិញ ។ បើទោះបីជាអាចធ្វើបាន បើគិតតាមលក្ខណៈបច្ចេកទេស និងមានភាពសមស្របតាមផ្លូវច្បាប់នៅក្រោម CDM ក៏ដោយ ក៏លក្ខណៈសេដ្ឋកិច្ចរបស់គំរោងប្រភេទនេះចាំបាច់ត្រូវធ្វើការវាយតំលៃបន្ថែមទៀត ។ លើសពីនេះ លទ្ធភាពកើតវិវាទដីធ្លីនឹងកាន់តែខ្ពស់ឡើងថែមទៀតសំរាប់គំរោងធំៗ ។ ដូច្នេះ ការដាំព្រៃអាងស្រូបកាបូន CDM ជាទ្រង់ទ្រាយធំ ទំនងជាករណីលើកលែង ហើយប្រហែលជាពុំអាចប្រព្រឹត្តទៅយ៉ាងទូលំទូលាយបានទេ នៅក្នុងប្រទេសកម្ពុជា ។ ទោះយ៉ាងណាក៏ដោយ ការវិភាគរូបភាពផ្កាយរណប និងរូបភាពថតពីអាកាសពីឆ្នាំ 1990 នៅតែជាការចាំបាច់ ដើម្បីអាចឱ្យគេធ្វើការវាយតំលៃមួយដែលកាន់តែមានភាពសុក្រឹត ។

### 4.3.2 សក្តានុពលសំរាប់គំរោង CDM ដាំព្រៃ/ស្តារព្រៃឡើងវិញខ្នាតតូច

បើទោះបីជាមានការពិបាក ក្នុងការស្វែងរកផ្ទៃដីគ្មានព្រៃធំៗ ដែលមិនត្រូវបានប្រើប្រាស់សំរាប់កសិកម្មនាពេលបច្ចុប្បន្ននេះ ហើយដែលសមស្របសំរាប់គំរោង CDM ក៏ដោយ ក៏ប្រទេសកម្ពុជាបង្ហាញពីឱកាសជាច្រើន សំរាប់ការអនុវត្តសកម្មភាពដាំព្រៃ និងស្តារព្រៃឡើងវិញ តាមសហគមន៏ជាទ្រង់ទ្រាយតូច (រូបភាពទី 4.2) ។

ការស្រាវជ្រាវលើការគ្រប់គ្រងព្រៃសហគមន៏ បានកំណត់ព្រៃសហគមន៏ចំនួន 237 នៅក្នុងប្រទេសកម្ពុជា (CDRI 2002) ។ សហគមន៏ព្រៃឈើទាំងនេះ ពាក់ព័ន្ធជាមួយនឹងប្រជាពលរដ្ឋច្រើនជាង 410.000 នាក់ ក្នុងភូមិចំនួន 416 ហើយគ្របដណ្តប់លើផ្ទៃដី 72.000 ហិចតា ។ ស្ថាប័ននានា ដែលធ្វើការងារបង្កើតសហគមន៏ព្រៃឈើ រួមមានអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងរដ្ឋាភិបាល ។ គំរោងប្រហែលជាពាក់កណ្តាលបានចាប់ផ្តើមមុនឆ្នាំ 2000 ហើយគំរោងខ្លះបានចាប់ផ្តើមតាំងពីឆ្នាំ 1991 ប៉ុន្តែភាគច្រើនចាប់ផ្តើមនៅចុងទសវត្សរ៏ឆ្នាំទី 1990 ។ ការណ៏នេះបង្ហាញថា មានបទពិសោធន៏យ៉ាងច្រើនខាងផ្នែកសហគមន៏ព្រៃឈើនៅក្នុងប្រទេសកម្ពុជា ហើយក៏បង្ហាញផងដែរថា នៅមានចំណាប់អារម្មណ៏ជាច្រើនពីអ្នកផ្តល់ជំនួយ ព្រោះពាក់កណ្តាលនៃគំរោងប្រភេទនេះ បានបង្កើតឡើងក្រោយឆ្នាំ 2000 ។

រូបភាពទី 4.2 ផែនទីគំរបដីរបស់ប្រទេសកម្ពុជា




*ប្រភព: UNDP និង FAO 1994*

ព្រៃឈើសហគមន៍បានទាក់ទាញចំណាប់អារម្មណ៍របស់អ្នកផ្តល់ជំនួយកាន់តែច្រើនឡើងៗ នាពេលថ្មីៗនេះ ដោយសារតែការរួមផ្សំគ្នារបស់កត្តាចំនួនពីរ : (1) ការលំបាកក្នុងការកែទំរង់ប្រព័ន្ធព្រៃសម្បទានឱ្យមាននិរន្តភាព និងការទទួលខុសត្រូវសង្គម និង (2) ការរេចរឹលធនធានព្រៃយ៉ាងឆាប់រហ័ស ដែលប្រជាពលរដ្ឋជនបទមួយភាគធំពឹងអាស្រ័យលើ ។ ការបំផ្លាញធនធានព្រៃរបស់ប្រទេសកម្ពុជា អាចគេស្តីបន្ទោសទៅលើអសមត្ថភាពរបស់អ្នកផ្តល់ជំនួយ និងរដ្ឋាភិបាល ក្នុងការកែទំរង់ប្រព័ន្ធសម្បទានព្រៃ និងក្នុងការរក្សាការអនុញ្ញាតឱ្យកាប់ព្រៃប្រចាំឆ្នាំ ដែលស្របតាមច្បាប់ ។ នៅក្នុងចក្ខុវិស័យរបស់ខ្លួនសំរាប់ការអភិវឌ្ឍវិស័យព្រៃឈើរបស់ប្រទេសកម្ពុជា ធនាគារពិភពលោកចាត់ទុកព្រៃឈើសហគមន៍ថាជា " មធ្យោបាយមួយដើម្បីសំរេចឱ្យបាននូវការគ្រប់គ្រងធនធានព្រៃលើផ្ទៃដីធំធេងប្រកបដោយចីរភាព ដែលមិនសក្តិសមសំរាប់ផលិតកម្មជាលក្ខណៈពាណិជ្ជកម្ម និងដែលហួសពីសមត្ថភាពគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋាភិបាល (ធនាគារពិភពលោក 1999) ។ ដូច្នេះ ព្រៃឈើសហគមន៍អាចជាជំរើសប្រកបដោយចីរភាពជំនួសឱ្យការធ្វើសម្បទានព្រៃឈើ ។ លើសពីនេះទៅទៀត ជាប្រពៃណី ព្រៃឈើបានផ្តល់ឱ្យប្រជាពលរដ្ឋជនបទនូវផលិតផលព្រៃឈើ និងអនុផលព្រៃឈើ ដែលរួមមាន អុស ជ័រ ផ្លែឈើ បន្លែ ឱសថ ស្មៅចំណីសត្វពាហនៈ និងសត្វព្រៃ ។ យោងទៅតាមជំរឿនជាតិឆ្នាំ 1997 អុសគឺជាប្រភពសំខាន់នៃឥន្ធនៈចំអិនអាហារសំរាប់ប្រជាពលរដ្ឋ 90 ភាគរយ (NIS 1999) ។ ព្រៃឈើដើរតួជាសំណាញ់សុវត្ថិភាពយ៉ាងសំខាន់ ហើយបំពេញបន្ថែមលើសកម្មភាពកសិកម្ម។ ព្រៃឈើសហគមន៍សំបូរបែប បង្កើតការងារ ផ្តល់ឱកាសសំរាប់ការរកចំណូល និងមានតួនាទីសំខាន់នៅក្នុងការកាត់បន្ថយភាពក្រីក្រ។

យោងទៅតាមនីតិវិធី CDM សំរាប់សកម្មភាពស្តារព្រៃ និងដាំព្រៃ គំរោងនានាមានភាពសមស្របសំរាប់វិធីសាស្ត្រងាយ ប្រសិនបើគំរោងទាំងនោះ : (1) អាចស្រូបយក GHG ដែលកើតឡើងដោយសកម្មភាពមនុស្សតិចជាង 8 គីឡូតោននៃ $CO_2$ និង (2) ត្រូវបានបង្កើតឡើង ឬអនុវត្តដោយសហគមន៍ដែលមានចំណូលទាប ។ និយមន័យរបស់សហគមន៍ចំណូលទាបត្រូវកំណត់ដោយប្រទេសទទួលគំរោង ប៉ុន្តែប្រទេសកម្ពុជាពុំទាន់បានរាយការណ៍ទៅជូនក្រុមប្រឹក្សាប្រតិបត្តិ CDM ពីនិយមន័យផ្លូវការនៃសហគមន៍ចំណូលទាប សំរាប់ភាពសមស្របនៃវិធីសាស្ត្រងាយស្រួលនៅឡើយទេ ។ ក៏ប៉ុន្តែ បន្ទាត់នៃភាពក្រីក្រផ្លូវការរបស់កម្ពុជា ត្រូវបានកំណត់ដោយអសមត្ថភាពក្នុងការទិញចំណីអាហារ ដើម្បីបំពេញតំរូវការ 2.100 កាឡូរី និងប្រូតេអ៊ីន 58 ក្រាម ប្រចាំថ្ងៃ ឬចំណូលសមមូលតិចជាង 14 ដុល្លារ ក្នុងមួយខែ សំរាប់ប្រជាជនម្នាក់ (ក្រសួងផែនការ 1999) ។ ប្រជាពលរដ្ឋក្រីក្ររបស់ប្រទេសកម្ពុជាពុំមានលទ្ធភាពចំណាយច្រើនជាង 45 សេន ក្នុងមួយថ្ងៃ លើតំរូវការមូលដ្ឋាននានា ដូចជា អាហារ សំលៀកបំពាក់ និងទីជំរកឡើយ ។ នៅក្នុងឆ្នាំ 1999 ប្រជាពលរដ្ឋប្រហែលជា 36 ភាគរយ ឬជាង 4 លាននាក់ ពុំមានលទ្ធភាពបំពេញតំរូវការអាហារជាមូលដ្ឋាន ហើយត្រូវបានចាត់ចំណាត់ថ្នាក់ថាជាប្រជាពលរដ្ឋក្រីក្រ (ក្រសួងផែនការ 1999) ។ ភាពក្រីក្រនៅទីជនបទខ្ពស់ជាងភាពក្រីក្រនៅទីក្រុង ។ ទីក្រុងភ្នំពេញមានអត្រានៃប្រជាជនក្រីក្រទាបជាងគេនៅក្នុងប្រទេស ពោលគឺប្រហែលជា 11,1 ភាគរយ នៃចំនួនប្រជាជនសរុបរបស់ទីក្រុងនេះ ។ នៅទីក្រុងផ្សេងទៀត អត្រានេះមានជាមធ្យមចំនួន 29,7 ភាគរយ ឯនៅទីជនបទមាន 40,1 ភាគរយ ។ បើនិយាយក្នុងន័យទូលំទូលាយជាងនេះ

ទៅទៀត "ការវាយតំលៃលើភាពក្រីក្រដែលមានលក្ខណៈចូលរួម" មួយដែលត្រូវបានធ្វើឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី បានប្រើប្រាស់កង្វះខាតសន្តិសុខស្បៀង ជាសូចនាករនៃភាពក្រីក្រសំខាន់ជាងគេ (ADB 2001) ។ អ្នកភូមិចូលរួមនៅក្នុងការវាយតំលៃនេះ បានកំណត់និយមន័យនៃគ្រួសារក្រីក្រ ថាជាគ្រួសារទាំងឡាយណា ដែលជួបប្រទះភាពអត់ឃ្លានជាប្រចាំ ឬដែលអាចចៀសវាងភាពអត់ឃ្លានតែក្នុងរយៈពេលបណ្តោះអាសន្ន ។ គំរោងស្រូបកាបូន CDM ផ្អែកលើសហគមន៍ មានសក្តានុពលសំរាប់ការកាត់បន្ថយភាពក្រីក្រនៅតាមទីជនបទ តាមរយៈការបង្កើនចំណូល និងការផ្តល់ឱ្យប្រជាពលរដ្ឋមូលដ្ឋាននូវផលិតផលព្រៃឈើ ។ ដូចដែលមានពិពណ៌នានៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ 2003-2005 រដ្ឋាភិបាលមានគោលបំណង "កាត់បន្ថយភាពក្រីក្រ និងវិសមធម៌ ហើយលើកកំពស់គុណភាពជីវភាពរបស់ប្រជាពលរដ្ឋភាគច្រើនរបស់ប្រទេសកម្ពុជា ដែលកំពុងតែកើនឡើងជាលំដាប់" (CSD 2002) ។ គោលដៅជាផ្លូវការរបស់រដ្ឋាភិបាល គឺត្រូវកាត់បន្ថយភាពក្រីក្រ ឱ្យនៅត្រឹម 31 ភាគរយ នៅមុនឆ្នាំ 2005 ។ ដូច្នេះ គំរោងអាងស្រូបកាបូន CDM ខ្នាតតូច ដែលអនុវត្តដោយសហគមន៍ចំណូលទាប ក៏នឹងចូលរួមចំណែកជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់ជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រផងដែរ ។

ទីកន្លែងសក្តានុពលសំរាប់ដីព្រៃឈើសហគមន៍ ទំនងជាមានទំហំតូច និងនៅរប៉ាត់រប៉ាយពីគ្នា ប៉ុន្តែប្រសិទ្ធភាពសេដ្ឋកិច្ចអាចធ្វើឱ្យសំរេចបាន ដោយប្រមូលផ្តុំបញ្ចូលគ្នាដីភូមិទាំងឡាយ ដែលស្ថិតនៅក្រោមគំរោងអាងស្រូបកាបូន CDM តែមួយ ។ ខណៈពេលដែលខេត្តនៅភាគកណ្តាល ដែលមានដង់ស៊ីតេប្រជាជនខ្ពស់ អាចបង្ហាញឱកាសមួយចំនួនតូចសំរាប់ការដាំព្រៃឈើជាទ្រង់ទ្រាយធំ ខេត្តទាំងនេះអាចកាន់តែមានភាពសក្តិសមសំរាប់គំរោងស្រូបកាបូន CDM ទ្រង់ទ្រាយតូច ដែលអនុវត្តដោយសហគមន៍ចំណូលទាប ។ បណ្តាខេត្តទាំងនេះមានធនធានព្រៃឈើនៅសល់តិចតួច ហើយបានបាត់បង់ព្រៃឈើភាគច្រើននៅមុនឆ្នាំ 1990 ។ ព្រៃឈើសហគមន៍ ដីព្រៃគ្រួសារ និងកសិកម្ម-រុក្ខកម្ម គឺជាសក្តានុពលសំរាប់ការចាប់យកកាបូន និងផ្តល់អត្ថប្រយោជន៍ចំពោះការអភិវឌ្ឍប្រកបដោយចីរភាពសំរាប់ប្រជាពលរដ្ឋតាមមូលដ្ឋាន ។

# 5. ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងយន្តការអភិវឌ្ឍន៍ស្អាត

## *5.1 រចនាសម្ព័ន្ធបច្ចុប្បន្ននៃស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតរបស់ប្រទេសកម្ពុជា*

នៅក្នុងអំឡុងពេលនៃការនិពន្ធសៀវភៅមគ្គុទ្ទេសក៍នេះ ក្រសួងបរិស្ថានបានដើរតួនាទីជាស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៅខែធ្នូ ឆ្នាំ 1995 និងបានចុះហត្ថលេខាលើលិខិតុប្បករណ៍នៃពិធីសារក្យូតូ នៅខែកក្កដា ឆ្នាំ 2002 ។ ក្រសួងបរិស្ថានគឺជាជនបង្គោលនៃអនុសញ្ញា និងពិធីសារទាំងពីរនេះ ។ របាយការណ៍ជាតិលើកទី 1 របស់ប្រទេសកម្ពុជា នៅក្រោមអនុសញ្ញា UNFCCC ត្រូវបានដាក់ជូននៅខែតុលា ឆ្នាំ 2002 ។

រាជរដ្ឋាភិបាលកម្ពុជាបានតែងតាំងក្រសួងបរិស្ថាន ជាស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត នៅថ្ងៃទី 15 ខែកក្កដា ឆ្នាំ 2003 ។ ក្រសួងបរិស្ថានបានជូនដំណឹងដល់ក្រុមប្រឹក្សាប្រតិបត្តិបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតនៃអនុសញ្ញា UNFCCC អំពីការបង្កើតស្ថាប័នជាតិនេះ នៅថ្ងៃទី 26 ខែសីហា ឆ្នាំ 2003 បន្ទាប់មកនៅថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2004 ក្រសួងបរិស្ថាន ក៏បានផ្តល់ឈ្មោះមន្ត្រីដែលមានសិទ្ធិផ្តល់ការអនុម័តលើគំរោង CDM ដែលបានស្នើឡើង គឺ ឯកឧត្តម **ខៀវ មុត** រដ្ឋលេខាធិការនៃក្រសួងបរិស្ថាន ។

នៅថ្ងៃទី 23 ខែមិថុនា ឆ្នាំ 2003 ការិយាល័យប្រែប្រួលអាកាសធាតុបានបង្កើតឡើងនៅក្នុងនាយកដ្ឋានផែនការ និងកិច្ចការច្បាប់នៃក្រសួងបរិស្ថាន ។ ការិយាល័យប្រែប្រួលអាកាសធាតុមានតួនាទីទូលំទូលាយក្នុងការអនុវត្តរាល់ការងារបច្ចេកទេស ដែលពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញា និងភារកិច្ចដ៏ទៃទៀត ក្នុងវិស័យប្រែប្រួលអាកាសធាតុ ដែលក្រសួងបរិស្ថានផ្តល់ជូន (ក្រសួងបរិស្ថាន 2003) ។ លើសពីនេះ ការិយាល័យប្រែប្រួលអាកាសធាតុដើរតួនាទីជាលេខាធិការដ្ឋាននៃអនុសញ្ញា UNFCCC, ពិធីសារក្យូតូ និងជាជនបង្គោលនៃ CDM សំរាប់ប្រទេសកម្ពុជា ។ ទាក់ទងជាមួយ CDM ការិយាល័យប្រែប្រួលអាកាសធាតុ មានតួនាទីដូចតទៅ : ផ្តល់ព័ត៌មាន និងជូនយោបល់ដល់រដ្ឋាភិបាលស្តីអំពីការរៀបចំគោលជំហរចរចា, តាក់តែងគោលនយោបាយជាតិ ផែនការ និងបរិធានច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ, កំណត់ និងវាយតម្លៃបច្ចេកវិទ្យាថ្មីៗដែលសមស្របសំរាប់ប្រទេសកម្ពុជាដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ឬដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់, រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ និងជំរុញកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ ដែលពាក់ព័ន្ធដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

រចនាសម្ព័ន្ធបច្ចុប្បន្នស្តីពីវិស័យប្រែប្រួលអាកាសធាតុរបស់រដ្ឋាភិបាលផ្នែក មានបង្ហាញជូននៅក្នុងរូបភាព ទី 5.1 ។ ដ្យាក្រាមបង្ហាញអំពីមុខនាទីផ្សេងៗរបស់ការិយាល័យប្រែប្រួលអាកាសធាតុ : ការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់

ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការវិភាគភាពងាយរងគ្រោះនិងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការអនុវត្តអនុសញ្ញា UNFCCC ។ ការិយាល័យប្រែប្រួលអាកាសធាតុអនុវត្តការងារដែលបាន កំណត់របស់ខ្លួន ដោយសហការជាមួយក្រសួងផ្សេងៗ តាមរយៈក្រុមការងារអន្តរក្រសួងផ្នែកវិស័យថាមពល និង ព្រៃឈើ ដែលក្រុមទាំងពីរមានមន្ត្រីបច្ចេកទេសមកពីក្រសួងពាក់ព័ន្ធក្នុងវិស័យថាមពល និងព្រៃឈើ ។ ក្រុមការងារផ្នែកថាមពលមានមន្ត្រីបច្ចេកទេសមកពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយឡែកក្រុមការងារផ្នែកព្រៃឈើមានមន្ត្រីបច្ចេកទេសមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ក្រុមការងារទាំងពីរនេះមានតួនាទីជួយដល់ការិយាល័យប្រែប្រួលអាកាសធាតុក្នុងការវាយតំលៃគំរោង ដែលបានស្នើឡើងនៅក្នុងវិស័យ ថាមពល និងព្រៃឈើ ។

រូបភាពទី 5.1. រចនាសម្ព័ន្ធបច្ចុប្បន្នសំរាប់ការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា



## *5.2 ការរៀបចំស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតរបស់ប្រទេសកម្ពុជានៅពេលអនាគត*

ដូចក្នុងករណីស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតបច្ចុប្បន្នដែរ រចនាសម្ព័ន្ធដែលបានស្នើឡើងសំរាប់ស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតនៅពេលអនាគតផ្តល់តួនាទីស្នូលមួយដល់ក្រសួងបរិស្ថាន ។ ដំណើរការអនុម័តគំរោងដែលស្នើឡើងមានប្រហាក់ប្រហែលគ្នា ដោយតម្រូវឱ្យមានការចូលរួមពីក្រសួងពាក់ព័ន្ធសំរាប់គំរោងក្នុងវិស័យថាមពល និងព្រៃឈើ ។ ទោះបីយ៉ាងនេះក៏ដោយ រចនាសម្ព័ន្ធថ្មីដែលបានស្នើឡើងត្រូវបានរៀបចំ ដោយផ្តល់តួនាទីផ្លូវការជាងមុនស្របច្បាប់ដល់ស្ថាប័នដើរតួសំខាន់ៗ ក្នុងដំណើរការវាយតំលៃគំរោង ។

រចនាសម្ព័ន្ធដែលបានស្នើឡើង សំរាប់ស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតរួមមានស្ថាប័នដើរតួសំខាន់ៗ ចំនួន 3 : (1) ក្រុមប្រឹក្សាជាតិ CDM (2) លេខាធិការដ្ឋានស្ថាប័នជាតិទទួលបន្ទុក CDM និង (3) ក្រុមការងារអន្តរក្រសួង ។

**ក្រុមប្រឹក្សាជាតិ** CDM : ក្រុមប្រឹក្សាជាអ្នកចេញលិខិតអនុម័តផ្លូវការដោយបញ្ជាក់អំពីការចូលរួមដោយស្ម័គ្រចិត្ត និងថាគំរោងអនុលោមទៅតាមទិសដៅអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយចីរភាព ។ ក្រុមប្រឹក្សានេះរួមមានសមាសភាពមកពី : ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងផែនការ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ សមាជិកក្រុមប្រឹក្សាជាតិ CDM ត្រូវមានឋានៈយ៉ាងតិចបំផុតថ្នាក់អនុរដ្ឋលេខាធិការ ។ ក្រុមប្រឹក្សានេះមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន ឬក្នុងករណីប្រធានអវត្តមាន អនុប្រធានម្នាក់ (មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល) ជាអ្នកដឹកនាំ ។ ការធ្វើសេចក្តីសំរេចរបស់ក្រុមប្រឹក្សានេះ ទាក់ទងទៅនឹងការអនុម័តគំរោង CDM ដែលបានស្នើឡើង ត្រូវមានការឯកភាពទាំងស្រុងពីរាល់សមាជិក ហើយសមាជិកទាំងអស់ត្រូវចុះហត្ថលេខាលើកំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សា ។ បន្ទាប់មក លិខិតអនុម័តគំរោងត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រី ឬតំណាង ។

**លេខាធិការដ្ឋាន DNA :** ការិយាល័យប្រែប្រួលអាកាសធាតុនៃប្រទេសកម្ពុជា ដើរតួនាទីជាលេខាធិការដ្ឋាន DNA និងជាចំណុចទាក់ទងសំរាប់គំរោង CDM នៅក្នុងប្រទេសកម្ពុជា ។ ការិយាល័យប្រែប្រួលអាកាសធាតុស្ថិតនៅក្រោមចំណុះនាយកដ្ឋានផែនការ និងកិច្ចការច្បាប់នៃក្រសួងបរិស្ថាន ។ កិច្ចការរបស់លេខាធិការដ្ឋានមានដូចតទៅ : ទទួលនិងពិនិត្យឯកសារប្លង់គំរោងលើភាពពេញលេញ សំរបសំរួលជាមួយក្រុមការងារបច្ចេកទេស និងទាក់ទងដោយផ្ទាល់ជាមួយក្រុមប្រឹក្សាជាតិ CDM ។ លើសពីនេះ លេខាធិការដ្ឋានត្រូវប្រមូលព័ត៌មាន ដាក់ជូនដល់ក្រុមប្រឹក្សាសំរាប់ធ្វើសេចក្តីសំរេចជាផ្លូវការទៅលើគំរោងដែលបានស្នើឡើង ។ ដូច្នេះ លេខាធិការដ្ឋានត្រូវសំរបសំរួលដល់ការវាយតម្លៃប្លង់គំរោង PDDs ក្រុមការងារបច្ចេកទេស និងកត់ត្រាគោលជំហរ ឬមតិយោបល់របស់ក្រុមអ្នកពាក់ព័ន្ធសំខាន់ៗ ទាក់ទងជាមួយគំរោងដែលបានស្នើឡើង ។ តួនាទីមួយទៀតរបស់លេខាធិការដ្ឋាន គឺធានាឱ្យបាននូវការ

ផ្សព្វផ្សាយជាសាធារណៈអំពីគំរោងដែលបានស្នើឡើង និងធ្វើការពិភាក្សាឱ្យបានទូលំទូលាយជាមួយអ្នកពាក់ព័ន្ធ រួមមាន អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន គ្រឹះស្ថានសិក្សា អ្នកជំនាញការ ។ល។ ដើម្បីប្រមូល និងវិភាគព័ត៌មានឱ្យមានប្រសិទ្ធភាព សំរាប់ដាក់ជូនក្រុមប្រឹក្សាជាតិ CDM លេខាធិការដ្ឋាននេះមានដែនអំណាចទូលំទូលាយ ដូចជា : មានសិទ្ធិបដិសេធឯកសារប្លង់គំរោងដែលមិនពេញលក្ខណៈ, អាចជួល ឬសុំអញ្ជើញអ្នកជំនាញការបច្ចេកទេសជាតិ និងអន្តរជាតិ មកចូលរួមវាយតំលៃគំរោង, សិទ្ធិស្នើសុំព័ត៌មានបន្ថែមពីអ្នករៀបចំគំរោង, សិទ្ធិស្នើសុំចូលមើលទីតាំងគំរោងដែលបានស្នើឡើង ។ សូមបញ្ជាក់ថា លេខាធិការដ្ឋាន DNA គ្មានសិទ្ធិអនុម័តគំរោងទេ ពោលគឺមិនមានសិទ្ធិអនុម័ត ឬបដិសេធនឹងឯកសារប្លង់គំរោងដោយផ្អែកទៅលើទិសដៅ ឬលក្ខណៈវិនិច្ឆ័យការអភិវឌ្ឍដោយចីរភាពបានទេ ។ ដូចបានបញ្ជាក់ខាងដើម សិទ្ធិនេះជារបស់ក្រុមប្រឹក្សាជាតិ CDM ។

**ក្រុមការងារបច្ចេកទេសអន្តរក្រសួង :** មានក្រុមការងារបច្ចេកទេសពីរសំខាន់ៗ គឺក្រុមការងារបច្ចេកទេសផ្នែកថាមពល និងផ្នែកព្រៃឈើ ។ ក្រុមការងារបច្ចេកទេសផ្សេងទៀតអាចនឹងបង្កើតឡើង ប្រសិនបើចាំបាច់ ។ សមាសភាពក្រុមការងារបច្ចេកទេសផ្នែកថាមពលរួមមាន : តំណាងមកពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចំនួន 3 នាក់ (ផ្នែកថាមពលកកើតឡើងវិញ ផែនការ និងវារីអគ្គិសនី) តំណាងមកពីក្រសួងបរិស្ថាន ចំនួន 3 នាក់ (ការិយាល័យប្រែប្រួលអាកាសធាតុ នាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងមួយទៀតមកពីនាយកដ្ឋានពាក់ព័ន្ធ) តំណាងមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចំនួន 1 នាក់ តំណាងមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំនួន 1 នាក់ តំណាងមកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាចំនួន 1 នាក់ និងតំណាងមកពីក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន 1 នាក់ ។ សមាសភាពក្រុមការងារបច្ចេកទេសផ្នែកវិស័យព្រៃឈើ រួមមាន : តំណាងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន 3 នាក់ (រដ្ឋបាលព្រៃឈើ ក្សេត្រសាស្ត្រ និងផែនការ) តំណាងមកពីក្រសួងបរិស្ថាន ចំនួន 3 នាក់ (ការិយាល័យប្រែប្រួលអាកាសធាតុ នាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងមួយទៀតមកពីនាយកដ្ឋានពាក់ព័ន្ធ) តំណាងមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចំនួន 1 នាក់ តំណាងមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំនួន 1 នាក់ តំណាងមកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាចំនួន 1 នាក់ និងតំណាងមកពីក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន 1 នាក់ ។ ដូច្នេះ សមាសភាពក្រុមការងារបច្ចេកទេសអន្តរក្រសួងធានាបាននូវតំណាងដ៏ទូលំទូលាយពីសំណាក់ស្ថាប័នរដ្ឋាភិបាល និងគ្រឹះស្ថានសិក្សា ។ ក្រុមការងារបច្ចេកទេសពិនិត្យផ្ទៀងផ្ទាត់ឯកសារប្លង់គំរោងជាមួយលក្ខណៈវិនិច្ឆ័យនៃការអភិវឌ្ឍដោយចីរភាព ប៉ុន្តែគ្មានសិទ្ធិធ្វើសេចក្តីសំរេចទេ ។ ក្រុមការងារបច្ចេកទេសរៀបចំរបាយការណ៍បច្ចេកទេស ស្តីពីការការវាយតំលៃគំរោង ដោយមានបញ្ចូលនូវអនុសាសន៍បច្ចេកទេស និងនយោបាយ សំរាប់ដាក់ជូនក្រុមប្រឹក្សាជាតិ CDM ។ បន្ទាប់មក របាយការណ៍បច្ចេកទេសស្តីពីការវាយតម្លៃគំរោង ត្រូវដាក់ជូនលេខាធិការដ្ឋាន DNA ។

សមាសភាព តួនាទី ការទទួលខុសត្រូវ និងអំណាចសំរេច របស់ក្រុមប្រឹក្សាជាតិ CDM លេខាធិការដ្ឋាន DNA និងក្រុមការងារបច្ចេកទេសអន្តរក្រសួង មានសង្ខេបជូននៅក្នុងតារាងទី 5.1 ។

តារាងទី 5.1. សេចក្តីសង្ខេបអំពីអ្នកដើរតួសំខាន់ៗនៅក្នុងស្ថានប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត

| **អ្នកដើរតួរសំខាន់ៗ** | **សមាសភាព** | **តួនាទី និងការទទួល ខុសត្រូវ** | **សិទ្ធិសំរេច** |
|---|---|---|---|
| ក្រុមប្រឹក្សាជាតិ CDM | - មានតំណាងម្នាក់មកពី : ក្រសួងបរិស្ថាន, ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ, ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល, ក្រសួងផែនការ, ក្រសួងសាធារណការ និងដឹកជញ្ជូន, និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។<br>- តំណាងទាំងនោះត្រូវមានឋានៈយ៉ាងទាបបំផុតថ្នាក់អនុរដ្ឋ-លេខាធិការ ។<br>- ក្រុមប្រឹក្សានេះ មានឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន ឬ ក្នុងករណីប្រធានអវត្តមាន អនុប្រធានម្នាក់ជំនួស ។<br>- តំណាងមកពីក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ និង ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ជាអនុប្រធាន | - វាយតម្លៃគំរោង CDM ដែលបានស្នើឡើងសំរាប់កម្ពុជា<br>- ចេញលិខិតអនុម័តជាផ្លូវការ ដើម្បីបញ្ជាក់អំពីការចូលរួមអនុវត្តគំរោងដោយស្ម័គ្រចិត្ត និងភាពសមស្របនៃគំរោងតាមទិសដៅអភិវឌ្ឍន៍ដោយចីរភាព<br>- ជួយសំរបសំរួលដល់ដំណើរការវាយតំលៃគំរោងរបស់លេខាធិការដ្ឋាន DNA ជាមួយស្ថាប័នសាធារណៈ | - អនុញ្ញាត ឬបដិសេធគំរោងដែលស្នើឡើងសំរាប់ កម្ពុជា ។ សេចក្តីសំរេចរបស់ក្រុមប្រឹក្សានេះ ទាមទារឱ្យមានការឯកភាពទាំងស្រុងពីគ្រប់សមាជិក ព្រមទាំងហត្ថលេខារបស់សមាជិក នៅលើកំណត់-ហេតុរបស់ក្រុមប្រឹក្សា ។ លិខិតអនុញ្ញាត ឬបដិសេធត្រូវចុះហត្ថលេខាដោយប្រធាន ។<br>- ក្រុមប្រឹក្សាមានសិទ្ធិដកហូតមកវិញនូវលិខិតអនុញ្ញាត ក្នុងករណីដែលការអនុវត្តគំរោងបរាជ័យមិនបានរួមចំណែកដល់ការអភិវឌ្ឍដោយចីរភាព ដូចដែលបានសន្យានៅក្នុងឯកសារប្លង់គំរោង ។<br>- ក្រុមប្រឹក្សាចាត់តាំងសមាជិកនៃក្រុមការងារបច្ចេកទេសអន្តរក្រសួង ។ |
| លេខាធិការដ្ឋាន DNA | ការិយាល័យប្រែប្រួលអាកាសធាតុនៃប្រទេសកម្ពុជា ដើរតួនាទីជាលេខាធិការដ្ឋាន DNA | - លេខាធិការដ្ឋាន DNA គឺជាទីកន្លែងទំនាក់ទំនងសកម្មភាពគំរោង CDM នៅក្នុងប្រទេសកម្ពុជា ។<br>- ទទួល និងពិនិត្យឯកសារប្លង់គំរោង ថាតើបានបញ្ចប់ពេញលេញឬទេ | - លេខាធិការដ្ឋាន DNA មានសិទ្ធិបដិសេធឯកសារប្លង់គំរោងដែលមិនពេញលក្ខណៈ<br>- គ្មានសិទ្ធិអនុម័តគំរោងឡើយ ហើយមិនអាចទទួល ឬបដិសេធឯកសារប្លង់គំរោងដោយផ្អែកទៅលើទិសដៅ ឬ |

| អ្នកដើរតួរសំខាន់ៗ | សមាសភាព | តួនាទី និងការទទួល ខុសត្រូវ | សិទ្ធិសំរេច |
|---|---|---|---|
| | | - សំរបសំរួលសកម្មភាពក្រុមការងារបច្ចេកទេស<br>- ទាក់ទងដោយផ្ទាល់ជាមួយក្រុមប្រឹក្សាជាតិ CDM និងទទួលភារកិច្ចប្រមូលព័តិមានជូនដល់ក្រុមប្រឹក្សា ដើម្បីធ្វើសេចក្តីសំរេចជាផ្លូវការទៅលើគំរោងដែលបានស្នើឡើង ។ ព័តិមានទាំងនោះរួមមាន : ការវាយតំលៃឯកសារប្លង់គំរោងដោយក្រុមការងារបច្ចេកទេស, គោលជំហររបស់អ្នកពាក់ព័ន្ធសំខាន់ៗ<br>- សម្របសម្រួលការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធ ( អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន គ្រឹះស្ថានសិក្សា អ្នកជំនាញការ ។ល។) | លក្ខណៈវិនិច្ឆ័យការអភិវឌ្ឍដោយចីរភាពបានទេ<br>- អាចជួល ឬសុំអញ្ជើញអ្នកជំនាញការបច្ចេកទេសជាតិ និងអន្តរជាតិ ដើម្បីវាយតំលៃគំរោងប្រសិនបើចាំបាច់<br>- មានសិទ្ធិស្នើសុំព័តិមានបន្ថែមពីអ្នករៀបចំគំរោង ប្រសិនបើចាំបាច់<br>- មានសិទ្ធិស្នើសុំចូលមើលទីតាំងគំរោង<br>- មានសិទ្ធិរៀបចំការពិភាក្សាជាសាធារណៈជាមួយអ្នកពាក់ព័ន្ធ<br>- មានសិទ្ធិផ្សព្វផ្សាយ ឬបោះពុម្ពផ្សារឯកសារប្លង់គំរោងដែលបានដាក់ជូន ។ |
| ក្រុមការងារបច្ចេកទេសអន្តរក្រសួង | - មានក្រុមការងារបច្ចេកទេសពីរក្រុមសំខាន់ៗគឺ : ក្រុមការងារបច្ចេកទេសផ្នែកថាមពល និងផ្នែកព្រៃឈើ ។ ក្រុមការងារបច្ចេកទេសផ្សេងទៀតអាចនឹងបង្កើតឡើង ប្រសិនបើចាំបាច់<br>- សមាសភាពក្រុមការងារបច្ចេក-ទេសផ្នែកថាមពលរួមមាន : តំណាងមកពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល 3 នាក់ (ផ្នែកថាមពលកកើតឡើងវិញ ផែនការ និងវារីអគ្គិសនី), តំណាងមកពីក្រសួងបរិស្ថាន 3 នាក់ | - ក្រុមការងារបច្ចេកទេសពិនិត្យផ្ទៀងផ្ទាត់ឯកសារប្លង់គំរោងជាមួយលក្ខណៈវិនិច្ឆ័យការអភិវឌ្ឍដោយចីរភាព<br>- រៀបចំរបាយការណ៍បច្ចេកទេសស្តីពីការការវាយតំលៃគំរោងដោយមានផ្តល់នូវអនុសាសន៍បច្ចេកទេស និងនយោបាយដល់ក្រុមប្រឹក្សាជាតិ CDM ។ បន្ទាប់មក របាយការណ៍បច្ចេកទេសស្តីពីការវាយតំលៃគំរោង ត្រូវដាក់ជូនលេខាធិការដ្ឋាន DNA ។ | - ក្រុមការងារបច្ចេកទេសមានសិទ្ធិតាមដាន និងវាយតំលៃការអនុវត្តគំរោង ជាមួយនិងកិច្ចសន្យា ដូចដែលបានបញ្ជាក់នៅក្នុងឯកសារប្លង់គំរោងទាក់ទងនិងការអភិវឌ្ឍដោយចីរភាព |

| អ្នកដើរតួរសំខាន់ៗ | សមាសភាព | តួនាទី និងការទទួល ខុសត្រូវ | សិទ្ធិសំរេច |
|---|---|---|---|
| | (ការិយាល័យប្រែប្រួលអាកាសធាតុ នាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងមួយទៀតមកពីនាយកដ្ឋានពាក់ព័ន្ធ), តំណាងមកពីក្រសួងសាធារណការ និងដឹកជញ្ជូន 1 នាក់, តំណាងមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ 1 នាក់, តំណាងមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម 1 នាក់ និងតំណាងមកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា 1 នាក់ ។<br>- សមាសភាពក្រុមការងារបច្ចេកទេសផ្នែកព្រៃឈើ រួមមាន : តំណាងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ 3 នាក់ (រដ្ឋបាលព្រៃឈើ ក្សេត្រសាស្ត្រ និងផែនការ) តំណាងមកពីក្រសួងបរិស្ថាន 3 នាក់ (ការិយាល័យប្រែប្រួលអាកាសធាតុ នាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងមួយទៀតមកពីនាយកដ្ឋានពាក់ព័ន្ធ), តំណាងមកពីក្រសួងសាធារណការ និងដឹកជញ្ជូន 1 នាក់, តំណាងមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ 1 នាក់, តំណាងមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម 1 នាក់ និងតំណាងមកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា 1 នាក់ ។ | | |

*ប្រភព : ការិយាល័យប្រែប្រួលអាកាសធាតុ 2004*

# 6. តម្រូវការ និងនីតិវិធីអនុម័តគំរោងយន្តការអភិវឌ្ឍន៍ស្អាត

## *6.1. តារាងវាយតម្លៃ និងលក្ខណៈវិនិច្ឆ័យការអភិវឌ្ឍប្រកបដោយចីរភាព*

ស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតរបស់ប្រទេសកម្ពុជា វាយតម្លៃគំរោងដែលបានស្នើឡើង ដោយធៀបទៅនឹងមុំទាំង 3 នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល គឺការអភិវឌ្ឍសេដ្ឋកិច្ច កិច្ចការពារបរិស្ថាន និងការកាត់បន្ថយភាពក្រីក្រ ។ គំរោង CDM ដែលបានអនុម័តរួច ត្រូវតែរួមចំណែកដល់ការអភិវឌ្ឍដោយចីរភាពរបស់ប្រទេសកម្ពុជា (CCCO 2004) ។

ប្រទេសកម្ពុជាបាន រៀបចំតារាងមួយស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីប្រើជាឯកសារសំរាប់វាយតម្លៃគំរោង CDM ។ តារាងនេះមានលក្ខណៈប្រហាក់ប្រហែលនឹងតារាងដែលបានប្រើប្រាស់ដោយអង្គការអន្តរជាតិ ដើម្បីវាយតំលៃគំរោង CDM ជាមួយនឹងលក្ខណៈវិនិច្ឆ័យដោយចីរភាព (ឧទាហរណ៍ សូមមើលអង្គការ Worldwide Fund for Nature and SouthSouthNorth) ។ តារាងនេះ រៀបចំឡើងដោយផ្អែកលើច្បាប់ បញ្ញត្តិ គោលនយោបាយ សេចក្តីថ្លែងការណ៍ និងកាតព្វកិច្ចរបស់ប្រទេសកម្ពុជាចំពោះអនុសញ្ញាអន្តរជាតិ ដោយផ្តោតទៅលើទិដ្ឋភាព 4 នៃការអភិវឌ្ឍដោយចីរភាព គឺ : សេដ្ឋកិច្ច សង្គម បរិស្ថាន និងការផ្ទេរបច្ចេកវិទ្យា ។ មានសូចនាករចំនួន 25 ដែលចែកចេញជា : សូចនាករការកែលំអ និងការពារបរិស្ថានចំនួន 11, សូចនាករសង្គមចំនួន 8 (ការបង្កើនប្រាក់ ចំណូល និងកំរិតកំពស់ជីវភាព), សូចនាករការផ្ទេរបច្ចេកវិទ្យាចំនួន 2 និងសូចនាករផលប្រយោជន៍សេដ្ឋកិច្ចចំនួន 4 ។[13]

គំរោងដែលស្នើឡើងត្រូវបានវាយតម្លៃទៅតាមសូចនាករនីមួយៗ ដែលមានចាប់ពី **វិជ្ជមាន** ទៅ **អវិជ្ជមាន** ។ ការឱ្យតម្លៃវិជ្ជមានទៅលើលក្ខណៈវិនិច្ឆ័យណាមួយបញ្ជាក់អំពីការអនុវត្តល្អ ហើយផ្ទុយមកវិញ ការឱ្យតម្លៃអវិជ្ជមានមានន័យថា គំរោងនោះមានផលប៉ះពាល់ធ្ងន់ធ្ងរ ។ ការឱ្យតំលៃអព្យាក្រឹតបញ្ជាក់ថា គំរោងគ្មានផលប៉ះពាល់អ្វីជាសំខាន់ (វិជ្ជមាន ឬអវិជ្ជមាន) ធៀបទៅនឹងសូចនាករណាមួយនោះទេ ឬមានដំណើរការដូចធម្មតា ។

គំរោងត្រូវសំរេចឱ្យបាននូវតម្លៃវិជ្ជមាន ឬអព្យាក្រឹត្យ ចំពោះសូចនាករនីមួយៗ នៃទិដ្ឋភាពទាំង 4 (សេដ្ឋកិច្ច សង្គម បរិស្ថាន និងការផ្ទេរ បច្ចេកវិទ្យា) ។ អាស្រ័យហេតុនេះ តំលៃអវិជ្ជមានមួយនៃសូចនាករនាមួយបញ្ជាក់ថា គំរោងនោះមិនបានឆ្លើយតបពេញលេញទៅនឹងទិសដៅអភិវឌ្ឍន៍ដោយចីរភាពរបស់ប្រទេសកម្ពុជាទេ (ដូចបានបញ្ជាក់នៅក្នុងច្បាប់ បញ្ញត្តិ គោលនយោបាយ សេចក្តីថ្លែងការ និងអនុសញ្ញា) ហើយគំរោងនោះគួរតែរៀបចំកែសំរួល និងដាក់មកស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតសារជាថ្មី ។ អវត្តមាននៃផលប៉ះពាល់អវិជ្ជមានសំរាប់សូចនាករនីមួយៗ ត្រូវចាត់ទុកថាជាលក្ខខណ្ឌអតិបរមាដែលគំរោងត្រូវអនុវត្តតាម ។

13. តារាងស្តីពីការអភិវឌ្ឍដោយចីរភាពមានផ្តល់ជូននៅក្នុងសេចក្តីបន្ថែមទី 6.1 ។

គោលការណ៍ណែនាំដែលភ្ជាប់ជាមួយនឹងតារាងស្ដីពីការអភិវឌ្ឍដោយចីរភាពបញ្ជាក់ថា អ្នករៀបចំគំរោងត្រូវដាក់ជូនឯកសារប្លង់គំរោងដល់ស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត ដោយបញ្ជាក់ថា តើគំរោងមានទិសដៅអភិវឌ្ឍន៍ដោយចីរភាពយ៉ាងណាខ្លះ ដូចដែលមានចែងនៅក្នុងសូចនាករទាំង 25 ។ លើសពីនេះ ការវាយតម្លៃត្រូវគិតគូរទៅលើ : (1) រាល់ផលប៉ះពាល់របស់គំរោង ទាំងក្នុងព្រំដែន និងក្រៅព្រំដែនគំរោង (2) រាល់ដំណាក់កាលនៃវដ្តគំរោង ចាប់តាំងពីការសាងសង់ រហូតដល់ដាក់ឱ្យដំណើរការរបស់គំរោង ។

ស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតរបស់ប្រទេសកម្ពុជា បញ្ជាក់យ៉ាងច្បាស់ថា *ផែនការពិនិត្យតាមដាន និងការបញ្ជាក់* មិនត្រូវអនុវត្តតែចំពោះការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នោះទេ ពោលគឺត្រូវគ្របដណ្តប់ទៅលើរាល់កិច្ចសន្យាទាំងអស់ ដូចដែលបានបញ្ជាក់នៅក្នុងឯកសារប្លង់គំរោង ដែលទាក់ទងនឹងតារាងការអភិវឌ្ឍដោយចីរភាព ។ ដូច្នេះ ស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតបញ្ជាក់ថា ការខកខានរបស់គំរោងក្នុងការអនុវត្តតាមរាល់កិច្ចសន្យាទាំងនោះ នឹងទទួលនូវការដកហូតមកវិញនូវលិខិតអនុញ្ញាត ហើយស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាតនឹងជំរាបជូនជាផ្លូវការដល់ក្រុមប្រឹក្សាប្រតិបត្តិយន្តការអភិវឌ្ឍន៍ស្អាត ។

## 6. 2 នីតិវិធីអនុម័តគំរោងបច្ចុប្បន្ន

បច្ចុប្បន្ន កម្ពុជាបានរៀបចំរួចរាល់នូវនីតិវិធីអនុម័តគំរោង CDM របស់ប្រទេសកម្ពុជា ។ អ្នករៀបចំគំរោង ដែលមានបំណងវិនិយោគលើគំរោងយន្តការអភិវឌ្ឍន៍ស្អាតនៅប្រទេសកម្ពុជា ត្រូវដាក់ជូននូវឯកសារប្លង់គំរោងទៅ DNA របស់កម្ពុជា ដែលស្ថិតនៅក្នុងការិយាល័យប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន ។ ដូចមានបញ្ជាក់នៅក្នុងគោលការណ៍ណែនាំដែលភ្ជាប់ជាមួយតារាងអភិវឌ្ឍន៍ដោយចីរភាព ដំណើរការអនុម័តគំរោងរួមមាន 6 ជំហាន (ការិយាល័យប្រែប្រួលអាកាសធាតុ 2004) :

1. អ្នករៀបចំគំរោងដាក់ជូនឯកសារប្លង់គំរោង (PDD) ទៅ DNA
2. DNA ទទួល PDD ហើយពិនិត្យមើលថា តើឯកសារនេះមានភាពពេញលេញដែរឬទេ ។ ប្រសិនបើពុំមានព័ត៌មានគ្រប់គ្រាន់សំរាប់ធ្វើការវាយតំលៃដោយប្រើតារាងអភិវឌ្ឍន៍ដោយចីរភាព ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទេ នោះ DNA នឹងស្នើឱ្យអ្នករៀបចំគំរោងដាក់ជូនឡើងវិញនូវ PDD ដោយភ្ជាប់ជាមួយនូវព័ត៌មានបន្ថែមដែលត្រូវការ
3. នៅពេលបានទទួល PDD ដែលមានភាពពេញលេញហើយ DNA នឹងផ្សព្វផ្សាយពាក្យស្នើសុំរបស់គំរោងយន្តការអភិវឌ្ឍន៍ស្អាតដែលស្នើឡើងនេះ តាមមធ្យោបាយសមស្របនានា ដូចជាតាមប្រព័ន្ធអ៊ីនធឺណិត ឬនៅក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកជាដើម សំដៅលើកទឹកចិត្តឱ្យមានការផ្តល់ យោបល់ពីភាគីពាក់ព័ន្ធ

4. DNA នឹងកោះអញ្ជើញក្រុមការងារអន្តរក្រសួង និងភាគីពាក់ព័ន្ធមួយចំនួន ដើម្បីធ្វើការវាយតម្លៃគំរោងនោះ ផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការអភិវឌ្ឍដោយចីរភាព ដូចមានចែងក្នុងឧបសម្ព័ន្ធ ។ ប្រសិនបើចាំបាច់ ក្រុមវាយតម្លៃគំរោងនេះអាចធ្វើទស្សនកិច្ចទៅទីតាំងគំរោងដោយផ្ទាល់
5. ប្រសិនបើគំរោងបំពេញបានតាមគោលបំណងអភិវឌ្ឍន៍ដោយចីរភាពរបស់កម្ពុជា នោះ DNA នឹងចេញលិខិតបញ្ជាក់ពីការឯកភាពលើគំរោងនេះ ដោយបញ្ជាក់ថា រដ្ឋាភិបាលចូលរួមនៅក្នុងគំរោងនេះដោយស្ម័គ្រចិត្ត ហើយថាគំរោងនេះឆ្លើយតបទៅនឹងគោលបំណងអភិវឌ្ឍន៍ដោយចីរភាពរបស់ប្រទេសកម្ពុជា ។ ប្រសិនបើគំរោងនេះមិនបានបំពេញតាមគោលបំណងអភិវឌ្ឍន៍ដោយចីរភាពរបស់ប្រទេសកម្ពុជាទេ នោះ DNA នឹងជូនដំណឹងអំពីលទ្ធផលនៃដំណើរការវាយតម្លៃទៅអ្នករៀបចំគំរោង ព្រមទាំងជួយផ្តល់ការណែនាំដើម្បីកែសំរួល PDD គំរោងនោះឡើងវិញ
6. បន្ទាប់មក គំរោងនេះនឹងត្រូវដាក់បញ្ចូលជាបន្ថែមទៅក្នុងមូលដ្ឋានទិន្នន័យគំរោងយន្តការអភិវឌ្ឍន៍ស្អាតក្នុងប្រព័ន្ធអ៊ីនធឺណិតនៃយន្តការអភិវឌ្ឍន៍ស្អាត ។

## 6.3 នីតិវិធីដែលបានស្នើឡើងសំរាប់អនុម័តគំរោង

អនាគត DNA របស់ប្រទេសកម្ពុជានឹងប្រើប្រាស់តារាងការអភិវឌ្ឍដោយចីរភាពដូចគ្នានឹង DNA ប្រើសព្វថ្ងៃដើម្បីវាយតំលៃគំរោង CDM ។ នីតិវិធីដែលស្នើឡើងដើម្បីអនុម័តគំរោង ផ្តល់នូវព័តិមានលំអិត ដូចជា រយៈពេល និងរបៀបរបបសកម្មភាពដែលអ្នកដើរតួសំខាន់ៗរបស់ DNA ត្រូវអនុវត្ត មានដូចជាក្រុមប្រឹក្សាជាតិ CDM លេខាធិការដ្ឋាន CDM និងក្រុមការងារបច្ចេកទេសអន្តរក្រសួង ។ ដំណើរការអនុម័តគំរោងទាំងស្រុងត្រូវចំណាយពេលប្រហែល 55 ថ្ងៃធ្វើការ ។

ដ្យាក្រាមនៃដំណើរការអនុម័តគំរោង (សូមមើលរូបភាពទី 6.1 និង 6.2) ចែកចេញជា 3 ដំណាក់កាល ។ ដំណាក់កាលទី 1 (10ថ្ងៃធ្វើការ) រួមមានការពិនិត្យឯកសារប្លង់គំរោងលើកដំបូងរបស់លេខាធិការដ្ឋាន DNA ថាតើឯកសារប្លង់គំរោងនោះមានលក្ខណៈពេញលេញហើយឬនៅ ។ លើសពីនេះ ប្រសិនបើចាំបាច់ នៅពេលដាក់ជូនឯកសារប្លង់គំរោង ដើម្បីស្នើសុំការអនុម័ត ត្រូវភ្ជាប់មកជាមួយនូវ (1) លិខិតអនុម័តវិនិយោគផ្លូវការដែលពាក់ព័ន្ធ (ពីទីស្តីការគណៈរដ្ឋមន្ត្រី ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពីអាជ្ញាធរខេត្ត-ក្រុង) និង (2) របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ។ នៅពេលពិនិត្យឃើញថា ឯកសារប្លង់គំរោងមានលក្ខណៈពេញលេញហើយ ឯកសារប្លង់គំរោងនេះនឹងត្រូវដាក់ជូនដំណឹងជាសាធារណៈ ។ ដំណាក់កាលទី 2 (30 ថ្ងៃធ្វើការ) រួមមានការវាយតំលៃជាលក្ខណៈបច្ចេកទេស ទៅលើឯកសារប្លង់គំរោង PDD ជាមួយនឹងតារាងការអភិវឌ្ឍដោយចីរភាព និងប្រមូលនូវរាល់គំនិតយោបល់របស់អ្នកពាក់ព័ន្ធដែលបាន ផ្ញើជូនលេខាធិការដ្ឋាន DNA ។ ក្រុមការងារបច្ចេកទេសអន្តរក្រសួងផ្អែកថាមពល ព្រៃឈើ និងវិស័យដ៏ទៃទៀត ទទួលរៀបចំរបាយការណ៍បច្ចេកទេស ស្តីពីការវាយតំលៃគំរោង ជាមួយនឹង

ទិសដៅអភិវឌ្ឍន៍ជាតិដោយចីរភាព ដោយប្រើប្រាស់តារាងការអភិវឌ្ឍដោយចីរភាព ។ អ្នកពាក់ព័ន្ធ ដែលរួមមាន អង្គការមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាន សាធារណជន និងគ្រឹះស្ថានសិក្សា មានពេល 20 ថ្ងៃធ្វើការ ដើម្បីផ្ញើគំនិតយោបល់របស់ពួកគេស្តីពីគំរោង ទៅលេខាធិការដ្ឋាន DNA ។ បន្ទាប់មក លេខាធិការដ្ឋាន DNA រៀបចំរបាយការណ៍វាយតំលៃគំរោង ដោយបញ្ចូលនូវរបាយការណ៍បច្ចេកទេសរបស់ក្រុមការងារ គំនិតយោបល់របស់អ្នកពាក់ព័ន្ធ និងព័តិមានពាក់ព័ន្ធផ្សេងៗទៀត ។ នៅចុងបញ្ចប់នៃដំណាក់កាលទី 2 របាយការណ៍វាយតំលៃគំរោងត្រូវបានដាក់ជូនទៅក្រុមប្រឹក្សជាតិ CDM ។ ដំណាក់កាលទី 3 (15 ថ្ងៃធ្វើការ) រួមមានការពិនិត្យរបស់ក្រុមប្រឹក្សាជាតិ CDM ។ បន្ទាប់មក ក្រុមប្រឹក្សានេះធ្វើសេចក្តីសំរេចទាក់ទងនឹងគំរោង CDM ដែលស្នើឡើង បន្ទាប់ពី 10 ថ្ងៃធ្វើការ ។ លិខិតអនុម័ត ឬបដិសេធ ត្រូវចេញឱ្យក្នុងរយះពេល 5 ថ្ងៃបន្ទាប់ពី ការសំរេចរបស់ក្រុមប្រឹក្សា ។

រូបភាពទី 6.1. ដ្យាក្រាមនៃដំណើរការអនុម័តគំរោង CDM នៅកម្ពុជា




*ប្រភព : ការិយាល័យប្រែប្រួលអាកាសធាតុ 2004*

* ឯកសារគំរោងត្រូវតែបំពេញគ្រប់គ្រាន់ ដោយភ្ជាប់មកជាមួយនូវលិខិតអនុម័តវិនិយោគផ្លូវការ ប្រសិនបើមាន (ពីទីស្តីការគណៈរដ្ឋមន្ត្រី , ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា , ពីអាជ្ញាធរខេត្ត-ក្រុង) និងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

** បញ្ចូលនូវរបាយការណ៍បច្ចេកទេសរបស់ក្រុមការងារ គំនិតយោបល់របស់អ្នកពាក់ព័ន្ធ និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀត ។

រូបភាពទី 6.2. រយៈពេល និងសកម្មភាពសំរាប់ការវាយតំលៃគំរោង CDM ដែលបានស្នើឡើងនៅកម្ពុជា



# 7. ច្បាប់ និងបទបញ្ញត្តិនានា

## *7.1 ច្បាប់វិនិយោគ*

ច្បាប់ស្តីពីការវិនិយោគ ដែលបានបង្កើតឡើងនៅឆ្នាំ 1994 និងធ្វើវិសោធនកម្មក្នុងឆ្នាំ 2003 បង្កើតមូលដ្ឋានស្ថាប័ន និងមូលដ្ឋានច្បាប់ សំរាប់ការវិនិយោគនៅក្នុងប្រទេសកម្ពុជា (ប្រអប់ទី 7.1) ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) គឺជាស្ថាប័នរដ្ឋ ដែលទទួលខុសត្រូវខាងការអភិវឌ្ឍ និងការគ្រប់គ្រង FDI និងជាស្ថាប័នប្រតិបត្តិ ដែលទទួលខុសត្រូវក្នុងការកំណត់យុទ្ធសាស្ត្រវិនិយោគ និងទទួលយក ឬបដិសេធចោលសំណើវិនិយោគនានា ។ ស្ថាប័ននេះមានក្រុមប្រឹក្សាប្រតិបត្តិចំនួនពីរ : (1) ក្រុមប្រឹក្សានីតិសម្បទាន និងអភិវឌ្ឍន៍កម្ពុជា (CRDB) និង (2) ក្រុមប្រឹក្សាវិនិយោគកម្ពុជា (CIB) ។ CRDB សំរបសំរួលជំនួយអន្តរជាតិ និងការវិនិយោគជាសាធារណៈ ហើយ CIB ទទួលខុសត្រូវខាងការវិនិយោគឯកជន ។ គួរកត់សំគាល់ថា វិនិយោគិនជាជនជាតិខ្មែរពុំចាំបាច់សុំអាជ្ញាប័ណ្ណពី CDC នោះទេ ហើយអាចចុះបញ្ជីការជាមួយនឹងក្រសួងពាណិជ្ជកម្ម (MOC) ដោយផ្ទាល់តែម្តង ។

ប្រអប់ទី 7.1 សេចក្តីសង្ខេបច្បាប់វិនិយោគសំខាន់ៗ

- ច្បាប់ស្តីពីការវិនិយោគរបស់ព្រះរាជាណាចក្រកម្ពុជា (1994)
- ច្បាប់ស្តីពីវិសោធនកម្មលើច្បាប់វិនិយោគរបស់ព្រះរាជាណាចក្រកម្ពុជា (2003)
- អនុក្រឹត្យលេខ 70 ស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (2001)
- អនុក្រឹត្យស្តីពីវិសោធនកម្មលើអនុក្រឹត្យលេខ 70 (2001)
- អនុក្រឹត្យលេខ 80 ស្តីពីការអនុវត្តច្បាប់ស្តីពីការវិនិយោគរបស់ព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ 50 ស្តីពីវិសោធនកម្មលើអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការវិនិយោគរបស់ព្រះរាជាណាចក្រកម្ពុជា (1997)

CDC ត្រូវបានកំណត់ដោយច្បាប់ថាជា សេវា "ច្រកចេញចូលតែមួយ" ("one-stop" service) ដែលទទួលខុសត្រូវលើសកម្មភាពស្តារ អភិវឌ្ឍ និងការវិនិយោគ (អនុក្រឹត្យលេខ 70 2001) ។ វាជាច្រកដែលអ្នកស្នើគំរោង CDM នៅក្នុងប្រទេសកម្ពុជាត្រូវតែឆ្លងកាត់ ដើម្បីបានអាជ្ញាប័ណ្ណវិនិយោគ ដែលអាចឱ្យគេអាចទទួលបានអត្ថប្រយោជន៍ពីការលើកទឹកចិត្តរបស់រដ្ឋាភិបាល ដូចជាការអនុគ្រោះពន្ធជាដើម ។ ដំណើរការនៃការអនុម័តលើការវិនិយោគត្រូវការរយៈពេលអតិបរមា 28 ថ្ងៃ (CDC 2004) ។ CDC កំពុងស្ថិតនៅក្នុងដំណើរការនៃការរៀបចំរចនាសម្ព័ន្ធឡើងវិញ ដើម្បីឱ្យស្ថាប័ននេះអាចផ្តល់សេវាកម្មយ៉ាងពេញលេញដល់បណ្តាវិនិយោគិន ដែលរួមមាន សេវាកម្មនានាដូចជា : ព័ត៌មាន ការដាក់ពាក្យសុំនិងការអនុម័តលើការវិនិយោគ ពន្ធអាករនិងការលើកលែងពន្ធ ទិដ្ឋាការនិងលិខិតអនុញ្ញាតការងារ និងការចុះបញ្ជីក្រុមហ៊ុន ។ ដំណាក់កាលនានា ដើម្បីទទួលបានអាជ្ញាប័ណ្ណវិនិយោគរបស់ CDC

ត្រូវបានពិពណ៌នាខាងក្រោម (ប្រអប់ទី 7.2)[14] ។ ការសិក្សាលទ្ធភាពត្រូវដាក់រួមគ្នាជាមួយនឹង ពាក្យសុំដែលគួររៀបរាប់ពីចំណុចដូចតទៅ : សំណើទីផ្សារសំរាប់ផលិតផល តំរូវការដែលបានដឹង បច្ចេកទេសកំណត់ថ្លៃនិងការប្រកួតប្រជែងសំរាប់ផលិតផល សំណើបច្ចេកទេសសំរាប់ការផលិតនិងផលិតកម្ម សមាមាត្រនៃការនាំចេញនិងនាំចូលដែលបានស្នើឡើង សមាមាត្រការងារសំរាប់ជនជាតិខ្មែរនិងបរទេស ការវិភាគហិរញ្ញវត្ថុនិងបច្ចេកទេស ប្រាក់ចំណូលប៉ាន់ស្មាន និងការសិក្សាអំពីហេតុប៉ះពាល់លើបរិស្ថាន (រួមទាំង ផែនការលំអិតសំរាប់ការធ្វើប្រព្រឹត្តិកម្ម និងចោលសំណល់) និងសំណើផែនការអភិវឌ្ឍធនធានមនុស្ស ។

រដ្ឋាភិបាលពុំទាន់បានកំណត់បែបបទគ្រប់គ្រងប្រតិបត្តិការនានា ដែលអ្នកទិញបរទេសមានចំណាប់អារម្មណ៍ចង់កាន់កាប់ដោយផ្ទាល់មុខលើឥណទានកាត់បន្ថយការបញ្ចេញឧស្ម័នដែលបានបញ្ជាក់ (CER) ឬទំរង់ឥណទានកាបូនផ្សេងទៀត ដោយពុំវិនិយោគនៅក្នុងការរៀបចំគំរោងក្នុងប្រទេសកម្ពុជា នៅឡើយទេ ។ ឥណទានកាបូនទំនងជាត្រូវបានចាត់ទុកថាជាទំនិញសំរាប់ការនាំចេញ ហើយដោយសារតែមូលហេតុនេះ ត្រូវបានលើកលែងពីពន្ធលើតំលៃបន្ថែម (VAT) ។ លើសពីនេះទៅទៀត ពុំមានលក្ខខណ្ឌជាក់លាក់ ដែលតំរូវឱ្យអ្នកទិញឥណទានកាបូន ចូលរួមពាក់ព័ន្ធផ្នែកហិរញ្ញវត្ថុ នៅក្នុងការរៀបចំគំរោង នៅក្នុងប្រទេសខ្លួនឯងនោះទេ ។

ប្រអប់ទី 7.2 ដំណាក់កាលដើម្បីទទួលបានអាជ្ញាប័ណ្ណវិនិយោគក្នុងប្រទេសកម្ពុជា

1. ដាក់ពាក្យសុំ ទៅកាន់ក្រុមប្រឹក្សាវិនិយោគកម្ពុជា (CIB) នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ដែលរួមមានលិខិតសុំ លក្ខន្តិកៈរបស់ក្រុមហ៊ុន និងការសិក្សាលទ្ធភាព ។
2. ជួបប្រជុំជាមួយនឹងសមាជិក CIB/CDC ដើម្បីផ្តល់ព័ត៌មានបន្ថែម នៅអំឡុងដំណើរការនៃការពិនិត្យឡើងវិញ ។
3. ការឯកភាពដោយ CIB/CDC ក្នុងរយៈពេល 28 ថ្ងៃ ។
4. ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ជាមួយនឹងក្រសួងពាណិជ្ជកម្ម ។

## *7.2 ការកំហិតនៃការវិនិយោគដែលពាក់ព័ន្ធជាមួយនឹងគំរោង CDM*

ពលរដ្ឋ និងក្រុមហ៊ុនបរទេសពុំអាចមានកម្មសិទ្ធិដីធ្លីនៅក្នុងប្រទេសកម្ពុជាបានឡើយ ។ ដូច្នេះ កម្មសិទ្ធិលើដីធ្លីសំរាប់គោលបំណងអនុវត្តគំរោងវិនិយោគត្រូវផ្តល់ឱ្យជាផ្លូវការដល់បុគ្គលដែលមានសញ្ជាតិកម្ពុជា ឬដល់ក្រុមហ៊ុន ឬអង្គភាពកម្ពុជា ។ យ៉ាងណាក៏ដោយ ការប្រើប្រាស់ដីធ្លីដោយវិនិយោគិនបរទេស ត្រូវបានអនុញ្ញាតតាមរូបភាពកិច្ចសន្យាជួលរយៈពេលវែង និងកិច្ចសន្យាជួលរយៈខ្លីមានកំរិត ដែលអាចបន្តថ្មីបាន[15] ។

ការវិនិយោគលើឈើអារ ឈើបន្ទះ ក្តារបន្ទះ និងផលិតផលធ្វើពីឈើ ក៏ដូចជាការប្រើប្រាស់ឈើក្នុងស្រុកជាវត្ថុធាតុដើម ត្រូវបានបិទចំពោះទាំងវិនិយោគិនបរទេស និងវិនិយោគិនជាតិ ។

---

13. បែបទពាក្យសុំសំរាប់អាជ្ញាប័ណ្ណ CIB មាននៅក្នុងសេចក្តីបន្ថែម ។

14. ដូចដែលបានចែងនៅក្នុងច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីការវិនិយោគ ឆ្នាំ 2003 ។

## *7.3 ច្បាប់បរិស្ថាន*

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឆ្នាំ 1996 និងអនុក្រឹត្យដែលពាក់ព័ន្ធ បង្កើតជាក្របខ័ណ្ឌសំរាប់កិច្ចការពារគុណភាពបរិស្ថាន និងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន របស់គំរោងដែលបានស្នើឡើង (ប្រអប់ទី 7.3) ។ ច្បាប់នេះចែងថា គ្រប់ធនធានធម្មជាតិទាំងអស់របស់ព្រះរាជាណាចក្រកម្ពុជា ដូចជាប្រព័ន្ធអេកូឡូស៊ី និងធនធានធម្មជាតិ អាចយកមកប្រើប្រាស់ តាមវិធីសមហេតុសមផល និងធានាបាននូវនិរន្តភាព ដោយរក្សាការអភិវឌ្ឍប្រកបដោយចិរភាព ជាគោលការណ៍ចំបង ។

យោងទៅតាមលក្ខណៈ និងទំហំនៃសកម្មភាពរបស់វា គំរោង CDM ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជាត្រូវបានតំរូវដោយច្បាប់ ឱ្យធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) (តារាងទី 7.1) ។ អនុក្រឹត្យលេខ 72 ចេញឆ្នាំ 1999 ចែងលំអិតពីបទបញ្ញត្តិនៃដំណើរការ EIA និងបញ្ជីគំរោងនានា ដែលត្រូវធ្វើ EIA ។ ក្រសួងបរិស្ថានទទួលខុសត្រូវលើការអនុវត្តអនុក្រឹត្យស្តីពី EIA ។ វិនិយោគិននឹងអាចទទួលបានព័ត៌មានចាំបាច់ ដែលទាក់ទងនឹង CDM និង EIA ពី DNA របស់កម្ពុជា នៅការិយាល័យប្រែប្រួលអាកាសធាតុរបស់ក្រសួងបរិស្ថានកម្ពុជា ។

ប្រអប់ទី 7.3 សេចក្តីសង្ខេបនៃច្បាប់បរិស្ថានសំខាន់ៗរបស់ប្រទេសកម្ពុជា

- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (1996)
- អនុក្រឹត្យលេខ 72 ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (1999)
- អនុក្រឹត្យលេខ 27 ស្តីពីការគ្រប់គ្រងការបំពុលទឹក (1999)
- អនុក្រឹត្យលេខ 36 ស្តីពីការគ្រប់គ្រងសំណល់រឹង (1999)
- អនុក្រឹត្យលេខ 42 ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង (2000)

គំរោងថាមពល CDM ដែលរួមមានរោងចក្រផលិតថាមពលមានសមត្ថភាពផលិតអគ្គិសនីច្រើនជាង 5 MW និងសំរាប់ស្ថានីយ៍វារីអគ្គិសនីដែលមានសមត្ថភាព 1 MW ត្រូវតែមាន EIA ។ ដូច្នេះ សូម្បីតែគំរោង វារីអគ្គិសនីខ្នាតតូច ក៏ត្រូវការ EIA មួយដែរ ។ គំរោងចាប់យកមេតាននៅកន្លែងចាក់សំរាម ទោះបីជាមានសមត្ថភាពប៉ុណ្ណាក៏ដោយ ត្រូវបានចាត់ចូលទៅក្នុងប្រភេទរោងចក្រកែច្នៃសំណល់ ដូច្នេះតំរូវឱ្យមាន EIA ។ គ្រប់គំរោងផលិតថាមពលដទៃទៀតទាំងអស់ ដែលមានសមត្ថភាពក្រោម 5 MW មិនចាំបាច់មាន EIA នោះទេ ។

គំរោងដាំព្រៃ និងស្តារព្រៃ CDM ដែលមានទំហំតិចជាង 10.000 ហិចតា មិនទំនងជាត្រូវមាន EIA នោះទេ ព្រោះគំរោងទាំងនោះ ចូលទៅក្នុងប្រភេទសកម្មភាពលើដីកសិកម្ម និងដីកសិ-ឧស្សាហកម្ម។ ប៉ុន្តែ ប្រសិនបើត្រូវកាប់ព្រៃជាង 500 ហិកតាសំរាប់ធ្វើគំរោង នោះគំរោងនេះត្រូវតែធ្វើ EIA ។ គំរោងព្រៃឈើ CDM និង ការកែច្នៃក្រដាសរួមបញ្ចូលគ្នា ត្រូវមាន EIA សំរាប់ផ្នែកកែច្នៃក្រដាសរបស់គំរោងទាំងនោះ ។

តារាងទី 7.1 បញ្ជីគំរោង CDM សក្តានុពល ដែលត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

| គំរោង | ទំហំ/សមត្ថភាព |
|---|---|
| រោងចក្រក្រដាស | គ្រប់ទំហំទាំងអស់ |
| ការកែច្នៃក្រដាស | គ្រប់ទំហំទាំងអស់ |
| ការកែច្នៃសំណល់ | គ្រប់ទំហំទាំងអស់ |
| រោងចក្រថាមពល | ≥ 5 MW |
| ថាមពលវារីអគ្គិសនី | ≥ 1 MW |
| ការកាប់ព្រៃឈើ | ≥ 500 ហិកតា |
| ដីព្រៃ | ≥ 500 ហិកតា |
| ដីកសិកម្ម និងកសិ-ឧស្សាហកម្ម | ≥ 10,000 ហិកតា |

បន្ថែមលើអនុក្រឹត្យស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន មានអនុក្រឹត្យចំនួន 3 ទៀតស្តីពីការគ្រប់គ្រងការបំពុលទឹក ការត្រួតពិនិត្យបំពុលខ្យល់និងការរំខានដោយសំលេង និងការគ្រប់គ្រងសំណល់រឹង ។ រាល់គំរោង CDM ទាំងអស់ត្រូវអនុលោមទៅតាមបទបញ្ញត្តិរបស់អនុក្រឹត្យទាំងបីនេះ ។ អនុក្រឹត្យស្តីពីការគ្រប់គ្រងការបំពុលទឹក ចែងលំអិតអំពីបទដ្ឋានសារធាតុគ្រោះថ្នាក់សំរាប់សំណល់រាវ និងកំរិតអនុញ្ញាតសំរាប់ការបញ្ចេញចោលសារធាតុបំពុលទៅក្នុងទឹកសាធារណៈ ។ អនុក្រឹត្យស្តីពីការគ្រប់គ្រងការបំពុលខ្យល់ និងការរំខានដោយសំលេង ចែងលំអិតស្រដៀងគ្នាអំពីបទដ្ឋានគុណភាពខ្យល់ជុំវិញ និងកំរិតអតិបរមានៃការបញ្ចេញពីប្រភពចល័ត និងអចល័តទៅក្នុងខ្យល់ជុំវិញ ។ អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង គ្រប់គ្រងលើសំណល់គ្រោះថ្នាក់ដែលកើតឡើងដោយសារសកម្មភាពផ្សេងៗ ដូចជា សំណល់ភក់ពីការបញ្ចេញសំណល់រាវ និងដំណើការផលិតកម្មរបស់រោងចក្រ សំណល់ចំហេះពីរោងចក្រថាមពលដើរដោយធ្យូងថ្ម និងសំណល់សារធាតុគីមីកសិកម្ម ។

## *7.4 បទបញ្ញត្តិផ្សេងៗទៀត ដែលអាចយកមកអនុវត្តចំពោះគំរោងថាមពល CDM*

ច្បាប់អគ្គិសនីឆ្នាំ 2001 របស់ព្រះរាជាណាចក្រកម្ពុជា អាចអនុវត្តបានចំពោះគំរោង CDM ដែលផលិតអគ្គិសនី ។ ច្បាប់នេះចែងអំពីគោលការណ៍នានា ដែលគ្រប់គ្រងលើប្រតិបត្តិការរបស់ឧស្សាហកម្មថាមពលអគ្គិសនី និងសកម្មភាពរបស់អ្នកទទួលអាជ្ញាប័ណ្ណ ដែលផ្គត់ផ្គង់សេវាថាមពលអគ្គិសនី ។ គោលការណ៍ទាំងនេះ ត្រូវបានចែងនៅក្នុងមាត្រាទី 2 របស់ច្បាប់នេះ ដូចតទៅ : (i) ការការពារសិទ្ធិអតិថិជនអ្នកប្រើប្រាស់ ដើម្បីទទួលបានការផ្គត់ផ្គង់សេវាកម្មថាមពលអគ្គិសនីដែលគ្រប់គ្រាន់ និងដែលអាចជឿទុកចិត្តបាន ក្នុងតំលៃសមរម្យ (ii) ការជួយឱ្យមានការរីកចំរើនដល់កម្មសិទ្ធិឯកជនលើរោងចក្រ សំរាប់ការផ្តល់សេវាកម្មថាមពលអគ្គិសនី និង (iii) ការបង្កើតការប្រកួតប្រជែងនៅកន្លែង ដែលអាចធ្វើទៅបាន នៅក្នុងវិស័យថាមពលអគ្គិសនី ។

ច្បាប់អគ្គិសនីក៏បានបង្កើតផងដែរ នូវស្ថាប័នមួយ ដើម្បីគ្រប់គ្រងសេវាកម្មថាមពលអគ្គិសនី : អាជ្ញាធរអគ្គិសនីកម្ពុជា (EAC) ។ នៅក្នុងមាត្រាទី 5 នៃច្បាប់នេះ អ្នកផ្គត់ផ្គង់សេវាកម្មថាមពលនីមួយៗ ត្រូវមានអាជ្ញាប័ណ្ណ ដែលចេញដោយ EAC ដែលជាស្ថាប័នគ្រប់គ្រងស្វយ័ត ។ ស្ថាប័ននេះមានភារកិច្ចចេញ ពិនិត្យឡើងវិញ ពន្យារពេល លុបចោល ឬបដិសេធអាជ្ញាប័ណ្ណ សំរាប់ការផ្គត់ផ្គង់សេវាកម្មអគ្គិសនី ។ ស្ថាប័ននេះអនុម័តលើថ្លៃប្រើប្រាស់អគ្គិសនី លើកលែងតែថ្លៃប្រើប្រាស់ទាំងឡាយណា "ដែលត្រូវបានបង្កើតឡើង យោងទៅតាមស្ថានភាពប្រកួតប្រជែងលើទីផ្សារ" ។ ច្បាប់នេះក៏បានប្រគល់ភារកិច្ចឱ្យ EAC ធានាឱ្យបានច្បាស់ថា ការផ្តល់សេវាកម្មត្រូវបានធ្វើឡើង "ដោយតម្លាភាព" និងថា សាធារណៈជនត្រូវបានជូនដំណឹងអំពីកិច្ចការនានា ដែលស្ថិតនៅក្នុងភារកិច្ចរបស់ស្ថាប័ននេះ ។ ដូច្នេះ ថ្លៃប្រើប្រាស់អគ្គិសនីពុំត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាលឡើយ ប៉ុន្តែត្រូវបានកំណត់ដោយទីផ្សារ ។ ករណីលើកលែងគឺថ្លៃប្រើប្រាស់អគ្គិសនីជាលក្ខណៈសង្គម ឬលក្ខណៈជាជំនួយ ដែលត្រូវបានប្រើប្រាស់ដោយអគ្គិសនីកម្ពុជា នៅពេលគិតថ្លៃប្រើប្រាស់ចំពោះគ្រួសារដែលមានចំណូលទាប ។

មាត្រាទី 29 របស់ច្បាប់អគ្គិសនី ចែងពីអាជ្ញាប័ណ្ណ 8 ប្រភេទផ្សេងៗគ្នា : (1) អាជ្ញាប័ណ្ណផលិត (2) អាជ្ញាប័ណ្ណតបណ្តាញ (3) អាជ្ញាប័ណ្ណបញ្ជូន (4) អាជ្ញាប័ណ្ណចែកចាយ (5) អាជ្ញាប័ណ្ណលក់ដុំ (6) អាជ្ញាប័ណ្ណលក់រាយ (7) អាជ្ញាប័ណ្ណធ្វើអាជីវកម្មបន្ត និង (8) អាជ្ញាប័ណ្ណរួម ។ អ្នកទទួលអាជ្ញាប័ណ្ណធ្វើអាជីវកម្មធ្វើប្រតិបត្តិការ ដោយយោងទៅតាមកិច្ចព្រមព្រៀងធ្វើអាជីវកម្មបន្ត ជាមួយនឹងអ្នកទទួលអាជ្ញាប័ណ្ណដែលមានស្រាប់ ។ អាជ្ញាប័ណ្ណរួម គឺជាការដាក់បញ្ចូលគ្នានៃគ្រប់ប្រភេទ ឬប្រភេទមួយចំនួននៃអាជ្ញាប័ណ្ណ ។ គំរោងថាមពល CDM ដែលផលិតអគ្គិសនី ត្រូវមានអាជ្ញាប័ណ្ណផលិត ។

វិបសាយរបស់ EAC ដែលមាននៅក្នុងសេចក្តីបន្ថែម មានបង្ហាញពីសេចក្តីណែនាំចំពោះវិនិយោគគិន ដែលចង់ស្នើសុំអាជ្ញាប័ណ្ណផលិត អាជ្ញាប័ណ្ណចែកចាយ ឬអាជ្ញាប័ណ្ណរួម[16] ។ ដើម្បីសុំអាជ្ញាប័ណ្ណផលិត តំរូវឱ្យមានច្បាប់ចំលងនៃកិច្ចព្រមព្រៀងជាវថាមពល ជាមួយនឹងអ្នកទិញថាមពលសក្តានុពល ។

## *7.5 បទបញ្ញត្តិ ដែលអាចយកមកអនុវត្តចំពោះគំរោងព្រៃឈើ CDM*

បរិធានច្បាប់ចំនួន 2 អាចយកមកអនុវត្តបានចំពោះគំរោងព្រៃឈើ CDM : ច្បាប់ព្រៃឈើ (2002) និងសេចក្តីព្រាងអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ (2003) ។

ច្បាប់ព្រៃឈើគ្របដណ្តប់លើការគ្រប់គ្រង ការទាញយកប្រយោជន៍ ការប្រើប្រាស់ ការអភិវឌ្ឍ និងការបំរុងទុកព្រៃឈើទាំងអស់ មិនថាព្រៃឈើដុះដោយធម្មជាតិ ឬដុះដោយដាំ ដូច្នេះ ច្បាប់នេះពាក់ព័ន្ធជាមួយនឹងសកម្មភាពអាងស្រូបកាបូន CDM ។ គោលដៅចំបងរបស់ច្បាប់នេះ គឺត្រូវធានាឱ្យមានការគ្រប់គ្រងព្រៃប្រកបដោយចីរភាព សំរាប់ជំនាន់មនុស្សនាពេលបច្ចុប្បន្ន និងនាពេលអនាគត ដោយគិតទៅលើអត្ថប្រយោជន៍ផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាន ដូចជាការអភិរក្សជីវៈចំរុះ និងការរក្សាកេរដំណែលវប្បធម៌ ជាដើម ។ ច្បាប់ចែងថា ការចូលរួមរបស់

15. ពាក្យសុំ អាចរកបានពីអាជ្ញាធរអគ្គិសនីកម្ពុជា (សូមមើលសេចក្តីបន្ថែមទី VI) ។

ប្រជាពលរដ្ឋទូទៅនៅក្នុងសកម្មភាពស្តារព្រៃ គួរត្រូវបានជំរុញតាមរយៈការកៀរគរសហគមន៍ ។ ការដាំដើមឈើលើដីឯកជន អាចធ្វើឡើងដោយក្រុមហ៊ុនឯកជន។ មាត្រាទី 47 ចែងថា : "អ្នកដែលដាំដើមឈើលើដីរដ្ឋ ឬដីឯកជន មានសិទ្ធិរក្សា អភិវឌ្ឍ ប្រើប្រាស់ លក់ ឬចែកចាយផលិតផលរបស់ដើមឈើទាំងនោះ" ។ វិធាន និងបទបញ្ញត្តិបន្ថែម ដែលពាក់ព័ន្ធ ជាមួយនឹងហេតុប៉ះពាល់សង្គម និងបរិស្ថានជាសក្តានុពល របស់ពូជឈើដែលបានជ្រើសរើស នឹងត្រូវបង្កើតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

អនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើឆ្នាំ 2003 បង្កើតជាក្របខ័ណ្ឌច្បាប់ សំរាប់ការបង្កើត ការប្រើប្រាស់ និងការគ្រប់គ្រងធនធានព្រៃឈើ ដោយសហគមន៍ ។ ដូច្នេះ អនុក្រឹត្យនេះគ្របដណ្តប់លើគំរោងអាងស្រូបកាបូន CDM ដែលអនុវត្តដោយប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដែលរួមទាំងគំរោងនានា ដែលសមស្របសំរាប់វិធីសាស្ត្រងាយ ។ នៅក្នុងអនុក្រឹត្យនេះ សហគមន៍ត្រូវបានគេឱ្យនិយមន័យថា ជា "ក្រុមប្រជាពលរដ្ឋនៅក្នុងភូមិមួយ ឬច្រើន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលចែករំលែកផលប្រយោជន៍សង្គម វប្បធម៌ ប្រពៃណី និងសេដ្ឋកិច្ចរួម នៅក្នុងការប្រើប្រាស់ប្រកបដោយចីរភាពលើដីធនធានធម្មជាតិ ដែលពួកគេរស់នៅក្នុង ឬនៅក្បែរ សំរាប់គោលបំណងចិញ្ចឹមជីវិត និងការលើកកំពស់ជីវភាពរស់នៅ" ។ " កិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ " មាននិយមន័យថា ជា កិច្ចព្រមព្រៀងលាយលក្ខណ៍អក្សរ រវាងសហគមន៍ និងអាជ្ញាធររដ្ឋ ដែលទទួលខុសត្រូវលើការពិនិត្យឃ្លាំមើល និងវាយតំលៃសកម្មភាពសហគមន៍ព្រៃឈើ និងធានាឱ្យមានការប្រើប្រាស់ធនធានព្រៃឈើប្រកបដោយចីរភាព ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកទទួលខុសត្រូវលើការគ្រប់គ្រងព្រៃសហគមន៍ ដែលនៅខាងក្រៅតំបន់អភិរក្ស និងតំបន់គ្រប់គ្រងអង្គរ ដែលតាមលំដាប់លំដោយ ស្ថិតនៅក្រោមវង្វង់សមត្ថកិច្ចរបស់ក្រសួងបរិស្ថាន និងអាជ្ញាធរការពារនិងគ្រប់គ្រងអង្គរ និងតំបន់សៀមរាប (អាជ្ញាធរអប្សរា) ។ នៅក្រោមច្បាប់នេះ សហគមន៍ទទួលខុសត្រូវលើការបង្កើតផែនការគ្រប់គ្រងព្រៃឈើ និងវិធាននានា សំរាប់ធានាការប្រើប្រាស់ប្រកបដោយចីរភាព សិទ្ធិប្រើប្រាស់ ថ្លៃដែលត្រូវបង់ដោយអ្នកប្រើប្រាស់ ការចែករំលែកផលប្រយោជន៍ និងការផាកពិន័យសំរាប់បទល្មើស ។ សហគមន៍ទាំងនោះមានសិទ្ធិទាញយកប្រយោជន៍ និងលក់ផលិតផលពីឈើពេញចំណាស់ និងអនុផលឈើ ។ មានឱសានវាទលើការទាញយកប្រយោជន៍ពីព្រៃឈើ នៅក្នុងរយៈពេល 5 ឆ្នាំដំបូងនៃការឯកភាពលើកិច្ចព្រមព្រៀងព្រៃសហគមន៍ ។ ច្បាប់នេះដាក់បញ្ចូលអនុផលព្រៃឈើដូចតទៅ : ឈើងាប់ ផ្លែឈើព្រៃ ផលិតផលពីឃ្មុំ និងជ័រ ។ កិច្ចព្រមព្រៀងសហគមន៍ព្រៃឈើនៅចូលជាធរមានសំរាប់រយៈពេល 15 ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការឯកភាព ហើយអាចបន្តថ្មីបាន ។

សហគមន៍ព្រៃឈើនៅក្នុងប្រទេសកម្ពុជា ដូចដែលបានពិភាក្សានៅក្នុងវគ្គខាងលើ មានមុនពេលការបង្កើតអនុក្រឹត្យនេះ ដែលមានគោលបំណងសំខាន់ ផ្តល់តួនាទីគ្រប់គ្រងដល់ស្ថាប័នរដ្ឋាភិបាល និងបង្កើតមូលដ្ឋានច្បាប់សំរាប់សិទ្ធិរបស់សហគមន៍ ។ មួយភាគធំនៃគំនិតផ្តួចផ្តើមបង្កើតសហគមន៍ព្រៃឈើ នៅតែនាំមុខដោយអ្នកផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ។

រូបភាពទី 7.1 សេចក្តីសង្ខេបអំពីច្បាប់សំខាន់ៗ ដែលពាក់ព័ន្ធជាមួយនឹងគំរោង CDM នៅក្នុងប្រទេសកម្ពុជា



# 8. បញ្ហាហិរញ្ញវត្ថុ និងសារពើពន្ធ

## *8.1 ប្រព័ន្ធហិរញ្ញវត្ថុ*

ប្រទេសកម្ពុជាគឺជាប្រទេសសេដ្ឋកិច្ចសាច់ប្រាក់ ដោយមានអន្តរកម្មធនាគារនៅមានកំរិត (ធនាគារពិភពលោក 2004) ហើយប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសនេះ នៅពុំទាន់មានការអភិវឌ្ឍនៅឡើយ ។ ធនាគារក្រោយសង្គ្រាមដំបូងត្រូវបានបង្កើតឡើង នៅដើមទសវត្សរ៍ឆ្នាំ 1990 ។ វិស័យហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន រួមមានធនាគារជាតិនៃកម្ពុជា ធនាគារពាណិជ្ជកម្មចំនួន 13 ធនាគារឯកទេសអភិវឌ្ឍន៍ជនបទចំនួន 4 ស្ថាប័នមីក្រូហិរញ្ញវត្ថុចំនួន 10 និងក្រុមហ៊ុនធានារ៉ាប់រងចំនួន 4 (ICC 2003) ។ លើកលែងតែអង្គការមីក្រូឥណទានចេញ ស្ថាប័នហិរញ្ញវត្ថុភាគច្រើនមានទីតាំងនៅទីក្រុងភ្នំពេញ ។ ធនាគារធំជាងគេចំនួន 5 រួមគ្នា មានទ្រព្យសម្បត្តិធនាគារ និងប្រាក់បញ្ញើច្រើនជាង 50 ភាគរយនៃទ្រព្យសម្បត្តិ និងប្រាក់បញ្ញើសរុបរបស់ធនាគារទាំងអស់ ។ ប្រាក់បញ្ញើជាដុល្លារសហរដ្ឋអាមេរិចដែលជាមធ្យោបាយដោះដូរចំបងនៅក្នុងប្រទេសកម្ពុជា តំណាងឱ្យជាង 90 ភាគនៃគ្រប់ប្រាក់បញ្ញើទាំងអស់ ។ កម្ចីនិងបញ្ញើធនាគារតំណាងឱ្យ 8 និង 10 ភាគរយ តាមលំដាប់លំដោយ នៃ GDP ដែលជា GDP ទាបជាងគេមួយនៅក្នុងពិភពលោក ។ នាពេលបច្ចុប្បន្ននេះ ពុំមានទីផ្សារភាគហ៊ុន ឬការដោះដូរមូលធនប័ត្រ នៅក្នុងប្រទេសកម្ពុជានោះទេ ។ ទឹកប្រាក់មួយភាគធំនៅក្នុងសេដ្ឋកិច្ច ត្រូវបានកាន់កាប់នៅខាងក្រៅប្រព័ន្ធហិរញ្ញវត្ថុផ្លូវការ ដែលត្រូវបានចាត់ចំណាត់ថ្នាក់ថាមានថ្លៃដើមប្រតិបត្តិការខ្ពស់ គុណភាពទ្រព្យសម្បត្តិខ្សោយ និងទំនុកចិត្តពីសាធារណជននៅទាប (ADB 2001) ។

ជាទូទៅ ក្រុមហ៊ុនកម្ពុជាពុំទទួលបានអត្ថប្រយោជន៍ពីការផ្តល់ហិរញ្ញប្បទានពីខាងក្រៅនោះទេ (ធនាគារពិភពលោក 2004) ។ ធនាគារពាណិជ្ជកម្មក្នុងស្រុក ផ្តល់តែ 2.2 ភាគរយនៃទុនបង្វិលសរុប និង 2.8 ភាគរយ នៃទុនវិនិយោគសរុបតែប៉ុណ្ណោះ ។ ផ្ទុយទៅវិញ បណ្តាញគ្រួសារ និងមិត្តភ័ក្រ្ត ផ្តល់ហិរញ្ញប្បទានក្រុមហ៊ុនច្រើនជាងមួយភាគបួន ហើយក្រុមហ៊ុនខ្នាតតូច និងមធ្យម ពឹងអាស្រ័យលើគ្រួសារ និងមិត្តភ័ក្រ្ត ច្រើនជាងក្រុមហ៊ុនធំៗ ។ សូម្បីតែក្រុមហ៊ុនដែលវិនិយោគពីបរទេស ក៏ពឹងអាស្រ័យលើបណ្តាញទាំងអស់នេះ ដើម្បីទទួលបានស្ទើរតែ 10 ភាគរយនៃទុនបង្វិល និងទុនវិនិយោគរបស់ពួកគេដែរ ។ សកម្មភាពនេះកើតឡើង ដោយសារតែមូលហេតុពីរយ៉ាង ។ ទីមួយ អត្រាការប្រាក់លើកម្ចីពាណិជ្ជកម្ម ជារឿយៗលើសពី 20 ភាគរយ ហើយមានរយៈពេលកម្ចីខ្លី ។ គំលាតរវាងអត្រាការប្រាក់កម្ចី និងអត្រាការប្រាក់បញ្ញើ គឺប្រហែលជា 13 ភាគរយ (ADB 2001) ។ ធនាគារចូលចិត្តចេញកម្ចីរយៈពេលខ្លីពី 3 ទៅ 6 ខែ ដែលងាយស្រួលប្រមូលត្រលប់មកវិញ ។ បញ្ហានេះកើតឡើង ដោយសារតែមានការប្រកួតប្រជែងតិចតួចនៅក្នុងវិស័យធនាគារ ហើយមានហានិភ័យនៃការមិនសងកម្ចីធំៗខ្ពស់ ។ កង្វះខាតស្តង់ដាហិរញ្ញវត្ថុ គណនេយ្យ និងសវនកម្ម ក៏ដូចជាអវត្តមាននៃប្រព័ន្ធចុះបញ្ជីបន្ថែម បង្កើនហានិភ័យ និងចំណាយប្រតិបត្តិការ ។ ដូច្នេះ មានតែក្រុមហ៊ុនដែលមានឈ្មោះល្បី និងធ្លាប់ទទួលបានជោគជ័យតែប៉ុណ្ណោះ ដែលទទួលបានអត្ថប្រយោជន៍ពីកម្ចីធនាគារ ។

ទីពីរ ធនាគារត្រូវការការបង្ហាញព័ត៌មានហិរញ្ញវត្ថុ ដូចជា ទ្រព្យសម្បត្តិ និងបំណុល ពេញលេញ ។ ប្រការនេះអាចធ្វើឱ្យក្រុមហ៊ុនដែលរក្សាអាថ៌កំបាំងព័ត៌មានរបស់ខ្លួន ពុំអាចដាក់ពាក្យសុំខ្ចីធនាគារបានឡើយ ។

ទាំងអ្នកផ្តល់ជំនួយ ទាំងរដ្ឋាភិបាល បានទទួលស្គាល់ថា ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុទន់ខ្សោយរបស់ប្រទេសកម្ពុជាជាកត្តារារាំងការអភិវឌ្ឍសេដ្ឋកិច្ច (ADB 2001; UNCTAD និង ICC 2003; ធនាគារពិភពលោក 2004) ។ ដោយមានការគាំទ្រពីអន្តរជាតិ ប្រទេសកម្ពុជាបានបង្កើតផែនការលំអិតវិស័យហិរញ្ញវត្ថុ ពីឆ្នាំ 2001 ដល់ 2010 ។ បើទោះបីជាមានរបាំងរាំងស្ទះយ៉ាងណាក៏ដោយ ក៏ប្រព័ន្ធធនាគារអាចផ្តល់ឱ្យវិនិយោគិនបរទេសនូវសេវាកម្មហិរញ្ញវត្ថុជាច្រើនផងដែរ ។ ពុំមានការកំហិតលើប្រតិបត្តិការរូបិយប័ណ្ណបរទេស ដូចជាការផ្ទេរ និងការទូទាត់រូបិយប័ណ្ណបរទេសគ្រប់ប្រភេទឡើយ ។ លើសពីនេះទៅទៀត ពុំមានលក្ខខណ្ឌតំរូវឱ្យរាយការណ៍សំរាប់វិនិយោគគិន ដែលផ្ញើ និងទទួលលុយជាអន្តរជាតិនោះទេ ។ គោលដៅរួមរបស់ផែនការលំអិតនេះ គឺត្រូវបង្កើតឱ្យមាននូវសមាសភាគនៃប្រព័ន្ធហិរញ្ញវត្ថុទីផ្សារដែលមានលក្ខណៈល្អប្រសើរ ឱ្យបានមុនឆ្នាំ 2010 ។ កំលាំងចលករសំខាន់បំផុត សំរាប់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា គឺសមត្ថភាពប្រកួតប្រជែង ដែលត្រូវមានការគាំទ្រពីប្រព័ន្ធច្បាប់មួយដែលមានតម្លាភាពជាងមុន ។ ប្រព័ន្ធហិរញ្ញវត្ថុរួម និងដែលមានសមត្ថភាពប្រកួតប្រជែងខ្លាំងក្លា នឹងបង្កើតឱ្យមាននូវផលិតផលផ្សេងៗជាច្រើនប្រភេទ ដល់អតិថិជន ដោយរួមទាំងប្រជាពលរដ្ឋកម្ពុជាមកពីស្រទាប់សេដ្ឋកិច្ចទាបផងដែរ ។ ផែនការលំអិតនេះព្យាករណ៍ទុកជាមុន អំពីកំណើនការកៀរគរធនធាននៅក្នុងស្រុក និងការវិនិយោគឆ្ពោះទៅរក កំណើន ហើយដោយហេតុនេះ អាចបញ្ចុះជាលំដាប់នូវគំលាតរវាងអត្រាការប្រាក់កម្ចី និងអត្រាការប្រាក់បញ្ញើ ។ ល្បឿននៃការបញ្ចុះនេះនឹងត្រូវបានកំណត់ដោយ : (1) ការបន្តស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច (2) ការកែលំអហេដ្ឋារចនា-សម្ព័ន្ធច្បាប់ និងហិរញ្ញវត្ថុ និង (3) កំណើននៃការប្រកួតប្រជែងនៅក្នុងចំណោមធនាគារ (ADB 2001) ។ លើសពី នេះទៅទៀត ការកាត់បន្ថយភាពមិនប្រាកដប្រជានៅក្នុងប្រព័ន្ធច្បាប់ និងការបង្កើនប្រសិទ្ធភាព អាចបង្កលក្ខណៈ ឱ្យធនាគារបង្កើនរយៈពេលផ្តល់កម្ចីជាមធ្យមរបស់ខ្លួន ។ នៅក្នុងការគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់ខ្លួន រដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាធ្វើកំណែទំរង់ប្រព័ន្ធច្បាប់របស់ខ្លួន ក្នុងគោលបំណងធានាឱ្យបាននូវសុវត្ថិភាពនៃកិច្ចការជំនួញ ការធ្វើភតិសន្យា និងភាពពុំអាចសងបំណុលបាន ។

ពាក់ព័ន្ធជាមួយនឹង CDM និងកិច្ចការប្រែប្រួលអាកាសធាតុ ការយល់ដឹងរបស់ស្ថាប័នហិរញ្ញវត្ថុនៅក្នុងស្រុក នៅមានកំរិតទាប ហើយនៅមានការមន្ទិលសង្ស័យនៅក្នុងដំណាក់កាលនេះ ដែលថាអ្នករៀបចំគំរោង CDM នឹងអាចទទួលបាននូវលក្ខខណ្ឌហិរញ្ញវត្ថុដែលមានលក្ខណៈសមប្រកបជាងអ្នករៀបចំគំរោងមិនមែន CDM ។ អត្រាទទួលបានមកវិញផ្នែកហិរញ្ញវត្ថុ ការគិតពិចារណាទៅលើហានិភ័យ និងប្រភេទសកម្មភាព គឺជាកត្តាសំខាន់ៗសំរាប់ប្រតិបត្តិការអន្តរកម្មធនាគារនៅក្នុងស្រុក ។ គំរោងថាមពលប្រកបដោយចីរភាព មិនថាជាប្រសិទ្ធភាពថាមពល ឬថាមពលកកើតឡើងវិញនោះទេ អាចត្រូវបានចាត់ទុកថាជាការងារថ្មីហើយប្លែក នៅពេលធ្វើការប្រៀបធៀបជាមួយនឹងការវិនិយោគដែលមានលក្ខណៈបែបប្រពៃណីជាង ។ ស្ថានភាពនេះមិនមែនពិសេសតែចំពោះប្រទេសកម្ពុជានោះទេ

ព្រោះភាពស្មុគស្មាញនៃការផ្តល់ហិរញ្ញប្បទាន CDM ត្រូវការគំរូនៃអន្តរកម្មធនាគារដែលមានលក្ខណៈឯកទេស និង ទំនើប ។ ទោះបីជាផែនការលំអិតវិស័យហិរញ្ញវត្ថុព្យាករណ៍ទុកជាមុន អំពីការរីកចំរើនជាដំណាក់ៗ តាមរយៈការ បង្កើនការកៀរគរធនធាន និងការបញ្ចុះអត្រាការប្រាក់យ៉ាងណាក៏ដោយ ក៏ផលប៉ះពាល់មកលើការរៀបចំគំរោង CDM ដោយផ្ទាល់ នៅពុំទាន់បានកំណត់នៅឡើយទេ ។ ដូច្នេះ បើគិតតាមទស្សនៈផលបន្ថែម អាចមានអំណះ អំណាងមួយលើកឡើងថា អសមត្ថភាពក្នុងការធានាឱ្យមានការផ្តល់មូលនិធិដោះបំណុលនៅក្នុងស្រុក អាចជាឧបសគ្គ យ៉ាងធំមួយ ចំពោះការវិនិយោគ CDM នៅក្នុងប្រទេសកម្ពុជា ។

## *8.2 បញ្ហាសារពើពន្ធ*

ពន្ធអាករ ដែលពាក់ព័ន្ធជាមួយនឹងគំរោង CDM នៅក្នុងប្រទេសកម្ពុជា គឺពន្ធប្រាក់ចំណេញ ពន្ធលើតំលៃបន្ថែម (VAT) អាករនាំចូល ពន្ធប៉ាតង់ និងពន្ធចុះបញ្ជីដីធ្លីនិងយានយន្ត (តារាងទី 8.1) ។ គ្រប់នីតិបុគ្គលទាំងអស់ ដែល ត្រូវបានកំណត់ថា ជា "អ្នកបង់ពន្ធដែលតាំងទីលំនៅ" ត្រូវមានកាតព្វកិច្ចបង់ពន្ធ នៅក្នុងប្រទេសកម្ពុជា ។ នីតិបុគ្គល ម្នាក់គឺជាអ្នកបង់ពន្ធដែលតាំងទីលំនៅ ប្រសិនបើបំពេញលក្ខណៈវិនិច្ឆ័យមួយ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យខាងក្រោម : (1) នីតិបុគ្គលមានទីកន្លែងប្រកបអាជីវកម្មចំបងនៅក្នុងប្រទេសកម្ពុជា (2) អាជីវកម្មនេះត្រូវបានរៀបចំ ឬគ្រប់គ្រង នៅក្នុងប្រទេសកម្ពុជា (3) វាជាទីតាំងអាជីវកម្មអចិន្ត្រៃយ៍ សាខារបស់ក្រុមហ៊ុនបរទេស ឬអ្នកតាំងទីលំនៅ ដែលជា ភ្នាក់ងារនៅក្នុងប្រទេសកម្ពុជា ដែលអ្នកពុំតាំងទីលំនៅប្រកបអាជីវកម្មនៅក្នុងប្រទេសកម្ពុជាតាមរយៈខ្លួន ឬ (4) សមាគមនានាដទៃទៀត ដែលអ្នកពុំតាំងទីលំនៅចូលរួមនៅក្នុង "សកម្មភាពសេដ្ឋកិច្ច" ក្នុងប្រទេសកម្ពុជា តាម រយៈខ្លួន ។ "គ្រឹះស្ថានជំនួញអចិន្ត្រៃយ៍" ដូចដែលបានកំណត់នៅក្នុងលក្ខណៈវិនិច្ឆ័យទី 3 និងទី 4 គឺជាប់ពន្ធតែលើ ប្រភពចំណូលពីប្រទេសកម្ពុជាតែប៉ុណ្ណោះ ។

- *ពន្ធលើប្រាក់ចំណេញ :* ពន្ធលើប្រាក់ចំណេញត្រូវបានដាក់ លើគ្រប់អាជីវកម្មទាំងអស់ ។ ពន្ធនេះអាចត្រូវបាន គណនា ដោយផ្អែកលើប្រាក់ចំណេញជាក់ស្តែង ឬប្រាក់ចំណេញប៉ាន់ស្មាន ។ អត្រាពន្ធលើប្រាក់ចំណេញគឺ 20 ភាគរយ សំរាប់គ្រប់អ្នកជាប់ពន្ធទាំងអស់ ។ អ្នកជាប់ពន្ធត្រូវបង់ពន្ធលើប្រាក់ចំណេញជាមុនប្រចាំខែ ដែលស្មើនឹង មួយភាគរយនៃប្រាក់ចំណូលប្រចាំខែ ។ ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធ ដែលទទួលបានពីគ្រប់ ប្រភេទប្រតិបត្តិការទាំងអស់ ដែលដឹងដោយអ្នកជាប់ពន្ធ ។
- *ពន្ធលើតំលៃបន្ថែម :* VAT 10 ភាគរយជាលក្ខណៈស្តង់ដា អាចកំណត់បាននៅលើទំនិញ និងសេវាកម្មជាច្រើន ប្រភេទ ដូចជាទំនិញនាំចូល និងទំនិញប្រើហើយជាដើម ។ ចំពោះការនាំចូល VAT ត្រូវបានគិតនៅលើតំលៃនៃ ការនាំចូល ដូចជាពន្ធគយ ថ្លៃធានារ៉ាប់រង និងថ្លៃដឹកជញ្ជូនជាដើម ។ ការនាំចេញទំនិញ និង សេវាកម្ម ត្រូវបាន លើកលែងពន្ធ ។
- *ពន្ធនាំចូល :* ពន្ធនាំចូល ដូចដែលបានកំណត់ដោយតារាងពន្ធគយ មានពី 7 ដល់ 35 ភាគរយ ។ ជំនួយមនុស្សធម៌ និងទំនិញនានាដែលពាក់ព័ន្ធនឹងទំនាក់ទំនងអន្តរជាតិ ត្រូវបានលើកលែងពន្ធ ។

- *ពន្ធប៉ាតង់ :* គ្រប់អាជីវកម្មទាំងអស់ត្រូវបង់ថ្លៃប៉ាតង់ប្រចាំឆ្នាំ ឬ "ពន្ធចុះបញ្ជីការអាជីវកម្ម" ចំនួន 300 ដុល្លារ ទៅឱ្យអាជ្ញាធរពន្ធដារ ។
- *ពន្ធចុះបញ្ជីដីធ្លី និងយានយន្ត :* ពន្ធចុះបញ្ជីចំនួន 4 ភាគរយ ត្រូវបានគិតទៅលើកម្មសិទ្ធិអចលនទ្រព្យ ឬទ្រព្យអចល័ត ដែលកើតឡើងដោយសារការផ្ទេរដោយផ្ទាល់ ឬជាផ្នែកនៃមូលធនរបស់សហគ្រាសមួយ ។ តំលៃពន្ធនេះមានមូលដ្ឋាននៅលើតំលៃវាយតំលៃរបស់ដី ។ ពន្ធចុះបញ្ជីចំនួន 4 ភាគរយ ក៏ត្រូវបានគិតផងដែរ លើការផ្ទេរកម្មសិទ្ធិយានយន្តជំនិះ និងទូក ។

តារាងទី 8.1 សេចក្ដីសង្ខេបនៃអត្រាពន្ធរបស់កម្ពុជា

| ពន្ធលើប្រាក់ចំណេញ | ពន្ធលើតំលៃបន្ថែម | ពន្ធនាំចូល | ពន្ធប៉ាតង់ (ការចុះបញ្ជីការអាជីវកម្ម) | ពន្ធចុះបញ្ជីដីធ្លី និងយានយន្ត |
|---|---|---|---|---|
| 20% | 10% | 0%, 7%, 15% ឬ 35% | 300 ដុល្លារប្រចាំឆ្នាំ | 4% នៃតំលៃ |

# 9. ការលើកទឹកចិត្តរបស់រដ្ឋាភិបាល

## 9.1 ការលើកទឹកចិត្តលើការវិនិយោគបរទេស

រាជរដ្ឋាភិបាលកម្ពុជាមានគោលបំណង បង្កើតនូវបរិយាកាសមួយ ដែលសំរួលដល់ការចូលរួមពីសំណាក់វិស័យឯកជន និងដើម្បីធ្វើឱ្យកាន់តែប្រសើរ និងសំរបសំរួលឱ្យមានការវិនិយោគបរទេស និងក្នុងស្រុក តាមរយៈនីតិវិធីផ្តល់ការអនុម័ត ដែលមានល្បឿនលឿន ។ ប្រទេសកម្ពុជាផ្តល់ឱ្យវិនិយោគិនបរទេស នូវអ្វីមួយដែលអាចជាកញ្ចប់វិនិយោគដែលមានលក្ខណៈប្រកួតប្រជែងជាងគេ នៅក្នុងតំបន់ (UNCTAD និង ICC 2003) ។ ការធ្វើវិសោធនកម្មលើច្បាប់ស្តីពីការវិនិយោគឆ្នាំ 2003 ផ្តល់អត្ថប្រយោជន៍ខាងក្រោមនេះ ដល់អ្នកវិនិយោគ ដែលមានសិទ្ធិទទួល (CDC 2004) :

1. ការរួចពន្ធរយៈពេល 3 ឆ្នាំដោយស្វ័យប្រវត្តិ ហើយអាចបន្ថែម 3 ឆ្នាំទៀត ដោយចាប់ផ្តើមពីឆ្នាំទី 1 ដែលអាចរកប្រាក់ចំណេញបាន ឬបីឆ្នាំពីចំណូលដំបូង មួយណាក៏បានដែលមានមុនគេ (សូមមើលខាងក្រោម សំរាប់ការពិភាក្សាបន្ថែម)
2. ការលើកលែងពន្ធនាំចូល សំរាប់សំភារៈសំណង់ គ្រឿងបរិក្ខារផលិតកម្ម និងវត្ថុធាតុដើមសំរាប់គំរោងវិនិយោគដើម្បីនាំចេញ និងសំរាប់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគំរោងថាមពល
3. ការធានាទប់ទល់នឹងជាតូបនីយកម្ម
4. កិច្ចសន្យាជួលដី ដែលអាចបន្តថ្មី រហូតដល់រយៈពេល 99 ឆ្នាំ លើដីសម្បទាន សំរាប់គោលបំណងកសិកម្ម
5. ការលើកលែងពន្ធនាំចេញ
6. ផ្តល់ការងារឱ្យជនបរទេស សំរាប់ការងារណា ដែលជនជាតិខ្មែរពុំមានសមត្ថភាពធ្វើបាន
7. ពុំមានការគ្រប់គ្រងថ្លៃ លើផលិតផល និងសេវាកម្ម ដែលផលិតដោយគំរោងវិនិយោគ
8. ពុំមានជាតូបនីយកម្ម ដែលជះឥទ្ធិពលអវិជ្ជមានដល់ទ្រព្យសម្បត្តិរបស់វិនិយោគិន
9. ការផ្ទេររូបិយប័ណ្ណបរទេស ទៅក្រៅប្រទេស ។

បន្ថែមលើសមាជិកភាពរបស់ខ្លួនក្នុងអង្គការពាណិជ្ជកម្មពិភពលោក ប្រទេសកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគទ្វេភាគី ជាមួយនឹងប្រទេសដទៃទៀត (ប្រអប់ 9.1) ដែលរួមទាំងប្រទេសហត្ថលេខីជាច្រើនរបស់ពិធីសារក្យូតូ ។ កិច្ចព្រមព្រៀងទាំងនេះផ្តល់នូវការប្រតិបត្តិលក្ខណៈជាតិទៅវិញទៅមកដល់វិនិយោគិន ហាមឃាត់មិនឱ្យមានការដកហូតទ្រព្យសម្បត្តិដែលខុសច្បាប់ឬដែលមានការរើសអើង ធានាឱ្យមានការបញ្ជូនការវិនិយោគទៅកាន់ប្រទេសដើមវិញ និងបង្កើតឱ្យមានការដោះស្រាយវិវាទការវិនិយោគតាមរយៈអាជ្ញាកណ្តាល ។

ប្រអប់ទី 9. 1 បណ្តាប្រទេសសំខាន់ៗ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគទ្វេភាគីជាមួយ

| | | |
|---|---|---|
| • ចិន | • ម៉ាឡេស៊ី | • ហុល្លង់ |
| • បារាំង | • សាធារណៈរដ្ឋកូរ៉េ | |
| • អាល្លឺម៉ង់ | • ស្វីស | |

## *9.2 ការលើកទឹកចិត្តពន្ធបន្ថែម*

ដូចដែលបានពិភាក្សារួចមកហើយនៅក្នុងវគ្គមុន ការរួចពន្ធរយៈពេល 3 ឆ្នាំ ដោយស្វ័យប្រវត្តិ ត្រូវបានផ្តល់ទៅឱ្យគំរោងវិនិយោគដោយផ្ទាល់ពីបរទេស នៅក្នុងប្រទេសកម្ពុជា ហើយរយៈពេល 3 ឆ្នាំទៀត អាចត្រូវបានផ្តល់ទៅឱ្យគំរោងនានា ដែលសមស្រប ។ វគ្គនេះ ពិភាក្សាពីការលើកទឹកចិត្តនានា ដែលផ្តល់ដោយអនុក្រឹតស្តីពីការអនុវត្តច្បាប់ស្តីពីការវិនិយោគ ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ 1997 ហើយទំនងជានឹងត្រូវពិនិត្យឡើងវិញ ដើម្បីអនុលោមទៅតាមវិសោធនកម្មច្បាប់ស្តីពីការវិនិយោគឆ្នាំ 2003 ។ ប្រអប់ 9.2 សង្ខេបពីវិស័យនានា ដែលពាក់ព័ន្ធ សំរាប់គំរោង CDM ដែលគេអាចយកការលើកទឹកចិត្តមកអនុវត្តជាមួយបាន ។

ប្រអប់ទី 9.2 វិស័យវិនិយោគ CDM ប្រកបដោយសក្តានុពល ដែលអាចយកការលើកទឹកចិត្តមកអនុវត្តជាមួយបាន

- ផលិតកម្មកសិផល
  - ការធ្វើស្រែលើផ្ទៃដីធំជាង 1.000 ហិចតា
  - គ្រប់ប្រភេទនៃដំណាំលក់យកប្រាក់លើផ្ទៃដីធំជាង 500 ហិចតា
  - ការដាំបន្លែនៅលើផ្ទៃដីធំជាង 50 ហិចតា
- ផលិតកម្មបសុសត្វ
  - បសុសត្វច្រើនជាង 1,000 ក្បាល
  - ការចិញ្ចឹមសត្វយកទឹកដោះច្រើនជាង 100 ក្បាល
- ការផលិតក្រដាស និងផលិតផលខ្សែស្រឡាយ ( ដោយមានទុនវិនិយោគច្រើនជាង 1 លានដុល្លារ)
  - ការដាំដើមឈើដើម្បីយកមកផលិតក្រដាស
  - ផលិតកម្មក្រដាស
  - រោងចក្រផលិតក្រដាសកាតុង
  - ឡាំងក្រដាសកាតុង
- ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដើម្បីគាំទ្រដល់វិស័យទេសចរណ៍ និងវប្បធម៌
- សកម្មភាពផលិត និងទាញយកប្រយោជន៍ ដើម្បីការពារបរិស្ថាន

*កំណត់សំគាល់ :* យោងទៅតាមអនុក្រឹតលេខ 88 ឆ្នាំ 1997 ។

យោងទៅតាមអនុក្រឹតលេខ ៨៨ សកម្មភាពផលិត និងទាញយកប្រយោជន៍ ដើម្បីការពារបរិស្ថាន មានសិទ្ធិទទួលបានការលើកទឹកចិត្តផ្នែកពន្ធ ។ ដូច្នេះ អាចមានអំណះអំណាងលើកឡើងថា គ្រប់គំរោង CDM ទាំងអស់ សុទ្ធតែស្ថិតនៅក្នុងប្រភេទនេះ ព្រោះគំរោងទាំងនោះមានគោលបំណងជួយប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការកាត់បន្ថយការបញ្ចេញ GHG ហើយក្នុងពេលជាមួយគ្នានេះដែរ អាចសំរេចគោលដៅនៃការអភិវឌ្ឍដោយចីរភាព ។

សំរាប់គំរោងនៅក្នុងបណ្តាវិស័យ ដែលមានសិទ្ធិទទួលការលើកទឹកចិត្ត ម៉ាទ្រិចមួយដែលត្រូវបានបែងចែកជាលក្ខណៈវិនិច្ឆ័យផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គម ត្រូវបានយកមកអនុវត្តបន្ថែម ដើម្បីកំណត់ចំនួនឆ្នាំរួចពន្ធបន្ថែម ដែលអាចផ្តល់ឱ្យ ។ ករិតនៃតម្លៃឆ្លើយតបចំពោះលក្ខណៈវិនិច្ឆ័យនីមួយៗ ដែលធម្មតាគិតជាភាគរយ ហើយចំនួនសរុបត្រូវបានប្រើប្រាស់ ដើម្បីកំណត់ចំនួនឆ្នាំរួចពន្ធបន្ថែម ដែលត្រូវផ្តល់ទៅឱ្យគំរោងវិនិយោគ ។ លក្ខណៈវិនិច្ឆ័យសង្គមចំនួនពីរ ដែលត្រូវបានប្រើប្រាស់ គឺការងារស្ត្រី និងការងារជនពិការ (គិតជាភាគរយនៃកំលាំងពលកម្ម) ។ លក្ខណៈវិនិច្ឆ័យសេដ្ឋកិច្ចរួមមាន ទីតាំងរបស់គំរោងនៅក្នុងខេត្តមិនសូវល្អដូចគេ ចំនួនទុនវិនិយោគ ចំនួននិយោជិកកម្ពុជា ភាគរយនៃផលិតកម្មនាំចេញ ភាគរយនៃតម្លៃបន្ថែម ភាគរយនៃធនធានក្នុងស្រុកដែលបានប្រើប្រាស់ និង ចំនួនថ្ងៃបណ្តុះបណ្តាល សំរាប់បុគ្គលិកកម្ពុជា[17] ។

## *9.3 ការលើកទឹកចិត្តផ្នែកថាមពលកកើតឡើងវិញ*

ផែនការសកម្មភាពអគ្គិសនីដោយថាមពលកកើតឡើងវិញ (REAP) របស់កម្ពុជា ដែលត្រូវបានគាំទ្រដោយធនាគារពិភពលោក គឺជាគំនិតផ្តួចផ្តើម ដើម្បីជួយដល់ប្រទេសកម្ពុជា នៅក្នុងការប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ (REAP 2001) ។ REAP បានចាប់ផ្តើមសកម្មភាពរបស់ខ្លួននៅក្នុងឆ្នាំ 2001 នឹងមានរយៈពេលមួយទសវត្សរ៍ (REAP 2001; ធនាគារពិភពលោក 2002) ។ ផែនការនេះមានគោលដៅសំខាន់ ដើម្បី " លើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសសហគមន៍ជនបទ តាមរយៈការធ្វើការរួមគ្នា និងការចែករំលែកចំណេះដឹង និងព័ត៌មាន ដើម្បីបង្កើតយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព និងផែនការការងារមួយ សំរាប់ការផលិតអគ្គិសនី ដែលមានតំលៃសមស្រប និងដែលអាចទុកចិត្តបាន ពីអគ្គិសនីដោយថាមពលកកើតឡើងវិញ " ។

REAP មានចក្ខុវិស័យឆ្ពោះទៅរកភាពជាដៃគូយ៉ាងសកម្មមួយ រវាងវិស័យសាធារណៈ និងវិស័យឯកជន ដើម្បីបង្កើតបរិយាកាសល្អប្រសើរមួយ សំរាប់ឱកាសវិនិយោគនៅក្នុងផ្នែកអគ្គិសនីដោយថាមពលកកើតឡើងវិញ ជាពិសេសខាងវារីអគ្គិសនី និងថាមពលព្រះអាទិត្យ ។ ចក្ខុវិស័យរបស់ REAP គឺជាស្ថានភាពមួយ ដែលអគ្គិសនីភាវូបនីយកម្មតាមតំបន់ជនបទ អាចបំពេញបាននូវសេចក្តីត្រូវការរបស់សហគមន៍ និងលើកកំពស់ជីវភាពរស់នៅរបស់ពួកគេ ហើយក្នុងពេលជាមួយគ្នានេះ " លើកកំពស់ និងធានានិរន្តរភាពបូរណភាពរបស់ពិភពធម្មជាតិ " ។ កាន់តែជាក់លាក់ជាងនេះទៅទៀត REAP បានដាក់ចេញនូវបញ្ជីគោលដៅមួយ ដែលត្រូវសំរេចឱ្យបាននៅក្នុងទសវត្សរ៍ខាងមុខ (ប្រអប់ទី 9.3) ។

---

16. ម៉ាទ្រិចនៃលក្ខណៈវិនិច្ឆ័យមាននៅក្នុងសេចក្តីបន្ថែមទី IV ។

ប្រអប់ទី 9.3 គោលដៅ 10 ឆ្នាំនៃផែនការសកម្មភាពអគ្គិសនីកកើតឡើងវិញ

- 6 មេហ្គាវ៉ាត់ពីធនធានកកើតឡើងវិញ
- បំរើសេវាកម្មដល់ 100.000 គ្រួសារ
- តម្លើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះចំនួន 10.000
- ទីផ្សារអគ្គិសនីកកើតឡើងវិញតាមតំរូវការទីផ្សារ ហើយដែលអាចទទួលផលចំណេញ

*ប្រភព :* ធនាគារពិភពលោក 2002 ។

ដើម្បីសំរេចគោលដៅរបស់ខ្លួន REAP នឹងបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មដោយថាមពលកកើតឡើងវិញនៅតំបន់ជនបទ (REF) ជាស្ថាប័នឯករាជ្យ ដែលមានស្វ័យភាពស្របច្បាប់ ( ប្រអប់ទី 9.4) ។ មានស្រទាប់ចំនួន 3 នៅក្នុង "រចនាសម្ព័ន្ធគ្រប់គ្រង/រដ្ឋបាល" របស់ REF គឺ : (1) ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងហិរញ្ញវត្ថុ ដែលមានមហាសន្និបាតរបស់អ្នកដែលមានការពាក់ព័ន្ធជាទីប្រឹក្សាផ្តល់យោបល់ (2) គណៈកម្មការនាយកដែលគេហៅថា ក្រុមប្រឹក្សាអគ្គិសនីភាវូបនីយកម្មជនបទ (REB) និង (3) នាយកប្រតិបត្តិ និងលេខាធិការដ្ឋានរបស់ REF ។ សន្និបាតអ្នកដែលមានការពាក់ព័ន្ធរួមមាន អ្នកផ្តល់ជំនួយ ស្ថាប័នហិរញ្ញវត្ថុ សហគ្រាសថាមពលកកើតឡើងវិញ អ្នកផ្គត់ផ្គង់ទំនិញនិងសេវាកម្មថាមពលកកើតឡើងវិញ ក្រសួងនិងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការអភិវឌ្ឍជនបទ និងអង្គការមិនមែនរដ្ឋាភិបាល ។

ចំណាប់អារម្មណ៍ជាពិសេសចំពោះអ្នករៀបចំគំរោង CDM គឺការមានឧបត្ថម្ភធនសំរាប់គំរោងថាមពលកកើតឡើងវិញ ។ REF នឹងប្រើឧបត្ថម្ភធន សំរាប់សកម្មភាពជំនួយផ្សព្វផ្សាយ និងបច្ចេកទេស ក៏ដូចជាសំរាប់ "ការវិនិយោគរឹង" នៅ ក្នុងគំរោងអគ្គិសនីកកើតឡើងវិញ ។

គោលនយោបាយរបស់ REF សំរាប់ផ្តល់ជំនួយដល់គំរោងបច្ចេកវិទ្យាថាមពលកកើតឡើងវិញ ត្រូវបានពិពណ៌នានៅក្នុងឯកសារគោលគំនិតរបស់ធនាគារពិភពលោក ដូចតទៅ ( ធនាគារពិភពលោក 2002) : "REF លើកកំពស់ការវិនិយោគផ្នែកបច្ចេកវិទ្យាថាមពលកកើតឡើងវិញ (RET) ដរាបណាការវិនិយោគទាំងនេះគឺជាដំណោះស្រាយដែលមានការចំណាយតិចជាងគេ ដើម្បីបំពេញតំរូវការថាមពលរបស់អតិថិជនអ្នកប្រើប្រាស់ម្នាក់ៗ ឬក្នុងករណីផលិតអគ្គិសនីភ្ជាប់បណ្តាញដោយប្រើ RET វាអាចផ្គត់ផ្គង់ថាមពល យ៉ាងហោចណាស់ក្នុងតំលៃថោក ដូចអគ្គិសនីដែលផលិតដោយម៉ាស៊ីនភ្លើងធម្មតា ។ ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះសំរាប់គ្រួសារនៅដាច់ឆ្ងាយពីបណ្តាញពេក ដើម្បីធ្វើឱ្យការភ្ជាប់បណ្តាញដែលមានលក្ខណៈសមស្របផ្នែកសេដ្ឋកិច្ច ក្នុងរយៈពេល 5 ឆ្នាំ ឬលើសពីនេះ គឺជា [*sic*] ឧទាហរណ៍មួយ ។ មួយទៀត [*sic*] គឺជាវារីអគ្គិសនីខ្នាតតូចភ្ជាប់បណ្តាញ និងម៉ាស៊ីនភ្លើងប្រើប្រាស់ធនធានជីវម៉ាស"។ គោលនយោបាយនេះ កំពុងតែស្ថិតនៅក្រោមការពិភាក្សា ។ ប៉ុន្តែ នៅក្នុងរយៈពេលវែង មូលនិធិនេះអាចត្រូវបានបំពេញជាថ្មី តាមរយៈថ្លៃបញ្ជូន និងថ្លៃប្រើប្រាស់អគ្គិសនី ។

ប្រអប់ទី 9.4 តួនាទីរបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ និងថាមពលកកើតឡើងវិញ

> ផ្តត់ផ្តង់អគ្គិសនីប្រកបដោយប្រសិទ្ធភាពចំណាយ ទៅដល់អតិថិជនប្រើប្រាស់តាមទីជនបទ តាមរយៈ :
> - តំរង់ទិសដៅជំនួយ និងជំនួយបច្ចេកទេស (TA) ដែលមានប្រសិទ្ធភាពចំណាយ ដូចជាជំនួយសំរាប់ TA និងការវិនិយោគទុនសំរាប់សហគ្រាសអគ្គិសនីជនបទ អ្នកផ្តល់ប្រឹក្សា អន្តរការីហិរញ្ញវត្ថុ និងក្រុមហ៊ុនសំណង់ ដែលពាក់ព័ន្ធជាមួយនឹងគំរោងថាមពលជនបទ
> - ផ្តល់ឧបត្ថម្ភធនសំរាប់ការវិនិយោគរឹង ទៅដល់គ្រប់អ្នករៀបចំគំរោងទាំងអស់ រួមទាំង EDC និង
> - ផ្តល់ការគាំទ្រដល់ទីផ្សារប្រព័ន្ធពន្លឺព្រះអាទិត្យតាមផ្ទះដែលទើបចាប់ផ្តើមថ្មី

*ប្រភព :* ដកស្រង់ចេញពីធនាគារពិភពលោក 2002 ។

ដូចដែលបានពិភាក្សានៅក្នុង Williamson et al. (2004) REF នឹងផ្តល់ឧបត្ថម្ភធនដល់អគ្គិសនីភាវូបនីយកម្មជនបទ ដែលនឹងផ្តល់ប្រភពមូលនិធិបន្ថែម សំរាប់គំរោង CDM សក្តានុពលនានា ។ ប៉ុន្តែ គំរោងវ៉ារីអគ្គិសនីខ្នាតតូច និងគំរោង PV ចាំបាច់ត្រូវដាក់បញ្ចូលគ្នា ដើម្បីសំរេចបាននូវវិមាត្រសេដ្ឋកិច្ច ខាងផ្នែកថ្លៃដើមប្រតិបត្តិការ CDM ។ ដូចដែលបានគិតទុកកាលពីពេលថ្មីៗនេះ លេខាធិការដ្ឋាន REF នឹងអំពាវនាវសុំសំណើពីអ្នករៀបចំគំរោងឯកជន ដើម្បីអនុវត្តដំណោះស្រាយអគ្គិសនីភាវូបនីយកម្មជនបទ នៅកន្លែងមួយចំនួន ដូចខាងក្រោមនេះ :

- បណ្តាញខ្នាតតូចថ្មី ដែលមានមូលដ្ឋាននៅលើការបង្កើតអគ្គិសនីពីម៉ាស៊ីនម៉ាស៊ូត ថាមពលពន្លឺព្រះអាទិត្យ ឬ វ៉ារីអគ្គិសនី
- ពង្រីកប្រព័ន្ធបណ្តាញខ្នាតតូចដែលមានស្រាប់ ដើម្បីភ្ជាប់ទៅកាន់ផ្ទះថ្មីៗ
- ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ និង
- ប្រព័ន្ធវ៉ារីអគ្គិសនីខ្នាតតូច ឬមីក្រូ

គំរោងនឹងត្រូវបានជ្រើសរើស ដោយយោងទៅតាមលក្ខណៈវិនិច្ឆ័យសមស្រប ដែលពុំទាន់ត្រូវបានបង្កើតនៅឡើយ ហើយគំរោងដែលទទួលបានជោគជ័យ នឹងទទួលបានជំនួយ REF ។ ជំនួយនេះនឹងផ្តល់ឧបត្ថម្ភធនប្រហែលជា 25 ភាគរយនៃថ្លៃចំណាយសរុបរបស់គំរោង ហើយទុនឯកជនពីអ្នករៀបចំគំរោងនឹងផ្តល់ 25 ភាគរយទៀត ហើយកម្ចីធនាគារនៅសល់ 50 ភាគរយ (អត្រាឧបត្ថម្ភធនដែលបានស្នើ មាននៅក្នុងតារាងទី 9.1) ។ យ៉ាងណាក៏ដោយ នាពេលបច្ចុប្បន្ននេះ REF ពុំមានបំណងផ្តល់ការលើកទឹកចិត្តណាមួយ សំរាប់គំរោងជីវម៉ាសនោះទេ (សេចក្តីបន្ថែមទី VI មានបង្ហាញពីរបៀបសាយសំរាប់ព័ត៌មានបន្ថែម) ។

តារាងទី 9.1 អត្រាឧបត្ថម្ភធនរបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទដោយប្រើថាមពលកកើតឡើងវិញ ដែលបានស្នើឡើង គិតជាដុល្លារអាមេរិច

| **ប្រភេទគំរោង** | **ថ្លៃសរុប** | **ជំនួយរបស់ REF** |
| --- | --- | --- |
| ផ្ទះថ្មីភ្ជាប់ទៅនឹងបណ្តាញម៉ាស៊ូតខ្នាតតូចដែលមានស្រាប់ | 150 ដុល្លារ | 45 ដុល្លារ |
| វារីអគ្គិសនីខ្នាតតូច<br>( 5 MW) | 1,744 ដុល្លារ/kW<br>ដែលបានតម្លើង | 400 ដុល្លារ/kW<br>ដែលបានតម្លើង |
| វារីអគ្គិសនីមីក្រូ<br>( ជាមធ្យម 50 kW ) | 2,700 ដុល្លារ/kW<br>ដែលបានតម្លើង | 400 ដុល្លារ/kW<br>ដែលបានតម្លើង |
| ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ | 400 ដុល្លារ/មួយ 40 watt peak (Wp) | 400 ដុល្លារ/មួយ 40 Wp |

*ប្រភព :* Williamson et al. 2004 ។

